ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

# របាយការណ៍

# ស្ដីពី

# លទ្ធផលនៃការសិក្សាវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរ ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

រៀបចំដោយក្រុមការងារអន្តរក្រសួង

ខែឧសភា ឆ្នាំ២០២៣

គាំទ្រដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងកម្មវិធី ISD/GIZ

# មាតិកានុក្រម


**សេចក្តីសង្ខេប** ........................................ i

**១. សេចក្តីផ្តើម** ........................................ **១**

**២. គោលបំណង** ........................................ **៣**

**៣. ដែនកំណត់** ........................................ **៣**

**៤. យន្តការដឹកនាំសម្របសម្រួលការសិក្សាវាយតម្លៃ** ........................................ **៤**

**៥. វិធីសាស្ត្រនៃការសិក្សាវាយតម្លៃ** ........................................ **៤**

**៦. ការសិក្សាលើក្របខណ្ឌគតិយុត្ត និងលក្ខខណ្ឌនៃការផ្ទេរមុខងារ** ........................................ **៦**

៦.១. ការសិក្សាលើក្របខណ្ឌគតិយុត្ត ........................................ ៦

៦.២. លក្ខខណ្ឌនៃការផ្ទេរមុខងារ ........................................ ៧

**៧. របកគំហើញ** ........................................ **១១**

**៧.១. ចំណុចសំខាន់ៗនៃការសិក្សាវាយតម្លៃ** ........................................ **១១**

**៧.២.លទ្ធផលនៃការរកឃើញនៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង** ........................................ **១៣**

៧.២.១. ការគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡា ........................................ ១៣

៧.២.២. ការគ្រប់គ្រងសាលារៀន ........................................ ១៦

៧.២.៣. ការគ្រប់គ្រងបុគ្គលិកអប់រំ ........................................ ១៩

៧.២.៤. ការគ្រប់គ្រង និងការប្រើប្រាស់ថវិកា ........................................ ២២

៧.២.៥. ការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិ ........................................ ២៧

៧.២.៦. ទំនាក់ទំនងការងារ និងគណនេយ្យភាព ........................................ ២៩

**៧.៣.លទ្ធផលនៃការរកឃើញរដ្ឋបាលក្រុង ស្រុកក្នុងខេត្តក្រចេះ និងខេត្តកំពត** ........................................ **៣២**

៧.៣.១. ការគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡា ........................................ ៣២

៧.៣.២. ការគ្រប់គ្រងសាលារៀន ........................................ ៣៤

៧.៣.៣. ការគ្រប់គ្រងបុគ្គលិកអប់រំ ........................................ ៣៦

៧.៣.៤. ការគ្រប់គ្រង និងការប្រើប្រាស់ថវិកា ........................................ ៣៨

៧.៣.៥. ការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិ ........................................ ៤២

៧.៣.៦. ទំនាក់ទំនងការងារ និងគណនេយ្យភាព ........................................ ៤៣

**៨. ការវិភាគ និងអនុសាសន៍** ........................................ **៤៤**

៨.១. ការវិភាគ ........................................ ៤៤

៨.២. អនុសាសន៍ ........................................ ៥៦

**៩. សេចក្តីសន្និដ្ឋាន** ........................................ **៦០**

**១០. ឧបសម្ព័ន្ធ** ........................................ **៦១**

# លិខិតថ្លែងអំណរគុណ

ក្នុងនាមក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់ការសិក្សាវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.អ.ប.** ដែលបានផ្តល់គោលការណ៍អនុញ្ញាត ការណែនាំតម្រង់ទិសជាគន្លឹះៗ និងការគាំទ្រដល់កិច្ចដំណើរការសិក្សាវាយតម្លៃឱ្យប្រព្រឹត្តទៅដោយភាពរលូន ព្រមទាំងការដឹកនាំកិច្ចប្រជុំ គ.ជ.អ.ប. ដើម្បីពិនិត្យ ពិភាក្សា ព្រមទាំងសម្របសម្រួលឱ្យមានការឯកភាពគ្នាជាឯកច្ឆន្ទទៅលើរបាយការណ៍នៃការសិក្សាវាយតម្លៃនេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអនុគណៈកម្មាធិការមុខងារ និងធនធាននៃ គ.ជ.អ.ប. ដែលបានពិនិត្យ ពិភាក្សា និងផ្តល់ធាតុចូលដ៏មានសារៈសំខាន់ដើម្បីធានាឱ្យរបកគំហើញ និងការវិភាគនៃការសិក្សាវាយតម្លៃនេះកាន់មានភាពសុក្រឹត និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

សូមថ្លែងអំណរគុណជាអនេកចំពោះថ្នាក់ដឹកនាំរដ្ឋបាលរាជធានី ខេត្ត ថ្នាក់ដឹកនាំនៃមន្ទីរជំនាញពាក់ព័ន្ធ ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ថ្នាក់ដឹកនាំនៃការិយាល័យពាក់ព័ន្ធនានា នាយកសាលា លោកគ្រូ អ្នកគ្រូ មេឃុំ ចៅសង្កាត់ និងមាតាបិតាសិស្សដែលបានចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមក្នុងកិច្ចដំណើរការសិក្សាវាយតម្លៃនេះ ដោយបាននូវផ្តល់ព័ត៌មានពិតជាក់ស្តែងដ៏មានសារៈសំខាន់ជាច្រើនដល់ក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់ការសិក្សាវាយតម្លៃនេះ។

សូមថ្លែងអំណរគុណ និងការវាយតម្លៃខ្ពស់ចំពោះក្រុមការងារបច្ចេកទេសអន្តរក្រសួងសិក្សាវាយតម្លៃដែលបានចូលរួមដឹកនាំ និងសម្របសម្រួលក្នុងដំណើរការនៃការសិក្សាវាយតម្លៃតាំងពីដំណាក់កាលដំបូងរហូតដល់ការរៀបចំបញ្ចប់នៃរបាយការណ៍សិក្សាវាយតម្លៃនេះ។ ការសិក្សាវាយតម្លៃនេះនឹងមិនអាចទទួលបានលទ្ធផលជាផ្លែផ្កាតាមការគ្រោងទុកបានឡើយ បើសិនជាពុំមានការចូលរួមយ៉ាងសកម្ម និងប្រកបដោយស្មារតីទទួលខុសត្រូវពីសមាជិកនៃក្រុមការងារបច្ចេកទេសអន្តរក្រសួង។

សូមថ្លែងអំណរគុណដល់កម្មវិធី "ធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាជូនប្រជាពលរដ្ឋនៃអង្គការ GIZ" ដែលបានផ្តល់ទីប្រឹក្សាបច្ចេកទេស និងការគាំទ្រដល់សកម្មភាពមួយចំនួនក្នុងកិច្ចដំណើរការសិក្សាវាយតម្លៃនេះឱ្យទទួលបានជោគជ័យតាមការគ្រោងទុក។

**ប្រធានក្រុមការងារបច្ចេកទេសអន្តរក្រសួង**

**ចាន់ សុធា**

## សេចក្តីសង្ខេប

ផ្អែកតាមផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ២០២២របស់គ.ជ.អ.ប. និងសេចក្តីសម្រេចលេខ ០៣១ ស.ស.រ./គ.ជ.អ.ប. ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់សិក្សាវាយតម្លៃការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ លេខាធិការដ្ឋាន គ.ជ.អ.ប. បានដឹកនាំសម្របសម្រួលក្រុមការងារបច្ចេកទេសអន្តរក្រសួងដែលមានសមាសភាពមកពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីសិក្សាវាយតម្លៃលើការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌតាមដំណើរការ និងទទួលបានលទ្ធផលដូចមានសង្ខេបខាងក្រោម៖

### I. អំពីគោលបំណង និងកិច្ចដំណើរការនៃការសិក្សាវាយតម្លៃ

ការសិក្សាវាយតម្លៃនេះបានផ្តោតលើប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយពុំទាន់បានផ្តោតស៊ីជម្រៅលើគុណភាពនៃសេវាអប់រំឡើយ ដោយសារក្នុងអំឡុងពេលនៃការផ្ទេរមុខងារអប់រំនេះចំពេលដែលប្រទេសកម្ពុជាជួបវិបត្តិកូវីដ-១៩ ហើយសាលារៀននានាត្រូវបានបិទដំណើរការមួយរយៈពេល និងត្រូវផ្លាស់ប្តូរវិធីសាស្ត្របង្រៀនតាមប្រព័ន្ធអនឡាញ (ONLINE) ជាដើម។

ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានចុះទៅសិក្សាវាយតម្លៃនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន១៧ក្នុងរាជធានី ខេត្តចំនួន៥ គឺរដ្ឋបាលក្រុង ស្រុកចំនួន៧ក្នុងខេត្តបាត់ដំបង រដ្ឋបាលក្រុង ស្រុកចំនួន៣ក្នុងខេត្តក្រចេះ រដ្ឋបាលក្រុង ស្រុកចំនួន៣ក្នុងខេត្តកំពត រដ្ឋបាលក្រុង ស្រុកចំនួន២ក្នុងខេត្តកណ្តាល និងរដ្ឋបាលខណ្ឌចំនួន២ក្នុងរាជធានីភ្នំពេញ។ ក្នុងការចុះសិក្សាវាយតម្លៃនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានជួបសម្ភាសន៍ជាមួយថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលា លោកគ្រូ អ្នកគ្រូ មេឃុំ ចៅសង្កាត់ តំណាងមាតាបិតាសិស្ស ថ្នាក់ដឹកនាំខេត្ត មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរមុខងារសាធារណៈ និងរតនាគារខេត្ត ដែលមានចំនួនសរុប**ប្រមាណជាង៧០០នាក់**។ ក្នុងការជួបសម្ភាសន៍ និងការពិភាក្សាការងារជាមួយអ្នកពាក់ព័ន្ធខាងលើ ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានប្រើប្រាស់បញ្ជីសំណួរចំនួន២ប្រភេទ គឺបញ្ជីសំណួរសម្រាប់ស្ទង់មតិជាលក្ខណៈបុគ្គល និងបញ្ជីសំណួរសម្រាប់ពិភាក្សាជាក្រុមដោយផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ការគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡាបន្ទាប់ពីបានធ្វើសមាហរណកម្មមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការគ្រប់គ្រងសាលារៀនបន្ទាប់ពីការផ្ទេរមុខងារអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការគ្រប់គ្រងបុគ្គលិកអប់រំដែលបានផ្ទេរមកជាបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការប្រើប្រាស់ថវិកាសម្រាប់អនុវត្តមុខងារអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការប្រើប្រាស់ទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារអប់រំដែលបានផ្ទេរមកក្រុង ស្រុក ខណ្ឌ

- ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្ត មុខងារអប់រំដែលបានផ្ទេរឱ្យ។

ព័ត៌មាន និងទិន្នន័យនានាដែលប្រមូលបានពីការចុះសិក្សាវាយតម្លៃនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗត្រូវបានបូកសរុបជាសេចក្ដីព្រាងរបាយការណ៍បឋម និងបានដាក់ឱ្យពិនិត្យ ពិភាក្សាក្នុងសិក្ខាសាលាពិគ្រោះយោបល់មួយដែលបានរៀបចំឡើងនាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយមានអ្នកចូលរួមពីតំណាងពីក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាដែលមានចំនួនសរុបប្រមាណ១៧០នាក់។ ផ្អែកតាមមតិយោបល់ និងធាតុចូលនានាដែលទទួលបានពីសិក្ខាសាលាពិគ្រោះយោបល់ ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានរៀបចំបញ្ចប់សេចក្ដីព្រាងរបាយការណ៍លម្អិតស្ដីពីលទ្ធផលនៃការសិក្សាវាយតម្លៃការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## II. អំពីរបកគំហើញ

ផ្អែកតាមព័ត៌មានដែលប្រមូលបានពីការចុះទៅសិក្សាវាយតម្លៃនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសិក្ខាសាលាពិគ្រោះយោបល់ ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានវាយតម្លៃអំពីស្ថានភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលមានសង្ខេបដូចខាងក្រោម៖

### ក. ការគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡា

**ចំណុចវិជ្ជមាន៖**

ការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌបានធ្វើឱ្យការបំពេញការងារនិងការទទួលខុសត្រូវរបស់ការិយាល័យនេះកាន់តែមានលក្ខណៈល្អប្រសើរ និងបានជំរុញឱ្យក្រុមប្រឹក្សា និងគណៈអភិបាលមានការទទួលខុសត្រូវកាន់តែច្បាស់លាស់ក្នុងការដឹកនាំ ការគ្រប់គ្រង និងមានទំនាក់ទំនងការងារកាន់តែជិតស្និទ្ធជាមួយមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡា។ មន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡាបានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា និងកិច្ចប្រជុំនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌជាទៀងទាត់ ដោយបានរាយការណ៍អំពីស្ថានភាពការងារអប់រំ និងបញ្ហាប្រឈមនានាដែលត្រូវដោះស្រាយ និងការគាំទ្រពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ប្រការនេះបានធ្វើឱ្យថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌក្ដាប់បានការងារអប់រំ និងដោះស្រាយបញ្ហាលំបាកនានាបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ហើយមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡាក៏កាន់តែមានគណនេយ្យភាពច្បាស់លាស់ចំពោះក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការអនុវត្តតួនាទី ភារកិច្ចជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌលើការងារអប់រំ។

**បញ្ហាប្រឈម៖**

ក្នុងឆ្នាំដំបូងនៃការធ្វើសមាហរណកម្ម ការិយាល័យអប់រំ យុវជន និងកីឡាបានជួបការលំបាកមួយចំនួនក្នុងការបំពេញការងាររបស់ខ្លួន ដោយសារពុំទាន់បានយល់ដឹងច្បាស់អំពីខ្សែគណនេយ្យភាពថ្មី ទំនាក់

ទំនងការងារ នីតិវិធីគ្រប់គ្រងកិច្ចការរដ្ឋបាល ទម្រង់បែបបទលិខិតស្នាម និងចរន្តឯកសាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌជាដើម។ ក៏ប៉ុន្តែរហូតមកដល់ពេលនេះ បញ្ហាលំបាកទាំងនេះត្រូវបានដោះស្រាយ និងកែលម្អជាបណ្តើរៗពីមួយឆ្នាំទៅមួយឆ្នាំ។

### ខ. ការគ្រប់គ្រងសាលារៀន

**ចំណុចវិជ្ជមាន៖**

បន្ទាប់ពីការផ្ទេរមុខងារអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្ថានភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍនៅតាមសាលារៀនកាន់តែមានភាពល្អប្រសើរឡើង ជាពិសេសនៅតាមសាលារៀនក្នុងក្រុង ស្រុក នៃខេត្តបាត់ដំបងពាក់ព័ន្ធនឹងការផ្តល់សេវាអប់រំ ការអភិវឌ្ឍសាលា ការងារសន្តិសុខសណ្តាប់ធ្នាប់ ការការពារការឆ្លងរាលដាលជំងឺកូវីដ-១៩ ការថែរក្សាអនាម័យ បរិស្ថាន សុវត្ថិភាពចំណីអាហារ ចរាចរណ៍របស់សិស្ស សកម្មភាពអភិវឌ្ឍយុវជន ការអប់រំកាយ និងកីឡាជាដើម ដោយសារថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកមានឆន្ទៈម្ចាស់ការទទួលខុសត្រូវ និងផ្តល់អាទិភាពជាចម្បងក្នុងការផ្តល់អន្តរាគមន៍គាំទ្រ និងដោះស្រាយបញ្ហាប្រឈមនៅតាមសាលារៀនបានឆាប់រហ័ស។ ផ្អែកតាមការស្ទង់មតិក្នុងចំណោមអ្នកពាក់ព័ន្ធចំនួន**៣៧០នាក់**ក្នុងខេត្តបាត់ដំបងបានបង្ហាញឱ្យឃើញថា មានមតិ**៦៩%**យល់ថាស្ថានភាពគ្រប់គ្រងនៅតាមសាលារៀនមានភាពល្អប្រសើរជាងមុន។

**បញ្ហាប្រឈម៖**

ការគ្រប់គ្រង និងការអភិវឌ្ឍតាមសាលារៀននៅមានចំណុចខ្វះខាតមួយចំនួន ដោយសារថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌពុំទាន់ទទួលបានការបណ្តុះបណ្តាលឱ្យមានការយល់ដឹងច្បាស់អំពីតួនាទី ភារកិច្ចជាក់លាក់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារអប់រំ និងអំពីគោលការណ៍ នីតិវិធីសម្រាប់គ្រប់គ្រង និងអភិវឌ្ឍសាលារៀនតាមនិយាមដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌក្រៅពីខេត្តបាត់ដំបង។

### គ.ការគ្រប់គ្រងបុគ្គលិកអប់រំ

**ចំណុចវិជ្ជមាន៖**

ការគ្រប់គ្រងបុគ្គលិកអប់រំដែលបានផ្ទេរមកជាបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌមានស្ថានភាពល្អប្រសើរជាងការគ្រប់គ្រងបុគ្គលិកអប់រំដែលពុំបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ បុគ្គលិកអប់រំបម្រើការងារនៅតាមការិយាល័យអប់រំ យុវជន និងកីឡា និងនៅតាមសាលារៀនក្នុងខេត្តបាត់ដំបងបានបង្ហាញនូវការពេញចិត្តចំពោះការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក រួមទាំងការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការគ្រប់គ្រងវត្តមាន និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលផ្សេងទៀតរបស់បុគ្គលិកដែលបានអនុវត្តប្រកបដោយប្រសិទ្ធភាព តម្លាភាព និងឆាប់រហ័សស្របតាមគោលការណ៍ និងនីតិវិធីគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក។ ការសម្រេចនានាលើការគ្រប់គ្រងបុគ្គលិកត្រូវធ្វើឡើងដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីនីមួយៗបានឆាប់រហ័យ ដោយពុំចាំបាច់រង់ចាំការសម្រេចពីរដ្ឋបាលខេត្ត មន្ទីរ ឬពីក្រសួងអប់រំ យុវជន និងកីឡាដែលត្រូវប្រើពេលវេលាយូរឡើយ។ ប្រការនេះបានពង្រឹង

ប្រសិទ្ធភាព និងតម្លាភាពនៃការគ្រប់គ្រងបុគ្គលិក និងបានផ្តល់ការជឿជាក់មកលើការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌព្រមទាំងជំរុញលើកទឹកចិត្តបុគ្គលិកឱ្យកាន់តែមានឆន្ទៈក្នុងការបំពេញការងាររបស់ខ្លួន។ ផ្អែកតាមការស្ទង់មតិពីអ្នកពាក់ព័ន្ធចំនួន**៣២០នាក់**ក្នុងខេត្តបាត់ដំបងបានបង្ហាញឱ្យឃើញថា មានមតិ**៦៨%**យល់ឃើញថាស្ថានភាពគ្រប់គ្រងបុគ្គលិកអប់រំដែលបានផ្ទេរមករដ្ឋបាលក្រុង ស្រុកមានភាពល្អប្រសើរជាងមុន។

**បញ្ហាប្រឈមៈ**

ការរៀបចំបុគ្គលិកអប់រំនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌមានបញ្ហាប្រឈមមួយចំនួន ដោយសារការខ្វះចំនួនបុគ្គលិក រដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួនបានផ្លាស់ប្តូរបុគ្គលិកអប់រំឱ្យទៅបំពេញការងារនៅតាមការិយាល័យ/អង្គភាពផ្សេង ដែលប្រការទាំងនេះអាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តការងារអប់រំ។ នៅតាមសាលារៀនមួយចំនួនខ្វះចំនួនគ្រូបង្រៀនសម្រាប់ផ្តល់សេវាអប់រំតាមនិយាមដែលបានកំណត់ (បញ្ហាខ្វះគ្រូបង្រៀននេះកើតឡើងតាំងពីមុនពេលនៃការផ្ទេរមុខងារអប់រំ)។

### ឃ. ការប្រើប្រាស់ថវិកាសម្រាប់អនុវត្តមុខងារអប់រំ

**ចំណុចវិជ្ជមានៈ**

ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាគាំទ្រប្រតិបត្តិការនៃការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានដាក់ឱ្យអនុវត្តតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រង ការតាមដាន និងការត្រួតពិនិត្យ។ ការផ្ទេរថវិកាសម្រាប់ដំណើរការរបស់សាលារៀនទៅក្នុងគណនីរបស់សាលារៀននីមួយៗក្នុងខេត្តបាត់ដំបងបានលឿនជាងមុន ដោយសាររដ្ឋបាលក្រុង ស្រុកនីមួយៗបោះផ្សាយអាណត្តិបើកប្រាក់ដើម្បីផ្ទេរថវិកានេះទៅគណនីសាលារៀននីមួយៗក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតែម្តង ហើយការប្រើប្រាស់ថវិកានៅតាមសាលារៀននីមួយៗត្រូវបានកែលម្អពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈការចូលរួមត្រួតពិនិត្យពីគណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធនានា ព្រមទាំងមានការគាំទ្រ តាមដាន ត្រួតពិនិត្យដោយមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡា និងថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក។ ផ្អែកតាមការស្ទង់មតិពីអ្នកពាក់ព័ន្ធ**ចំនួន៣៩០នាក់**ក្នុងខេត្តបាត់ដំបងបានបង្ហាញថា **មានមតិ៦២%** យល់ឃើញថាការប្រើប្រាស់ថវិកាដំណើរការសាលារៀនមានស្ថានភាពល្អប្រសើរជាងមុន។

**បញ្ហាប្រឈមៈ**

ទោះបីការគ្រប់គ្រង និងការប្រើប្រាស់ថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានដាក់ឱ្យអនុវត្តតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ដោយ ក៏ការអនុវត្តជាក់ស្តែងនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗមានស្ថានភាពផ្សេងៗគ្នា ហើយជាទូទៅត្រូវបានរកឃើញថា ការិយាល័យអប់រំ យុវជន និងកីឡាជួបការលំបាកជាច្រើន ដូចជា ការទទួលបានប្រាក់បេសកកម្ម និងឧបករណ៍ សម្ភារៈនានាចំនួនតិចជាងមុន និងយឺតយ៉ាវជាងមុន ដោយសាររដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវអនុវត្តតាមនីតិវិធីលទ្ធកម្មឧបករណ៍សម្ភារៈរួមគ្នា ហើយរដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួន

បានចែករំលែកសម្ភារៈមួយចំនួនទៅឱ្យអង្គភាពផ្សេងទៀតក្រៅពីការិយាល័យអប់រំ យុវជន និងកីឡា។

ជារួម ថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាចំនួនប្រមាណ ៣០លានរៀលក្នុង១ឆ្នាំៗដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវបានរាយការណ៍ថា ពុំបានចំណាយគ្រប់ចំនួនទាំងអស់សម្រាប់គាំទ្រការិយាល័យអប់រំ យុវជន និងកីឡាឡើយ ដោយសារថវិកានេះត្រូវបានដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិការួមរបស់រដ្ឋបាលក្រុង ស្រុក និងពុំបានកំណត់ច្បាស់លាស់ថាជាថវិកាមានភ្ជាប់លក្ខខណ្ឌសម្រាប់រ៉ាប់រងតែទៅលើចំណាយគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាឡើយ អាស្រ័យហេតុនេះរដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួនបានចែករំលែកថវិកានេះសម្រាប់រ៉ាប់រងលើការចំណាយគាំទ្រប្រតិបត្តិការការិយាល័យ ឬអង្គភាពផ្សេងទៀត។

### ង. ការប្រើប្រាស់ទ្រព្យសម្បត្តិ

**ចំណុចវិជ្ជមាន៖**

ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារៈសម្រាប់អនុវត្តមុខងារអប់រំពុំរកឃើញថា ត្រូវបានយកទៅប្រើប្រាស់សម្រាប់សកម្មភាពផ្សេងក្រៅពីការងារអប់រំឡើយ។ លើសពីនេះ រដ្ឋបាលក្រុង ស្រុកមួយចំនួនសហការជាមួយឃុំ សង្កាត់បានកៀរគរធនធាននានាពីសប្បុរសជន មាតាបិតាសិស្ស អង្គការសង្គមស៊ីវិលសម្រាប់ការសាងសង់ ការជួសជុលសាលារៀន ការចាក់ដីបំពេញទីធ្លាសាលារៀន ការជួសជុល និងសាងសង់ផ្លូវទៅសាលារៀន ការទិញឧបករណ៍ សម្ភារៈបន្ថែមសម្រាប់ផ្តល់ឱ្យការិយាល័យអប់រំ យុវជន និងកីឡា និងសាលារៀន ដូចជា កុំព្យូទ័រ តុ កៅអីសិស្ស និងសម្ភារៈផ្សេងទៀតជាដើម។

**បញ្ហាប្រឈម៖**

ទ្រព្យសម្បត្តិដែលត្រូវផ្ទេរភ្ជាប់នឹងមុខងារអប់រំ ពុំទាន់ត្រូវបានផ្ទេរជាផ្លូវការទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឡើយ។ ភាពយឺតយ៉ាវនៃការផ្ទេរទ្រព្យសម្បត្តិទាំងនេះបានធ្វើឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌពុំមានភាពម្ចាស់ការក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនេះប្រកបដោយការទទួលខុសត្រូវបានពេញលេញ។ ទន្ទឹមគ្នានេះ ការិយាល័យអប់រំ យុវជន និងកីឡាមួយចំនួននៅខ្វះឧបករណ៍ និងសម្ភារៈសម្រាប់បំពេញការងារ ដោយសារឧបករណ៍ និងសម្ភារៈមួយចំនួនបានប្រើប្រាស់អស់រយៈពេលយូរឆ្នាំមកហើយ ខូចខាតប្រើប្រាស់លែងកើត ហើយរដ្ឋបាលក្រុង ស្រុកមួយចំនួនពុំមានថវិកាសម្រាប់ទិញឧបករណ៍ថ្មីមកជំនួសឧបករណ៍ដែលប្រើលែងកើតទាំងនោះ។

### ច. ទំនាក់ទំនងការងារ និងគណនេយ្យភាព

ទំនាក់ទំនងការងារ និងគណនេយ្យភាពរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្រូវបានកែលម្អជាបណ្តើរៗទៅតាមការទទួលខុសត្រូវ និងខ្សែគណនេយ្យភាពថ្មីក្នុងការគ្រប់គ្រងការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ចំពោះការធ្វើគណនេយ្យភាពចំពោះប្រជាពលរដ្ឋ បន្ទាប់ពីការផ្ទេរមុខងារអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាពិសេសរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង ក្រុមប្រឹក្សាក្រុង ស្រុកបានចាប់ផ្តើមទទួលខុសត្រូវក្នុងភាពម្ចាស់ការលើការដឹកនាំ និងការគ្រប់គ្រងមុខងារអប់រំ តាមរយៈការលើកយកបញ្ហាអប់រំមក

ពិនិត្យ ពិភាក្សាក្នុងកិច្ចប្រជុំប្រចាំខែរបស់ខ្លួន និងបានចាត់វិធានការគាំទ្រ តាមដានត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា។ ក្នុងវេទិកាសាធារណៈនានា ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកតែងបានចូលរួមផ្សព្វផ្សាយ និងប្រមូលសំណើសំណូមពររបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានអំពីបញ្ហាពាក់ព័ន្ធនឹងសេវាអប់រំ។ ជាទូទៅ សំណើសំណូមពរពាក់ព័ន្ធនឹងការងារអប់រំភាគច្រើនត្រូវបានយកចិត្តទុកដាក់សម្របសម្រួលដោះស្រាយដោយរដ្ឋបាលក្រុង ស្រុកបានឆាប់រហ័សប្រកបដោយការទទួលខុសត្រូវ និងភាពម្ចាស់ការខ្ពស់។ ផ្អែកលើការស្ទង់មតិអំពីក្នុងចំណោមអ្នកពាក់ព័ន្ធ**២៤៦នាក់**ក្នុងខេត្តបាត់ដំបងបង្ហាញឱ្យឃើញថា **មានមតិ៦៨%** យល់ឃើញថា រដ្ឋបាលក្រុង ស្រុកយកចិត្តទុកដាក់ទទួលខុសត្រូវ និងមានគណនេយ្យភាពលើការងារអប់រំបានល្អប្រសើរជាងមុន។ ជារួម ស្ថានភាពនៃទំនាក់ទំនងការងារ និងការធ្វើគណនេយ្យភាពលើការងារអប់រំរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានលើកកម្ពស់ជាបណ្តើរៗដោយពុំមានបញ្ហាប្រឈមគួរឱ្យកត់សម្គាល់ឡើយ។

## III. អំពីការវិភាគ និងវាយតម្លៃ

ផ្អែកតាមរបកគំហើញនានាពីការចុះសិក្សាវាយតម្លៃនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅ ក្រុមការងារបច្ចេកទេសអន្តរក្រសួងអាចឆ្លុះបញ្ចាំង និងវាយតម្លៃតាមទិដ្ឋភាពពាក់ព័ន្ធដូចខាងក្រោម៖

### ក. ការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវ

ការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញក្នុងក្របខណ្ឌនៃការ**ប្រគល់មុខងារអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង** បានជំរុញឱ្យរដ្ឋបាលក្រុង ស្រុកទាំងនោះមានភាពម្ចាស់ការក្នុងការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានប្រគល់ទាំងនេះទទួលបាន**លទ្ធផលល្អប្រសើរជាង**ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ**ក្នុងក្របខណ្ឌនៃការធ្វើប្រតិភូកម្ម**ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនៃរាជធានី ខេត្តផ្សេងទៀត។

### ខ. ការរៀបចំរចនាសម្ព័ន្ធសម្រាប់អនុវត្តមុខងារអប់រំ

ការរៀបចំរចនាសម្ព័ន្ធពេញលេញសម្រាប់អនុវត្តមុខងារអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង (ការធ្វើសមាហរណកម្មទាំងការិយាល័យអប់រំ និងទាំងសាលារៀនមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក) បានធ្វើឱ្យមានយន្តការស្ថាប័ន និងខ្សែគណនេយ្យភាពច្បាស់លាស់រវាងសាលារៀនជាមួយការិយាល័យអប់រំ យុវជន និងកីឡា រវាងការិយាល័យអប់រំ យុវជន និងកីឡាជាមួយរដ្ឋបាលក្រុង ស្រុក និងរវាងរដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរនិងក្រសួងអប់រំ យុវជន និងកីឡា ដែលប្រការនេះបានជំរុញឱ្យការអនុវត្តមុខងារអប់រំ**ដែលបានប្រគល់មកឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងមានភាពងាយស្រួល មានទំនាក់ទំនងការងារល្អ មានឋានានុក្រមច្បាស់លាស់ និងទទួលបានលទ្ធផលល្អប្រសើរជាង**ការអនុវត្តមុខងារអប់រំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌផ្សេងទៀតដែលបានធ្វើសមាហរណកម្មតែការិយាល័យអប់រំមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយរក្សាសាលារៀននៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

### គ. ការផ្ទេរធនធានមនុស្ស

ការគ្រប់គ្រងបុគ្គលិកអប់រំដែលបានផ្ទេរមកក្លាយជាបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក (ករណីក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបង) មានស្ថានភាពល្អប្រសើរជាងការគ្រប់គ្រងបុគ្គលិកអប់រំដែលពុំបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ (ករណីក្រុង ស្រុកក្រៅពីខេត្តបាត់ដំបង)។ ប្រការនេះបានជំរុញលើកទឹកចិត្តឱ្យបុគ្គលិកអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងមានការជឿជាក់លើការដឹកនាំ និងការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក និងកាន់តែមានឆន្ទៈមោះមុតក្នុងការបំពេញការងាររបស់ខ្លួន គ្រូបង្រៀនមកបង្រៀនបានទៀងទាត់ និងគោរពវិន័យក្រមសីលធម៌គ្រូបង្រៀនបានល្អប្រសើរស្របតាមស្តង់ដាកំណត់។

**ឃ. ការផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ**

ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់គាំទ្រកិច្ចដំណើរការសាលារៀនដែលបានផ្ទេរជាកញ្ចប់ថវិកាមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងមានស្ថានភាពកាន់តែល្អប្រសើរ ដោយសារមានការចូលរួមពិនិត្យ ផ្តល់យោបល់ និងតាមដានត្រួតពិនិត្យពីគណៈកម្មការគ្រប់គ្រងសាលា និងអ្នកពាក់ព័ន្ធ ព្រមទាំងមានការគាំទ្រ ការតាមដាន ត្រួតពិនិត្យពីមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡា និងថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក។ ទោះយ៉ាងនេះក្តី ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាគាំទ្រប្រតិបត្តិការរបស់ការិយាល័យអប់រំ យុវជន និងកីឡាដែលបានដាក់ឱ្យអនុវត្តតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបាន និងកំពុងជួបបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលចាំបាច់ត្រូវបន្តដោះស្រាយ។

**ង. ការរៀបចំលិខិតឧបករណ៍សម្រាប់អនុវត្តមុខងារអប់រំ**

ភាពយឺតយ៉ាវនៃការរៀបចំ និងការបណ្តុះបណ្តាលអំពីសេចក្តីណែនាំបច្ចេកទេសស្តីពីនីតិវិធីអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺជាមូលហេតុចម្បងមួយដែលធ្វើឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌជួបការលំបាក ឬពុំទាន់មានការយល់ដឹងច្បាស់លាស់ក្នុងការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យ។ ប្រការនេះចាំបាច់ត្រូវរៀបចំ និងផ្តល់ការបណ្តុះបណ្តាលជាបន្ទាន់ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌអំពីសេចក្តីណែនាំបច្ចេកទេសស្តីពីនីតិវិធីអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ច. ការរៀបចំយន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**

ស្ថានភាពនៃការផ្តល់ការគាំទ្របច្ចេកទេស ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងមានភាពសកម្ម និងមានលក្ខណៈល្អប្រសើរជាងការគាំទ្របច្ចេកទេស និងការតាមដានត្រួតពិនិត្យលើការអនុវត្តមុខងារអប់រំដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្តដទៃទៀត។ ប្រការនេះបានធ្វើឱ្យការអនុវត្តមុខងារអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងទទួលបានលទ្ធផលល្អប្រសើរជាង។

ភាពយឺតយ៉ាវក្នុងការរៀបចំយន្តការគាំទ្រជាក់លាក់ទាំងនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ដោយសារវិបត្តិកូវីដ-១៩ បានធ្វើឱ្យបញ្ហាប្រឈមមួយចំនួនដែលបានជួបប្រទះដោយរដ្ឋបាលក្រុង ស្រុក

ខណ្ឌក្នុងការអនុវត្តមុខងារអប់រំត្រូវបានអូសបន្លាយរហូតមកដល់ពេលនេះ ជាពិសេសបញ្ហាប្រឈមពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាជាដើម។

## IV. អំពីអនុសាសន៍

ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការពង្រីកការប្រគល់មុខងារទាំងនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដទៃទៀត ក្រុមការងារបច្ចេកទេសអន្តរក្រសួងលើកឡើងនូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំបន្ទាន់មួយដើម្បីផ្តល់ការណែនាំ និងជំរុញឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌបន្តផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យកាន់តែមានប្រសិទ្ធភាព
- បន្តជំរុញការរៀបចំបញ្ចប់សេចក្តីណែនាំបច្ចេកទេសស្តីពីគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធអំពីសេចក្តីណែនាំបច្ចេកទេសនេះឱ្យបានឆាប់ក្នុងឆ្នាំ២០២៣នេះ
- ពិនិត្យកែសម្រួលការវិភាជន៍ថវិកាសម្រាប់គាំទ្រប្រតិបត្តិការរបស់ការិយាល័យអប់រំ យុវជន និងកីឡាឱ្យបានសមស្របទៅតាមបន្ទុកការងារ និងស្ថានភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ព្រមទាំងពិនិត្យ និងកែសម្រួលគោលការណ៍ និងនីតិវិធីសម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិកានេះ ជាពិសេសថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡា ដើម្បីធានាឱ្យបានថា ការិយាល័យអប់រំ យុវជន និងកីឡាទទួលបានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់
- បន្តជំរុញការផ្ទេរជាផ្លូវការនូវទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗមានការទទួលខុសត្រូវប្រកបដោយភាពម្ចាស់ការក្នុងការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះប្រកបដោយប្រសិទ្ធភាព
- បន្តការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌអំពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិក ដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានការយល់ដឹងកាន់តែច្បាស់លាស់ និងមានសមត្ថភាពសមស្របក្នុងការរៀបចំ និងការគ្រប់គ្រងបុគ្គលិកអប់រំឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ពង្រឹង និងរៀបចំឱ្យមានយន្តការគាំទ្រច្បាស់លាស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ការអភិវឌ្ឍសមត្ថភាព និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ពង្រីកការប្រគល់មុខងារក្នុងវិស័យអប់រំដូចដែលបានអនុវត្តនៅរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុង

ខេត្តបាត់ដំបងនាពេលបច្ចុប្បន្នទៅអនុវត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។

## V. សេចក្តីសន្និដ្ឋាន

ទោះបីការផ្ទេរមុខងារអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌចំពេលដែលជួបស្ថានភាពលំបាកនៃការឆ្លងរីករាលដាលជំងឺកូវីដ-១៩ក៏ដោយ ក៏ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទាំងនោះពុំមានហានិភ័យធ្ងន់ធ្ងរឡើយ។ ផ្ទុយមកវិញ ស្ថានភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍនៅតាមសាលារៀន ជាពិសេសសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងកាន់តែមានស្ថានភាពល្អប្រសើរឡើង។

ទោះយ៉ាងនេះក្តី ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តផ្តោតការយកចិត្តទុកដាក់ដោះស្រាយ។ បញ្ហាប្រឈមទាំងនោះពាក់ព័ន្ធនឹងភាពពុំទាន់ច្បាស់លាស់នៃសិទ្ធិអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំក្នុងក្របខណ្ឌនៃការធ្វើប្រតិភូកម្ម ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលទាមទារការពិនិត្យ និងការកែសម្រួល រួមជាមួយនឹងការពង្រឹងយន្តការគាំទ្រ ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីជានាឱ្យការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌអាចអនុវត្តបានដោយរលូនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ជាពិសេសជានាបាននូវគុណភាពអប់រំល្អប្រសើរជាលំដាប់។

## ១. សេចក្តីផ្តើម

ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការដ៏មានសារៈសំខាន់ និងចាំបាច់នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាការបង្វិតការធ្វើសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រង ការចាត់ចែង និងការផ្តល់សេវាសាធារណៈឱ្យទៅកៀតជិតនឹងប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស ចំទិសដៅ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅតាមមូលដ្ឋាននីមួយៗប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។ ជាគោលការណ៍ ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្ទេរភ្ជាប់ទៅជាមួយនូវធនធានហិរញ្ញវត្ថុ ធនធានមនុស្ស សិទ្ធិអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានផ្ទេរទាំងនោះ។ ដើម្បីធានាដល់ការសម្រេចបាននូវគោលការណ៍នៃការផ្ទេរមុខងារទាំងនេះចាំបាច់ត្រូវមានការគាំទ្រ និងកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធជាមួយកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេសកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បច្ចុប្បន្ននេះ កំណែទម្រង់រដ្ឋបាលសាធារណៈបាន និងកំពុងផ្តោតទៅលើការពង្រឹងប្រសិទ្ធភាពស្ថាប័ន ការលើកកម្ពស់ប្រសិទ្ធភាពនៃគ្រប់គ្រងធនធានមនុស្សទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅធានាដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសង្គមប្រកបដោយសមធម៌ យុត្តិធម៌ និងបរិយាប័ន្ន ដោយផ្តោតលើការជំរុញនវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានក្នុងរដ្ឋបាលសាធារណៈ និងការជំរុញការដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ការរៀបចំយន្តការគណនេយ្យភាពរបស់ស្ថាប័នសាធារណៈ និងការចូលរួមវាយតម្លៃរបស់ប្រជាជនក្នុងដំណើរការនៃការផ្តល់សេវាសាធារណៈ។ ទន្ទឹមនេះ ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំហានទី៤ "គណនេយ្យភាពសមិទ្ធកម្ម" ប្រព័ន្ធថវិការបស់កម្ពុជាត្រូវបានផ្លាស់ប្តូរក្នុងគោលដៅធ្វើឱ្យការគ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈមានលក្ខណៈកាន់តែល្អប្រសើរ និងស្របតាមគោលដៅជាសារវន្ត ដើម្បីឈានឆ្ពោះទៅអនុវត្ត "ថវិកាព័ត៌មានសមិទ្ធកម្ម" ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្មឆ្នាំ២០២៥។ ក្នុងន័យនេះ ការវិភាជ និងការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំ និងការកែលម្អគោលការណ៍ និងនីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រ៉ាប់រងលើការអនុវត្តមុខងារនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព គឺជាកិច្ចការជាអាទិភាពមួយក្នុងចំណោមកិច្ចការជាអាទិភាពនានានៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ។

វិស័យអប់រំ គឺជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពនានាដែលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានតម្រូវឱ្យមានការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រោមការសម្របសម្រួល និងការគាំទ្របច្ចេកទេសពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ចាប់ពីឆ្នាំ២០១៤មក ក្រសួងអប់រំ យុវជន និងកីឡាបាន

ចាប់ផ្តើមរៀបចំផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលការណ៍ និងដំណើរការដែលបានកំណត់ ក្នុងនោះរួមមាន ការរៀបចំបញ្ជីវិភាគមុខងារ ការពិនិត្យឡើងវិញនូវមុខងារ ការកំណត់មុខងារ និងធនធានដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការកំណត់នូវបែបផែននៃការផ្ទេរមុខងារ និងធនធានទាំងនោះ (ការធ្វើប្រតិភូកម្ម ឬការប្រគល់) ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ នាឆ្នាំ២០១៦ តាមរយៈ គ.ជ.អ.ប. ក្រសួងអប់រំ យុវជន និងកីឡាបានស្នើផ្ទេរមុខងារក្នុងវិស័យអប់រំចំនួន៣ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមាន មុខងារការគ្រប់គ្រងការអប់រំកុមារតូច មុខងារការគ្រប់គ្រងការអប់រំបឋមសិក្សា និងមុខងារការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ។ ផ្អែកតាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវអនុក្រឹត្យលេខ១៩១អនក្រ/បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្រគល់មុខងារការគ្រប់គ្រងការអប់រំកុមារតូច ការគ្រប់គ្រងការអប់រំបឋមសិក្សា និងការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធឱ្យទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងសម្រាប់ការអនុវត្តដំណាក់កាលដំបូងពីឆ្នាំ២០១៦ ដើម្បីបានជាមេរៀន និងបទសោធន៍សម្រាប់ការប្រគល់មុខងារទាំងនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដទៃទៀតជាជំហានៗ។ ទោះយ៉ាងនេះក្តី អនុក្រឹត្យលេខ១៩១នេះមិនត្រូវបានអនុវត្តពេញលេញឡើយ ដោយមានការបារម្ភលើហានិភ័យផ្នែកបច្ចេកទេស និងផ្នែកនយោបាយមួយចំនួនដែលអាចកើតឡើងជាយថាហេតុនាំឱ្យរាំងស្ទះដល់ការអនុវត្តគោលនយោបាយវិមជ្ឈការក្នុងវិស័យអប់រំ ដែលបាន និងកំពុងអនុវត្តនៅតាមសាលារៀនបឋមសិក្សានីមួយៗ។

ទោះយ៉ាងនេះក្តី ផ្អែកតាមការវិវឌ្ឍនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានឈានចូលដល់ដំណាក់កាលកាន់តែស៊ីជម្រៅបានតម្រូវឱ្យធ្វើការពិនិត្យ និងកែសម្រួលឡើងវិញនូវមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ សំដៅរៀបចំឱ្យរដ្ឋបាលទាំងនេះក្លាយជារដ្ឋបាលមូលដ្ឋានស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាពដែលមានសមត្ថភាពសមស្របក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។ ពាក់ព័ន្ធនឹងកិច្ចការនេះ នាចុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវអនុក្រឹត្យចំនួន៣រួមមាន៖ អនុក្រឹត្យលេខ១៨២ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង អនុក្រឹត្យលេខ១៨៣ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ និងអនុក្រឹត្យលេខ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក។ អនុក្រឹត្យទាំងនេះបានតម្រូវឱ្យធ្វើសមាហរណកម្មការិយាល័យជំនាញខ្សែបណ្តោយទាំងអស់របស់ក្រសួង ស្ថាប័ននៅថ្នាក់ក្រុង ស្រុក ខណ្ឌចូលទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងបានផ្ទេរមុខងារចំនួន៥៥មុខងារក្នុងវិស័យចំនួន២០ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនេះផងដែរ។ ក្នុងចំណោមការិយាល័យជំនាញខ្សែបណ្តោយនានា ការិយាល័យអប់រំ យុវជន និងកីឡានៅថ្នាក់ក្រុង ស្រុក ខណ្ឌដែលជាខ្សែបណ្តោយរបស់ក្រសួងអប់រំ យុវជន និងកីឡាក៏ត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌផងដែរ។

ទន្ទឹមនេះ មុខងារក្នុងវិស័យអប់រំចំនួន៦ក៏ត្រូវបានផ្ទេរតាមបែបផែននៃការប្រគល់(វិមជ្ឈការ) និងតាមបែបផែនការធ្វើប្រតិភូកម្ម(វិសហមជ្ឈការ)ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមានដូចខាងក្រោម៖

១.) មុខងារការគ្រប់គ្រងការអប់រំកុមារតូច
២.) មុខងារការគ្រប់គ្រងការអប់រំបឋមសិក្សា
៣.) មុខងារការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ
៤.) មុខងារការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
៥.) ការងារអភិវឌ្ឍយុវជន និង
៦.) ការងារអប់រំកាយ និងកីឡា។

ជារួម ក្នុងការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡា និងការផ្ទេរមុខងារក្នុងវិស័យអប់រំទាំងនេះទៅឱ្យបានរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមាន ការផ្ទេរបុគ្គលិកដែលបំពេញការងារក្នុងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ**ចំនួនប្រមាណ២.៥០០នាក់**ទៅស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស និងការផ្ទេរបុគ្គលិកដែលជាគ្រូបង្រៀន**ចំនួនប្រមាណ៦.៥០០នាក់** ដែលបម្រើការងារនៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំងអស់ក្នុងខេត្តបាត់ដំបងក៏ទៅស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកនីមួយៗទាំង១៤ក្នុងខេត្តបាត់ដំបងផងដែរ។ ទន្ទឹមគ្នានេះ ធនធានហិរញ្ញវត្ថុ រួមមានបៀវត្សរបស់បុគ្គលិកអប់រំ ថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡា និងថវិកាសម្រាប់ដំណើរការគ្រឹះស្ថានបឋមសិក្សា មត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលបានផ្ទេរទៅស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌតាមក្របខណ្ឌនៃដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីនីមួយៗសម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងការអនុវត្តមុខងារដែលបានផ្ទេរឱ្យផងដែរ។

ការផ្ទេរមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដូចបានគូសបញ្ជាក់ខាងលើត្រូវបានអនុវត្តចាប់ពីដើមឆ្នាំ២០២០ ដែលគិតមកដល់ពេលនេះមានរយៈពេលប្រមាណ៣ឆ្នាំហើយ។ អាស្រ័យហេតុនេះ ចាំបាច់ត្រូវមានការសិក្សាវាយតម្លៃមួយដើម្បីពិនិត្យមើលស្ថានភាព និងលទ្ធផលនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

## ២. គោលបំណង

គោលបំណងនៃការសិក្សាវាយតម្លៃនេះ គឺដើម្បីពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈម និងស្ថានភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីជាមូលដ្ឋានសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារទាំងនោះផង និងធ្វើជាមូលដ្ឋានសម្រាប់ពង្រីកការប្រគល់មុខងារទាំងនោះទៅឱ្យដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្តដទៃទៀតក្រៅពីខេត្តបាត់ដំបងផងដែរ។

## ៣. ដែនកំណត់

ការសិក្សាវាយតម្លៃនេះបានផ្តោតតែទៅលើស្ថានភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌប៉ុណ្ណោះ ដោយពុំទាន់បានផ្តោតស៊ីជម្រៅទៅលើគុណភាពនៃសេវាអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឡើយ។

មូលហេតុដែលការសិក្សាវាយតម្លៃនេះពុំទាន់បានផ្តោតលើគុណភាពនៃសេវាអប់រំ គឺ៖

- ការសិក្សាវាយតម្លៃនេះត្រូវរៀបចំដោយមានភាពចាំបាច់ និងបន្ទាន់ដើម្បីជានាដល់ការដោះស្រាយបញ្ហាប្រឈមចំពោះមុខនានា បន្ទាប់ពីស្ថានភាពនៃវិបត្តិកូវីដ-១៩មានភាពធូរស្រាល និងដើម្បីមានមូលដ្ឋានសម្រាប់ការសម្រេចចិត្តផ្នែកនយោបាយក្នុងការពង្រីកការប្រគល់មុខងារក្នុងវិស័យអប់រំនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដទៃទៀតក្រៅពីរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង
- ការវាយតម្លៃគុណភាពសេវាអប់រំពាក់ព័ន្ធនឹងមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវការប្រើប្រាស់ពេលវេលាយូរ និងត្រូវផ្អែកលើទិន្នន័យដើមគ្រា ដែលបច្ចុប្បន្ននេះ ទិន្នន័យដើមគ្រាជាក់លាក់នៅពុំទាន់ត្រូវបានរៀបចំចងក្រងនៅឡើយ
- វិបត្តិកូវីដ-១៩ក្នុងអំឡុងពេលនៃការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ (២០២០-២០២២) គឺជាកត្តាខាងក្រៅដែលបានផ្តល់ផលប៉ះពាល់ជាអវិជ្ជមានដល់គុណភាពសេវាអប់រំជាទូទៅ។ អាស្រ័យហេតុនេះ ការសិក្សាវាយតម្លៃលើគុណភាពសេវាអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌគួររៀបចំក្នុងរយៈពេល២ ឬ៣ឆ្នាំក្រោយពីមានភាពធូរស្រាលនៃការរីករាលដាលនៃវិបត្តិជំងឺកូវីដ-១៩។

## ៤. យន្តការដឹកនាំសម្របសម្រួលការសិក្សាវាយតម្លៃ

ការសិក្សាវាយតម្លៃនេះបានរៀបចំដោយអនុលោមតាមគោលការណ៍ណែនាំតម្រង់ទិសរបស់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** តាមរយៈការដាក់ចេញនូវឯកសារទស្សនទានស្តីពីការសិក្សាវាយតម្លៃលើការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសេចក្តីសម្រេចលេខ០៣១ស.ស.រ./គ.ជ.អ.ប. ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់សិក្សាវាយតម្លៃលើការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះមាននៅក្នុងឧបសម្ព័ន្ធទី១នៃរបាយការណ៍នេះ។

ឯកសារទស្សនទានស្តីពីការសិក្សាវាយតម្លៃលើការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺជាផែនទីបង្ហាញផ្លូវសម្រាប់រៀបចំ និងអនុវត្តកិច្ចដំណើរការសិក្សាវាយតម្លៃនេះឱ្យមានប្រសិទ្ធភាព តម្លាភាព មិនលម្អៀង និងដោយមានការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធនានា។

ក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះ គឺជាយន្តការដឹកនាំសម្របសម្រួលកិច្ចដំណើរការសិក្សាវាយតម្លៃលើការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយមានសមាជិកសរុបចំនួន **៣២នាក់**ដែលមានសមាសភាពមកពីលេខាធិការដ្ឋានគ.ជ.អ.ប. ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ ការសិក្សាវាយតម្លៃនេះមានការគាំទ្របច្ចេកទេសពីកម្មវិធី "ធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាជូនប្រជាពលរដ្ឋនៅកម្ពុជា(ISD/GIZ)" គាំទ្រហិរញ្ញប្បទានពីរដ្ឋាភិបាលអាឡឺម៉ង់ និងរដ្ឋាភិបាលស្វីស។

## ៥. វិធីសាស្ត្រ

វិធីសាស្ត្រសំខាន់ៗដែលបានអនុវត្តក្នុងកិច្ចដំណើរការសិក្សាវាយតម្លៃនេះ រួមមាន៖

- **ការសិក្សាលើលិខិតបទដ្ឋានគតិយុត្ត៖** ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានសិក្សាលើលិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងការផ្ទេរមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីកំណត់ទិដ្ឋភាព និងលក្ខខណ្ឌចាំបាច់នានាសម្រាប់ជាមូលដ្ឋានក្នុងការពិនិត្យវាស់វែង ការវាយតម្លៃ និងការវិភាគស្ថានភាពលើការអនុវត្តជាក់ស្តែងនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗ។ លិខិតបទដ្ឋានគតិយុត្តសំខាន់ៗដែលក្រុមការងារអន្តរក្រសួងបានសិក្សារួមមាន អនុក្រឹត្យលេខ១៨២ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង អនុក្រឹត្យ លេខ១៨៣ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ និងអនុក្រឹត្យលេខ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក និងបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាល ការងារហិរញ្ញវត្ថុ និងការងារបុគ្គលិកអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងរបាយការណ៍សិក្សាវាយតម្លៃពាក់ព័ន្ធនានា។
- **ការប្រមូលព័ត៌មាន៖** ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានចុះទៅតាមរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុកគោលដៅដើម្បីប្រមូលព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រង ការចាត់ចែង ការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់ជាមូលដ្ឋានក្នុងការវិភាគ ថ្លឹងថ្លែង និងវាយតម្លៃដោយប្រៀបធៀបទៅនឹងគោលបំណង និងលក្ខខណ្ឌតម្រូវនានាដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ក្នុងការប្រមូលព័ត៌មាននេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានរៀបចំ និងប្រើប្រាស់បញ្ជីសំណួរពីរប្រភេទផ្សេងគ្នាគឺ

  ១. បញ្ជីសំណួរសម្រាប់ស្ទង់មតិយោបល់ និងការយល់ឃើញជាលក្ខណៈបុគ្គល

  ២. បញ្ជីសំណួរសម្រាប់ការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានា

បញ្ជីសំណួរដែលបានរៀបចំ និងប្រើប្រាស់សម្រាប់ប្រមូលព័ត៌មានក្នុងការសិក្សាវាយតម្លៃនេះមានក្នុងឧបសម្ព័ន្ធទី២នៃរបាយការណ៍នេះ។

- **រដ្ឋបាលក្រុង ស្រុកគោលដៅ៖** ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានកំណត់យករដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅសរុបចំនួន**១៧**ក្នុងរាជធានីភ្នំពេញ ខេត្តចំនួន៤សម្រាប់សិក្សាវាយតម្លៃ។ ការជ្រើសរើសរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅទាំងនេះបានផ្តោតលើលក្ខណៈវិនិច្ឆ័យមួយចំនួនដូចជា៖
  - រដ្ឋបាលក្រុង ស្រុកដែលកំពុងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ឱ្យ
  - រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្តដែលបាន និងកំពុងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានធ្វើប្រតិភូកម្មឱ្យ
  - រដ្ឋបាលស្រុកស្ថិតនៅក្នុងតំបន់ទីប្រជុំជន និងរដ្ឋបាលស្រុកស្ថិតក្នុងតំបន់ជនបទ។

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅដែលក្រុមការងារបច្ចេកទេសអន្តរ

ក្រសួងបានកំណត់ និងបានចុះទៅសិក្សាវាយតម្លៃមានក្នុងឧបសម្ព័ន្ធទី៣នៃរបាយការណ៍នេះ។

- **ក្រុមអ្នកផ្តល់ព័ត៌មាន៖** ដើម្បីជានាដល់ការប្រមូលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យបានគ្រប់ជ្រុងជ្រោយ ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានកំណត់ និងបានចុះជួបពិភាក្សាដោយផ្ទាល់ជាមួយក្រុមអ្នកផ្តល់ព័ត៌មានចំនួន៥ក្រុមផ្សេងៗគ្នានៅតាមរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុកគោលដៅនីមួយៗ។ អ្នកផ្តល់ព័ត៌មានដែលក្រុមការងារបានជួបពិភាក្សាសរុបចំនួនប្រមាណជាង៧០០នាក់ និងមានសមាសភាពជាមន្ត្រីថ្នាក់ដឹកនាំនៃរដ្ឋបាលខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធ មន្ត្រីថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ថ្នាក់ដឹកនាំការិយាល័យពាក់ព័ន្ធ ថ្នាក់ដឹកនាំ និងមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលាបឋមសិក្សា នាយកសាលាមត្តេយ្យ គ្រូបង្រៀនសាលាបឋមសិក្សា និងសាលាមត្តេយ្យ មេឃុំ ចៅសង្កាត់ តំណាងគណៈកម្មាធិការគ្រប់គ្រងសាលារៀន និងតំណាងមាតាបិតាសិស្ស។ បញ្ជីក្រុមអ្នកផ្តល់ព័ត៌មានមានក្នុងឧបសម្ព័ន្ធទី៤នៃរបាយការណ៍នេះ។
- **ការវិភាគ៖** ព័ត៌មានដែលប្រមូលបានពីក្រុមអ្នកផ្តល់ព័ត៌មានត្រូវបានកត់ត្រា ចងក្រង និងបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ និងត្រូវបានវិភាគ ដោយប្រៀបធៀបទៅតាមទិដ្ឋភាព និងលក្ខខណ្ឌនានាដែលកំណត់ក្នុងក្របខណ្ឌគតិយុត្ត ដើម្បីវាយតម្លៃឱ្យបានត្រឹមត្រូវនូវស្ថានភាពជាក់ស្តែងនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងកំណត់បាននូវចំណុចវិជ្ជមាន ចំណុចអវិជ្ជមាន និងបញ្ហាប្រឈមនានាដែលត្រូវបន្តដោះស្រាយ និងលើកអនុសាសន៍សម្រាប់ពង្រីកការប្រគល់មុខងារទាំងនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដទៃទៀតក្រៅពីរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង។
- **ការរៀបចំរបាយការណ៍៖** ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ខ្លួនដើម្បីរៀបចំសេចក្តីព្រាងបឋមនៃរបាយការណ៍ស្តីពីលទ្ធភាពនៃការសិក្សាវាយតម្លៃ។ បន្ទាប់ពីការរៀបចំសេចក្តីព្រាងបឋមនៃរបាយការណ៍នេះ ក្រុមការងារអន្តរក្រសួងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងកិច្ចប្រជុំអនុគណៈកម្មាធិការមុខងារ និងធនធាននៃគ.ជ.អ.ប.ដើម្បីពិនិត្យ ពិភាក្សាទៅលើចំណុចសំខាន់ៗដែលក្រុមការងារបច្ចេកទេសអន្តរក្រសួងបានរកឃើញ និងប្រមូលធាតុចូលបន្ថែមពីអ្នកពាក់ព័ន្ធនានាសម្រាប់រៀបចំរបាយការណ៍បូកសរុបចុងក្រោយ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនកិច្ចប្រជុំកទី២១ របស់ គ.ជ.អ.ប. ពិនិត្យ និងសម្រេចនាថ្ងៃទី២ ខែឧសភា ឆ្នាំ ២០២៣។
- **ពេលវេលា និងសកម្មភាព៖** ការសិក្សាវាយតម្លៃនេះត្រូវបានអនុវត្តចាប់ពីខែតុលា ឆ្នាំ២០២២ រហូតដល់ខែមេសា ឆ្នាំ២០២៣ តាមកម្មវិធីដូចមានក្នុងឧបសម្ព័ន្ធទី៥នៃរបាយការណ៍នេះ។

## ៦. ការសិក្សាលើក្របខណ្ឌគតិយុត្ត និងលក្ខខណ្ឌសំខាន់ៗ

### ៦.១. ការសិក្សាលើក្របខណ្ឌគតិយុត្ត

មូលដ្ឋានគតិយុត្តសំខាន់ៗដែលពាក់ព័ន្ធនឹងការផ្ទេរមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌរួមមាន៖

- អនុក្រឹត្យលេខ១៨២ អ.ន.ក្រ.ប.ក. ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- អនុក្រឹត្យលេខ១៨៣ អ.ន.ក្រ.ប.ក. ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ
- អនុក្រឹត្យលេខ១៨៤ អ.ន.ក្រ.ប.ក. ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក។
- អនុក្រឹត្យលេខ២០៦ អ.ន.ក្រ.ប.ក. ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ប្រកាសអន្តរក្រសួងលេខ៥២១ សហវ ប្រ.ក. ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ផ្ទេរធនធានមានភ្ជាប់លក្ខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- សារាចរណែនាំ ចុះថ្ងៃទី១៦ ខែកុម្ភៈ ស្តីពីនីតិវិធីអនុវត្តថវិកា បញ្ជិកាគណនេយ្យ និងចលនាឥណទានថវិកានៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- សេចក្តីសម្រេចរបស់ គ.ជ.អ.ប. ស្តីពីការធ្វើសមាហរណកម្មបុគ្គលិក និងការរៀបចំមុខតំណែងគ្រប់គ្រងនៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។
- សេចក្តីណែនាំពាក់ព័ន្ធនានាសម្រាប់ការអនុវត្តក្នុងដំណាក់កាលអន្តរការណ៍ជាដើម
- របាយការណ៍ស្តីពីលទ្ធផលនៃសិក្ខាសាលាឆ្លុះបញ្ចាំងលើការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបង (រៀបចំដោយកម្មវិធី DAR/GIZ ខែមីនា ឆ្នាំ២០២២)
- របាយការណ៍ស្តីពីលទ្ធផលនៃការចុះពិនិត្យស្រាវជ្រាវអំពីការផ្ទេរមុខងារការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបង (រដ្ឋបាលខេត្តបាត់ដំបង ខែតុលា ឆ្នាំ២០២២)

### ៦.២.លក្ខខណ្ឌសំខាន់ៗ

ផ្អែកតាមស្មារតីនៃអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ មុខងារក្នុងវិស័យអប់រំចំនួន៦ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទៅតាមលក្ខខណ្ឌ២ផ្សេងគ្នាគឺ

- លក្ខខណ្ឌនៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង
- លក្ខខណ្ឌនៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរដ្ឋបាលរាជធានី ខេត្តផ្សេង

ទៀតក្រៅពីខេត្តបាត់ដំបង

## គ. លក្ខណៈនៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង

### គ.១. ការផ្ទេរមុខងារ

អនុក្រឹត្យលេខ១៨២ និងលេខ១៨៤ បានផ្ទេរមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង ១៤ក្នុងខេត្តបាត់ដំបងតាមរយៈបែបផែន២យ៉ាង៖

- **តាមរយៈការប្រគល់** រួមមានមុខងារចំនួន៣ គឺ ១).មុខងារការគ្រប់គ្រងការអប់រំកុមារតូច ២).មុខងារការគ្រប់គ្រងការអប់រំបឋមសិក្សា និង ៣).មុខងារការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ។ ក្នុងមុខងារ៣ដែលបានប្រគល់នេះ រួមមានមុខងាររងចំនួន៤៣ និងសកម្មភាពចំនួន២១៤។ ក្នុងក្របខណ្ឌនៃការប្រគល់មុខងារទាំងនេះ រដ្ឋបាលក្រុង ស្រុកត្រូវបានផ្តល់សិទ្ធិអំណាច ការទទួលខុសត្រូវក្នុងភាពជាម្ចាស់ពេញលេញលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានប្រគល់ទាំងនោះស្របតាមគោលការណ៍ និងស្តង់ដាកំណត់ជាធរមាន។ រដ្ឋបាលក្រុង ស្រុកត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនលើលទ្ធផល និងផលប៉ះពាល់ដែលកើតចេញពីការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានប្រគល់ទាំងនោះ និងត្រូវមានគណនេយ្យភាពជាមួយក្រសួង/មន្ទីរអប់រំ យុវជន និងកីឡាក្នុងការអនុវត្តមុខងារដែលបានប្រគល់ទាំងនោះ តាមគោលការណ៍ និងស្តង់ដាដែលបានកំណត់។
- **តាមរយៈការធ្វើប្រតិភូកម្ម** រួមមានមុខងារចំនួន៣គឺ១).មុខងារផ្តល់ការគាំទ្រផ្នែករដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ ២).មុខងារការអភិវឌ្ឍយុវជន និង ៣).មុខងារអប់រំកាយ និងកីឡា។ ក្នុងមុខងារ៣ដែលបានធ្វើប្រតិភូកម្មនេះមានមុខងាររងចំនួន៥និងសកម្មភាពចំនួន ៤៨។ ក្នុងក្របខណ្ឌនៃការធ្វើប្រតិភូកម្ម រដ្ឋបាលក្រុង ស្រុកត្រូវបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវលើការជួយជំរុញ សម្របសម្រួល ត្រួតពិនិត្យ ការផ្តល់យោបល់ ការលើកសំណើ និងការសម្រេចលើកិច្ចការមួយចំនួន ដូចជាការសម្រេចលើការផ្លាស់ប្តូរគ្រូនៅក្នុងក្រុង ស្រុក ការសម្រេចលើការអនុញ្ញាតច្បាប់ឈប់សម្រាករបស់គ្រូ និងការសម្រេចជ្រើសរើសគ្រូកិច្ចសន្យាជាដើម។ រដ្ឋបាលក្រុង ស្រុកត្រូវមានគណនេយ្យភាពជាមួយក្រសួង/មន្ទីរអប់រំ យុវជន និងកីឡាក្នុងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មទាំងនោះតាមគោលការណ៍ និងស្តង់ដាដែលបានកំណត់។ ទោះយ៉ាងនេះក្តី រដ្ឋបាលក្រុង ស្រុកពុំត្រូវបានផ្តល់សិទ្ធិ អំណាច និងការទទួលខុសត្រូវក្នុងភាពម្ចាស់ការ និងគណនេយ្យភាពពេញលេញចំពោះប្រជាពលរដ្ឋលើលទ្ធផល និងផលប៉ះពាល់ដែលកើតចេញពីការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មទាំងនេះឡើយ។

### គ.២. ការផ្ទេរអង្គភាពខ្សែបណ្តោយរបស់ក្រសួងអប់រំ យុវជន និងកីឡានៅថ្នាក់ក្រុង ស្រុក

ការិយាល័យអប់រំ យុវជន និងកីឡាដែលជាអង្គភាពខ្សែបណ្តោយរបស់ក្រសួងអប់រំ យុវជន និងកីឡានៅថ្នាក់ក្រុង ស្រុកត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបង និងត្រូវមានតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រង

ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។

ជាមួយគ្នានេះ គ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំងអស់របស់ក្រសួងអប់រំ យុវជន និងកីឡាដែលមាននៅថ្នាក់ក្រុង ស្រុកក្នុងខេត្តបាត់ដំបងក៏ត្រូវបានធ្វើសមាហរណកម្មមកស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង។ គ្រឹះស្ថានសិក្សាសាធារណៈដែលបានធ្វើសមាហរណកម្មមកក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងរួមមាន គ្រឹះស្ថានបឋមសិក្សាសាធារណៈចំនួន៦៥២ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈចំនួន៣៨៥ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន៤កម្មវិធី។

### ក.៣. ការផ្ទេរបុគ្គលិកអប់រំ

តាមរយៈការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡា គ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំងនេះមកក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក បុគ្គលិកទាំងអស់ដែលបម្រើការងារនៅក្នុងអង្គភាពទាំងនេះ រួមមានបុគ្គលិកបម្រើការងារក្នុងការិយាល័យអបរំ យុវជន និងកីឡា និងគ្រូបង្រៀនបម្រើការងារនៅតាមសាលារៀន ក៏ត្រូវបានផ្ទេរឱ្យក្លាយទៅជាបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុកនីមួយៗក្នុងខេត្តបាត់ដំបង ហើយការគ្រប់គ្រងបុគ្គលិកអប់រំដែលបានផ្ទេរមកទាំងនោះត្រូវអនុវត្តតាមលក្ខន្តិកដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំនួនបុគ្គលិកអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងមានក្នុងឧបសម្ព័ន្ធទី៦នៃរបាយការណ៍នេះ។

### ក.៤. ការផ្ទេរធនធានហិរញ្ញវត្ថុ

#### ថវិកាសម្រាប់ដំណើរការសាលារៀន

យោងតាមប្រកាសអន្តរក្រសួងលេខ៥២១ ថវិកាសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំចំនួន៣ដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបង រួមមានថវិកាសម្រាប់ដំណើរការសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងលក្ខខណ្ឌជា**កញ្ចប់ថវិកាមានភ្ជាប់លក្ខខណ្ឌ**។ ក្នុងន័យនេះ រដ្ឋបាលក្រុង ស្រុកត្រូវធានាដល់ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាមានភ្ជាប់លក្ខខណ្ឌនេះសម្រាប់អនុវត្តសកម្មភាពដែលបម្រើដល់ការអនុវត្តមុខងារក្នុងវិស័យអប់រំ ដែលបានប្រគល់ឱ្យតែប៉ុណ្ណោះ ដោយពុំមានសិទ្ធិប្រើប្រាស់ថវិកានេះសម្រាប់សកម្មភាពផ្សេងទៀតក្រៅពីនេះឡើយ។ ថវិកាសម្រាប់ដំណើរការគ្រឹះស្ថានបឋមសិក្សា គ្រឹះស្ថានមត្តេយ្យសិក្សា និងសកម្មភាពអប់រំក្រៅប្រព័ន្ធដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងក្នុងរយៈពេល៣ឆ្នាំ (២០២០-២០២២)មាននៅក្នុងឧបសម្ព័ន្ធទី៧នៃរបាយការណ៍នេះ។

#### ថវិកាសម្រាប់ប្រតិបត្តិការរបស់ការិយាល័យអប់រំ

ថវិកាសម្រាប់គាំទ្រប្រតិបត្តិការរបស់ការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានវិភាជ និងផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗចំនួនប្រមាណ៣០លានរៀលក្នុងមួយឆ្នាំៗ ដើម្បីជានាឱ្យការិយាល័យអប់រំ យុវជន និងកីឡាមានធនធានសម្រាប់អនុវត្តតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានប្រគល់ និងធ្វើប្រតិភូកម្មឱ្យ។ ទោះយ៉ាងនេះក្តី ថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡានេះពុំត្រូវបានកំណត់លក្ខខណ្ឌជាក់លាក់សម្រាប់ការប្រើប្រាស់ឡើយ។

### ក.៩. ការផ្ទេរទ្រព្យសម្បត្តិ

យោងតាមស្មារតីនៃអនុក្រឹត្យលេខ១៨២ និងលេខ១៨៤ បានតម្រូវឱ្យមានការផ្ទេរទ្រព្យសម្បត្តិដែលបម្រើឱ្យការអនុវត្តមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុកសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរ។

## ខ. លក្ខខណ្ឌផ្ទេរមុខងារអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្តផ្សេងទៀត

### ខ.១. ការផ្ទេរមុខងារ

ផ្អែកតាមស្មារតីនៃអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ មុខងារក្នុងវិស័យអប់រំទាំង៦ត្រូវបានផ្ទេរតាមបែបផែននៃការធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់ក្រៅពីរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង។ មុខងារដែលបានធ្វើប្រតិភូកម្មទាំងនោះរួមមាន ១).មុខងារការគ្រប់គ្រងការអប់រំកុមារតូច ២).មុខងារការគ្រប់គ្រងការអប់រំបឋមសិក្សា ៣).មុខងារការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ៤).មុខងារផ្តល់ការគាំទ្រផ្នែករដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ ៥).មុខងារការអភិវឌ្ឍយុវជន និង៦).មុខងារអប់រំកាយ និងកីឡា។ មុខងារក្នុងវិស័យអប់រំទាំង៦ដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនេះរួមមាន មុខងាររងចំនួន៤៦ និងសកម្មភាពចំនួន១៧៣។

ក្នុងក្របខណ្ឌនៃការធ្វើប្រតិភូកម្មមុខងារទាំងនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវលើការជួយជំរុញ ការសម្របសម្រួល ការត្រួតពិនិត្យ ការផ្តល់យោបល់ ការលើកសំណើ និងការសម្រេចលើកិច្ចការមួយចំនួន ដូចជាការសម្រេចលើការផ្លាស់ប្តូរគ្រូនៅក្នុងក្រុង ស្រុក ការសម្រេចលើការអនុញ្ញាតច្បាប់ឈប់សម្រាករបស់គ្រូ និងការសម្រេចជ្រើសរើសគ្រូកិច្ចសន្យាជាដើម។ រដ្ឋបាលក្រុង ស្រុកត្រូវមានគណនេយ្យភាពជាមួយក្រសួង/មន្ទីរអប់រំ យុវជន និងកីឡាក្នុងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មទាំងនោះតាមគោលការណ៍ និងស្តង់ដាដែលបានកំណត់។ ទោះយ៉ាងនេះក្តី រដ្ឋបាលក្រុង ស្រុកពុំត្រូវបានផ្តល់សិទ្ធិ អំណាច និងការទទួលខុសត្រូវក្នុងភាពម្ចាស់ការ និងគណនេយ្យភាពពេញលេញចំពោះប្រជាពលរដ្ឋលើលទ្ធផល និងផលប៉ះពាល់ដែលកើតចេញពីការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មទាំងនេះឡើយ។

### ខ.២. ការផ្ទេរអង្គភាពខ្សែបណ្តោយរបស់ក្រសួងអប់រំ យុវជន និងកីឡានៅថ្នាក់ក្រុង ស្រុក ខណ្ឌ

ការិយាល័យអប់រំ យុវជន និងកីឡាដែលជាអង្គភាពខ្សែបណ្តោយរបស់ក្រសួងអប់រំ យុវជន និងកីឡានៅថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង

ស្រុក ខណ្ឌ និងត្រូវមានតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។

ដោយឡែក ចំពោះគ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និង និងមជ្ឈមណ្ឌលសិក្សាសហគមន៍នៃក្រសួងអប់រំ យុវជន និងកីឡា**ពុំត្រូវបាន**ធ្វើសមាហរណកម្មមកស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌឡើយ ដោយរក្សាឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តដដែល។

### ខ.៣. ការផ្ទេរបុគ្គលិកអប់រំ

តាមរយៈការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡា បុគ្គលិកដែលបម្រើការងារក្នុងការិយាល័យអបរំ យុវជន និងកីឡាត្រូវបានផ្ទេរឱ្យក្លាយទៅជាបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ហើយការគ្រប់គ្រងបុគ្គលិកអប់រំដែលបានផ្ទេរមកទាំងនោះត្រូវអនុវត្តតាមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

ដោយឡែក បុគ្គលិកអប់រំ និងគ្រូបង្រៀនដែលបម្រើការងារនៅតាមគ្រឹះស្ថានសិក្សានានាពុំត្រូវបានផ្ទេរមកក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌឡើយ គឺនៅរក្សាស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡាដដែល។

### ខ.៤. ការផ្ទេរធនធានហិរញ្ញវត្ថុ

#### ថវិកាសម្រាប់ប្រតិបត្តិការរបស់សាលារៀន

ក្នុងក្របខណ្ឌនៃការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យអប់រំទាំង៦ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនេះ ថវិកាប្រតិបត្តិការសាលាបឋមសិក្សា សាលាមធ្យមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍**ពុំត្រូវបាន**ផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឡើយ គឺត្រូវរក្សាទុកក្នុងកញ្ចប់ថវិការបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តដដែល។

#### ថវិកាសម្រាប់ប្រតិបត្តិការរបស់ការិយាល័យអប់រំ

ថវិកាសម្រាប់គាំទ្រប្រតិបត្តិការរបស់ការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានវិភាជ និងផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗចំនួន៣០លានរៀលក្នុងមួយឆ្នាំៗ ដើម្បីធានាឱ្យការិយាល័យអប់រំ យុវជន និងកីឡាមានធនធានសម្រាប់អនុវត្តតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មឱ្យ។ ទោះយ៉ាងនេះក្តី ថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡានេះពុំត្រូវបានកំណត់លក្ខខណ្ឌជាក់លាក់សម្រាប់ការប្រើប្រាស់ឡើយ។

### ខ.៥. ការផ្ទេរទ្រព្យសម្បត្តិ

យោងតាមស្មារតីនៃអនុក្រឹត្យលេខ១៨២ លេខ១៨៤ និងលេខ១៨៤ បានតម្រូវឱ្យមានការផ្ទេរទ្រព្យសម្បត្តិមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានប្រគល់ឱ្យ។

## ៧. របកគំហើញសំខាន់ៗ៖

### ៧.១. ចំណុចសំខាន់ៗនៃការសិក្សាវាយតម្លៃ

ក្នុងការសិក្សាវាយតម្លៃនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានផ្តោតទៅលើការប្រមូលព័ត៌មានសម្រាប់វាយតម្លៃលើស្ថានភាពប្រែប្រួលជាវិជ្ជមាន អវិជ្ជមាន និងបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពសំខាន់ៗមួយចំនួន បន្ទាប់ពីការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក។ សកម្មភាពសំខាន់ៗដែលក្រុមការងារបច្ចេកទេសអន្តរក្រសួងផ្តោតលើការសិក្សា វាយតម្លៃនេះ រួមមានដូចខាងក្រោម៖

- **ការគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡា៖** ផ្តោតទៅលើស្ថានភាពប្រែប្រួលជាវិជ្ជមាន អវិជ្ជមាន និងបញ្ហាប្រឈមពាក់ព័ន្ធនឹងទំនាក់ទំនងការងាររវាងការិយាល័យអប់រំ យុវជន និងកីឡាជាមួយក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល ការិយាល័យ អង្គភាពពាក់ព័ន្ធនានាក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក និងស្ថានភាពនៃការអនុវត្តការងារតាមគោលការណ៍ បែបបទ និងនីតិវិធីគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ដោយការិយាល័យអប់រំ យុវជន និងកីឡាក្នុងការបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុកលើការអនុវត្តមុខងារក្នុងវិស័យអប់រំ រួមមានដូចជា ការអនុវត្តតាមបែបបទ នីតិវិធីរដ្ឋបាលការងាររបៀប ការប្រើប្រាស់ត្រា របបប្រជុំ ការរៀបចំទីកន្លែងបំពេញការងារជាដើម បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក។
- **ការគ្រប់គ្រងនៅតាមសាលារៀន៖** សំដៅទៅលើស្ថានភាពប្រែប្រួលជាវិជ្ជមាន អវិជ្ជមាន និងបញ្ហាប្រឈមពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ការពារជំងឺឆ្លងកូវីដ-១៩ ការរក្សាអនាម័យ បរិស្ថាន សុវត្ថិភាពចំណីអាហារ ការធ្វើដំណើររបស់សិស្សានុសិស្ស សកម្មភាពនៃការអភិវឌ្ឍយុវជន ការអប់រំកាយ និងកីឡានៅតាមសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗ បន្ទាប់ពីមុខងារក្នុងវិស័យអប់រំទាំងនេះត្រូវបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក។
- **ការគ្រប់គ្រងបុគ្គលិកអប់រំ៖** ផ្តោតទៅលើស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំ ដែលបានផ្ទេរមកជាបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុកស្របតាមគោលការណ៍ បែបបទ នីតិវិធីដែលបានកំណត់ រួមមានដូចជា ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការផ្លាស់ប្តូរ ការដាក់ឱ្យចូលនិវត្តន៍ ការគ្រប់គ្រងវត្តមានបុគ្គលិក ដោយប្រៀបធៀបទៅនឹងស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំមុនពេលផ្ទេរបុគ្គលិកទាំងនោះមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក។
- **ការគ្រប់គ្រង និងការប្រើប្រាស់ថវិកា៖** សំដៅវាយតម្លៃលើប្រសិទ្ធភាព តម្លាភាព ស្វ័យភាព គណនេយ្យភាពនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ប្រៀបធៀបទៅនឹងប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាមុនពេលផ្ទេរថវិកាទាំង

នេះមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក។ ការប្រមូលព័ត៌មានសម្រាប់វាយតម្លៃលើស្ថានភាពប្រែប្រួលនៃការគ្រប់គ្រងថវិកានេះ បានដោយផ្តោតលើទិដ្ឋភាព២ផ្សេងគ្នា គឺៈ

– ការគ្រប់គ្រងថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡា

– ការគ្រប់គ្រងថវិកាដំណើរការសាលារៀន។

- **ការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិៈ** សំដៅវាយតម្លៃលើប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រង ការចាត់ចែង ការថែរក្សាទុកដាក់ និងការប្រើប្រាស់ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារៈនានាសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ប្រៀបធៀបទៅនឹងស្ថានភាពមុនពេលផ្ទេរមុខងារក្នុងវិស័យអប់រំទាំងនោះមកឱ្យរដ្ឋបាលក្រុង ស្រុក។
- **ទំនាក់ទំនងការងារ និងគណនេយ្យភាពៈ** សំដៅទៅលើការវាយតម្លៃស្ថានភាពនៃទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកជាមួយក្រសួង/មន្ទីរអប់រំ យុវជន និងកីឡាខេត្តលើការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យតាមគោលការណ៍ នីតិវិធី និងស្តង់ដាដែលបានកំណត់ និងគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកចំពោះប្រជាពលរដ្ឋ រួមមានដូចជាការពិគ្រោះយោបល់ ការដោះស្រាយបញ្ហាប្រឈម ការឆ្លើយតបទៅនឹងសំណើសំណូមពររបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យ ដោយប្រៀបធៀបទៅនឹងស្ថានភាពមុនពេលផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក។

ការរកឃើញសំខាន់ៗរបស់ក្រុមការងារបច្ចេកទេសអន្តរក្រសួងក្នុងពេលចុះទៅសិក្សាតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅ រួមមានសង្ខេបដូចខាងក្រោមៈ

## ៧.២.លទ្ធផលនៃការរកឃើញនៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង

### ៧.២.១. ការគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡា

ផ្អែកតាមព័ត៌មានដែលទទួលបានពីការស្ទង់មតិយោបល់ និងការយល់ឃើញអំពីកម្រិតនៃភាពពេញចិត្តចំពោះការធ្វើសមាហរណកម្មការិយាល័យអបរំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ធ្វើជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុកបានបង្ហាញឱ្យឃើញថា ក្នុងចំណោមអ្នកពាក់ព័ន្ធចំនួន១៦៦នាក់ដែលជាមន្ត្រីថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក និងមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡា មានមតិចំនួន៥៣% យល់ថាមានភាព



ពេញចិត្តខ្លាំង មតិចំនួន៤៥% យល់ថាមានការពេញចិត្តធម្មតា និងមតិចំនួន២% យល់ថាពុំពេញចិត្ត។

ផ្អែកតាមព័ត៌មានដែលទទួលបានពីការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុកបានបង្ហាញឱ្យឃើញនូវចំណុចវិជ្ជមាន អវិជ្ជមាន និងបញ្ហាប្រឈមនៃការគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡាដូចខាងក្រោម៖

**ចំណុចវិជ្ជមាន៖**

- ក្រុមអ្នកផ្តល់ព័ត៌មានភាគច្រើនបានលើកឡើងថា បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុកបានធ្វើឱ្យរដ្ឋបាលក្រុង ស្រុក ទាំងក្រុមប្រឹក្សា និងគណៈអភិបាលមានការទទួលខុសត្រូវកាន់តែច្បាស់លាស់ និងមានភាពងាយស្រួលក្នុងការដឹកនាំ គ្រប់គ្រង ពិភាក្សា ពិគ្រោះយោបល់ និងទំនាក់ទំនងការងារកាន់តែជិតស្និទ្ធជាមួយមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា។ ប្រការនេះបានផ្តល់លទ្ធភាពឱ្យរដ្ឋបាលក្រុង ស្រុកធ្វើសេចក្តីសម្រេចចិត្តចាត់វិធានការដោះស្រាយបញ្ហាប្រឈមនានាបានឆាប់រហ័យ ទាន់ពេលវេលា និងមានប្រសិទ្ធភាពជាងមុនពេលផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា បន្ទាប់ពីការធ្វើសមារណកម្មការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ប្រធាន និងអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា ប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុកជាទៀងទាត់។ តាមរយៈការចូលរួមកិច្ចប្រជុំទាំងនេះ បានផ្តល់ឱកាសឱ្យប្រធាន និងអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាធ្វើសេចក្តីរាយការណ៍ និងលើកឡើងនូវបញ្ហាប្រឈមនានាក្នុងវិស័យអប់រំដែលត្រូវការការគាំទ្រ និងការដោះស្រាយពីរដ្ឋបាលក្រុង ស្រុក។ ករណីនេះ បានជំរុញឱ្យការិយាល័យអប់រំ យុវជន និងកីឡាកាន់តែមានការទទួលខុសត្រូវ និងគណនេយ្យភាពច្បាស់លាស់ចំពោះរដ្ឋបាលក្រុង ស្រុកក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុកលើការអនុវត្តមុខងារអប់រំដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា ទោះបីការិយាល័យអបរំ យុវជន និងកីឡាមួយចំនួនមិនស្ថិតនៅក្នុងបរិវេណនៃសាលាក្រុង ស្រុកក៏ដោយ ក៏ទំនាក់ទំនងការងាររវាងការិយាល័យអប់រំ យុវជន និងកីឡាជាមួយរដ្ឋបាលក្រុង ស្រុក និងអង្គភាពនានានៃរដ្ឋបាលក្រុង ស្រុកនៅតែមានភាពល្អប្រសើរ និងមិនបង្កការរាំងស្ទះ ឬការលំបាកក្នុងការអនុវត្តតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុកឡើយ
- រដ្ឋបាលក្រុង ស្រុកនីមួយៗបានចាត់តាំងឱ្យអភិបាលរង១រូបទទួលបន្ទុកការងារអប់រំ។ ប្រការនេះបានធ្វើឱ្យការដឹកនាំ ការគ្រប់គ្រង និងការអនុវត្តការងារអប់រំកាន់តែមានភាពល្អប្រសើរដោយថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុកអាចក្តាប់បានច្បាស់អំពីស្ថានភាពនៃការគ្រប់គ្រង ការ

ចាត់ចែង និងការអនុវត្តការងារអប់រំ ហើយបញ្ហាប្រឈម និងសំណើសំណូមពរនានាដែលត្រូវបន្តដោះស្រាយ។

**ចំណុចអភិវឌ្ឍមាន និងបញ្ហាប្រឈម៖**

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា ក្នុងឆ្នាំដំបូងៗបន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ការបំពេញការងាររបស់ការិយាល័យអប់រំ យុវជន និងកីឡាបានជួបប្រទះការលំបាកជាច្រើន ជាពិសេសពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាល ដូចជា ការរៀបចំលិខិតស្នាមពុំទាន់មានឯកភាពគ្នាអំពីទម្រង់នៃឯកសាររដ្ឋបាល ការពុំទាន់យល់ដឹងអំពីចរន្ត ឬលំហូរឯកសាររបស់រដ្ឋបាលក្រុង ស្រុក ភាពប្រទាំងប្រទើសក្នុងការប្រើប្រាស់ត្រា ដោយសារមុនការធ្វើសមាហរណកម្ម ការិយាល័យអប់រំ យុវជន និងកីឡាមានសិទ្ធិប្រើប្រាស់ត្រារបស់ខ្លួន តែក្រោយសមាហរណកម្មត្រារបស់ការិយាល័យអប់រំ យុវជន និងកីឡាពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ទៀតឡើយ។ ប្រការទាំងនេះបានធ្វើឱ្យការអនុវត្តការងារមួយចំនួនមានការលំបាក និងមានភាពយឺតយ៉ាវ។ ទោះយ៉ាងនេះក្តី មកដល់ពេលនេះ បញ្ហាទាំងនេះត្រូវបានសម្របសម្រួល និងដោះស្រាយជាបណ្តើរៗ និងធ្វើឱ្យចរន្តការងាររដ្ឋបាលមានស្ថានភាពល្អជាងមុន
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា រដ្ឋបាលក្រុង ស្រុកពុំបានផ្តល់ការបណ្តុះបណ្តាលអំពីទំនាក់ទំនងការងារ បែបបទ នីតិវិធីគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុកដល់បុគ្គលិកដែលទើបបានផ្ទេរមក ឱ្យមានការយល់ដឹងច្បាស់លាស់នៅឡើយ
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា បន្ទាប់ពីការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក មន្ត្រីថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកបានចូលរួមការផ្សព្វផ្សាយព័ត៌មានអំពីគោលការណ៍គន្លឹះៗពាក់ព័ន្ធ ក៏ប៉ុន្តែពុំដែលបានទទួលការបណ្តុះបណ្តាលជាក់លាក់ អំពីបែបបទ នីតិវិធីនៃការដឹកនាំ ការគ្រប់គ្រង និងការចាត់ចែងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកឡើយ
- ប្រព័ន្ធ និងទម្រង់របាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តមុខងារក្នុងវិស័យអប់រំ ដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុកក៏ត្រូវបានលើកឡើងថានៅមិនទាន់មានភាពច្បាស់លាស់ និងសង្គតិភាពគ្នារវាងប្រព័ន្ធ និងទម្រង់របាយការណ៍របស់ក្រសួង/មន្ទីរអប់រំ យុវជន និងកីឡា និងរបស់រដ្ឋបាលក្រុង ស្រុក
- មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាមួយចំនួនបានលើកឡើងថា ក្នុងបណ្តាឆ្នាំដំបូងៗនៃការផ្ទេរមុខងារអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកបានជួបការលំបាកក្នុងការទៅចូលរួមកិច្ចប្រជុំ និងសិក្ខាសាលានានានៅក្រៅក្រុង ស្រុក ដោយពុំមានថវិកាសម្រាប់រ៉ាប់រងលើចំណាយបេសកកម្ម និងសោហ៊ុយធ្វើដំណើរ ដោយហេតុថា មុនពេលផ្ទេរមុខងារអប់រំឱ្យរដ្ឋបាលក្រុង ស្រុក ការចំណាយទាំងនេះត្រូវបានរ៉ាប់រងដោយថវិការបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ហើយថវិកាទាំងនេះមិនត្រូវបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុកឡើយ បន្ទាប់ពីការធ្វើសមាហរណកម្ម

ការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរដ្ឋបាលក្រុង ស្រុក។ ទោះយ៉ាងនេះក្តី មកដល់បច្ចុប្បន្ននេះ បញ្ហាប្រឈមទាំងនេះត្រូវបានដោះស្រាយ ដោយរដ្ឋបាលក្រុង ស្រុកនីមួយៗបានប្រើប្រាស់ថវិកាឆន្ទានុសិទ្ធិរបស់ខ្លួន(មូលនិធិក្រុង ស្រុក) សម្រាប់រ៉ាប់រងលើការចំណាយបេសកកម្មរបស់បុគ្គលិកអប់រំដែលត្រូវទៅបំពេញបេសកកម្មនៅក្រៅរដ្ឋបាលក្រុង ស្រុក។

### ៧.២.២.ការគ្រប់គ្រងនៅតាមសាលារៀន ការអភិវឌ្ឍយុវជន និងការអប់រំកាយ និងកីឡា

ផ្អែកតាមព័ត៌មានដែលទទួលបានពីការស្ទង់មតិយោបល់ និងការយល់ឃើញក្នុងចំណោមអ្នកពាក់ព័ន្ធចំនួន៣៧០នាក់ បានបង្ហាញឱ្យឃើញថា បន្ទាប់ពីការ**ប្រគល់មុខងារ**ក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក មានមតិរហូតដល់ទៅ៦៩% បានយល់ឃើញថា ស្ថានភាពទូទៅនៅតាមសាលារៀន**មានភាពល្អប្រសើរជាងមុន** មានមតិ៣០% បានយល់ឃើញថាមានស្ថានភាពល្អដូចពេលមុន និងមានមតិតែ១%ប៉ុណ្ណោះដែលបានលើកឡើងថាមានស្ថានភាពមិនល្អជាងមុន។




ចំពោះការស្ថានភាពនៃការគ្រប់គ្រងការចាត់ចែង និងការអនុវត្តមុខងារដែលបាន**ធ្វើប្រតិភូកម្ម** (កិច្ចការរដ្ឋបាលសាលាមធ្យមសិក្សា ការអភិវឌ្ឍយុវជន និងការអប់រំកាយ និងកីឡា) ផ្អែកលើការស្ទង់មតិក្នុងចំណោមអ្នកពាក់ព័ន្ធចំនួន**១៨០នាក់**បានបង្ហាញថា មានមតិចំនួន**៥៥%**បានយល់ឃើញថាមានស្ថានភាព**ល្អប្រសើរជាងមុន** មតិប្រមាណ**៤២%**យល់ឃើញថាមានស្ថានភាពដូចពីមុន និងមានមតិ**៣%**បានយល់ឃើញថា មានស្ថានភាពមិនល្អជាងមុន។




ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ថ្នាក់ឃុំ សង្កាត់ និងសហគមន៍បានបង្ហាញឱ្យឃើញចំណុចវិជ្ជមាន និងបញ្ហាប្រឈមនៃស្ថានភាពគ្រប់គ្រងជាទូទៅនៅតាមសាលារៀនដូចខាងក្រោម៖

**ចំណុចវិជ្ជមាន៖**

- ក្រុមអ្នកផ្តល់ព័ត៌មានជាច្រើន បានបង្ហាញនូវភាពរីករាយចំពោះការមើលឃើញស្ថានភាពនៃការអភិវឌ្ឍនៅតាមសាលារៀនដែលកាន់តែមានភាពល្អប្រសើរឡើង ជាពិសេសពាក់ព័ន្ធនឹងការងារសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ វិធានការការពារកូវីដ១៩ ការរក្សាអនាម័យបរិស្ថាន សុវត្ថិភាពចំណីអាហារ ការរក្សាសុវត្ថិភាពចរាចរណ៍របស់សិស្សានុសិស្ស សកម្មភាពនៃការអភិវឌ្ឍយុវជន អប់រំកាយ និងកីឡានៅតាមសាលារៀនជាដើម ដោយសាររដ្ឋបាលក្រុង ស្រុកបានផ្តល់អាទិភាពជាចម្បងលើកិច្ចការទាំងនេះ ព្រមទាំងមានភាពម្ចាស់ការក្នុងការផ្តល់អន្តរាគមន៍គាំទ្រ និងរៀបចំយន្តការដោះស្រាយបញ្ហាប្រឈមនានាជាប្រចាំ និងច្បាស់លាស់ជាងមុនពេលផ្ទេរមុខងារអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានកត់សម្គាល់ឃើញថា ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកបានផ្តោតការយកចិត្តទុកដាក់លើការផ្តល់អន្តរាគមន៍គាំទ្រជួយដោះស្រាយបញ្ហាប្រឈម និងគ្រោះអាសន្នចំពោះមុខនានាបានឆាប់រហ័ស និងទាន់ពេលវេលាជាងមុន ដូចជា ករណីគ្រោះធម្មជាតិ ទឹកជំនន់លិចផ្លូវទៅសាលារៀន លិចទីធ្លាសាលារៀន ខ្យល់ព្យុះធ្វើឱ្យខូចខាតអគារសាលារៀន ការកកស្ទះចរាចរណ៍តាមផ្លូវទៅសាលារៀន កូនសិស្សពុលចំណីអាហារ កូនសិស្សសន្លប់ ជាពិសេសបានផ្តល់អាទិភាពដល់ការចាត់វិធានការការពារទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ដល់សិស្សានុសិស្សនៅតាមសាលារៀន ដោយបានខ្នះខ្នែងសម្របសម្រួលការរៀបចំចាក់វ៉ាក់សាំងការពារនៅតាមសាលារៀន និងការផ្តល់សម្ភារៈចាំបាច់នានា ដូចជា ម៉ាស៊ីនវាស់កំដៅ ម៉ាស់ និងអាកុលជាដើម។
- រដ្ឋបាលក្រុង ស្រុកមួយចំនួនត្រូវបានរាយការណ៍ថា បានអញ្ជើញនាយកសាលារៀនឱ្យចូលរួមរាល់កិច្ចប្រជុំរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ហើយជាទូទៅតែងលើកយកបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈនៅតាមសាលារៀនជារបៀបវារៈមួយមកពិនិត្យ ពិភាក្សា និងចាត់វិធានការដោះស្រាយក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុកជាប្រចាំ។ នៅតាមរដ្ឋបាលស្រុកផ្សេងទៀតក៏ត្រូវបានលើកឡើងថា នាយកសាលាមួយចំនួនត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ហើយក្នុងកិច្ចប្រជុំនេះក៏តែងតែបានលើកយកស្ថានភាពសន្តិសុខ សុវត្ថិភាព និងស្ថានភាពនៃការសិក្សារបស់សិស្សានុសិស្ស នៅតាមសាលារៀនមកពិនិត្យ ពិភាក្សា និងដោះស្រាយផងដែរ។ មុនពេលផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក នាយកសាលាពុំត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុកឡើយ ហើយបញ្ហាប្រឈម និងការលំបាកនានានៅតាមសាលារៀនត្រូវបានរាយការណ៍ជូនទៅការិយាល័យអប់រំ យុវជន និងកីឡា ដើម្បីស្នើសុំការអន្តរាគមន៍ដោះស្រាយ ដែលករណីនេះ ការដោះស្រាយបញ្ហាប្រឈមទាំងនោះពុំសូវមានប្រសិទ្ធភាព និងទាន់ពេលវេលាដូចការផ្តល់អន្តរាគមន៍ដោះស្រាយនាពេលបច្ចុប្បន្ន។
- ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុកមួយចំនួនបានចុះត្រួតពិនិត្យជាប្រចាំ និងការចុះត្រួតពិនិត្យដោយពុំជូនដំណឹងមុននៅតាមសាលារៀនទៅលើការគ្រប់គ្រង និងផ្តល់សេវាអប់រំ។ ប្រការនេះ

បានជំរុញឱ្យថ្នាក់ដឹកនាំសាលា លោកគ្រូ អ្នកគ្រូពង្រឹងការអនុវត្តក្រមសីលធម៌ វិន័យ និងការបំពេញការងារបានកាន់តែល្អជាងមុន រួមទាំងការកែលម្អសោភ័ណភាព ការថែរក្សាអនាម័យបរិស្ថានក្នុងបរិវេណសាលារៀនផងដែរ។ មុនពេលផ្ទេរមុខងារ រដ្ឋបាលក្រុង ស្រុកក៏បានអនុវត្តការងារទាំងនេះដែរ ក៏ប៉ុន្តែការអនុវត្តការងារនេះពុំបានទៀងទាត់ និងជិតដល់ដូចពេលផ្ទេរមុខងារមកស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកឡើយ។

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានសង្កេតឃើញថា បន្ទាប់ពីការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកមានទំនាក់ទំនងការងារកាន់តែស្និទ្ធស្នាលជាមួយបុគ្គលិកអប់រំ រួមមានមន្ត្រីការិយាល័យអប់រំ នាយក នាយិកាសាលា និងលោកគ្រូ អ្នកគ្រូនៅតាមសាលារៀន។ ថ្នាក់ដឹកនាំក្រុង ស្រុកបានចូលរួម ដឹកនាំជាមួយបុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡាចុះទៅតាមសាលារៀន ដើម្បីផ្តល់ការផ្សព្វផ្សាយណែនាំអំពីការពង្រឹងការគ្រប់គ្រងសាលារៀន ការគ្រប់គ្រងសិស្ស ការបង្រៀន និងវិធានរក្សាបរិស្ថានស្អាត អនាម័យល្អ និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀន...ជាដើម។ ភាពស្និទ្ធស្នាល និងកិច្ចសហការបានល្អពីថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកបានធ្វើឱ្យបុគ្គលិកអប់រំ លោកគ្រូ អ្នកគ្រូបម្រើការងារនៅតាមសាលារៀនកាន់តែមានភាពកក់ក្តៅ និងជំរុញទឹកចិត្តក្នុងការចូលរួមសកម្មភាពអភិវឌ្ឍតាមសាលារៀនឱ្យកាន់តែមានស្ថានភាពល្អប្រសើរជាងមុន
- រដ្ឋបាលក្រុង ស្រុកមួយចំនួនត្រូវបានរាយការណ៍ថា បានកៀរគរការឧបត្ថម្ភ គាំទ្រពីស្ថាប័ននានា សប្បុរសជន និងវិស័យឯកជនក្នុងការរៀបចំការប្រកួតកីឡានៅតាមសាលារៀន ដែលបានធ្វើឱ្យសកម្មភាពកីឡាក្នុងរដ្ឋបាលក្រុង ស្រុកកាន់តែមានភាពសកម្មជាងមុន
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងអំពីភាពកាន់តែសកម្មជាងមុនរបស់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុកក្នុងការសម្របសម្រួលជាមួយរដ្ឋបាលឃុំ សង្កាត់ឱ្យផ្តោតការយកចិត្តទុកដាក់ជួយគាំទ្រ និងដោះស្រាយបញ្ហានានានៅតាមសាលារៀន ដូចជារៀបចំការប្រឡងប្រណាំងសាលាស្អាត និងការជួយឧបត្ថម្ភដល់សិស្សបោះបង់ការសិក្សា ការសម្អាតបរិវេណសាលា ការសាសង់របងសាលា ការចាក់ដីក្នុងទីធ្លាសាលា ការកែលម្អបរិស្ថាន ការការពារសន្តិសុខ និងសុវត្ថិភាពរបស់សិស្សានុសិស្សជាដើម
- បន្ទាប់ពីការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលរដ្ឋបាលក្រុង ស្រុក និងដោយមានកិច្ចសហការ និងការគាំទ្រពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា រដ្ឋបាលក្រុង ស្រុកមួយចំនួនបានផ្តួចផ្តើមរៀបចំបង្កើតយន្តការគាំទ្រដល់ការអនុវត្តមុខងារអប់រំទាំងនេះ រួមមានដូចជា គណៈកម្មការគាំទ្រការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក គណៈកម្មការគ្រប់គ្រងចំណីអាហារតាមសាលារៀន គណៈកម្មការវាយតម្លៃផ្តល់សេវាសាធារណៈគំរូ គណៈកម្មការកូវីដ-១៩ជាដើម ដើម្បីលើកកម្ពស់ការរៀបចំផែនការ ការគាំទ្រ ការសម្របសម្រួល និងការត្រួតពិនិត្យដំណើរការនៅតាមសាលារៀននីមួយៗ

- បន្ទាប់ពីការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ជាពិសេស អភិបាល និងអភិបាលរងដែលទទួលបន្ទុកការងារអប់រំតែងតែបានចូលរួមវេទិកានានានៅតាមសាលារៀន ដូចជាការបើកបវេសនកាល ទិវាបរិស្ថាន កម្មវិធីប្រកួតកីឡា និងកម្មវិធីផ្តល់អាហារូបករណ៍...ជាដើម
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានកត់សម្គាល់ឃើញថា រាល់កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុង ស្រុក កិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងវេទិកាពិគ្រោះយោបល់សាធារណៈរបស់ក្រុមប្រឹក្សា តែងតែបានលើកយកបញ្ហាពាក់ព័ន្ធនឹងការងារអប់រំ ជាពិសេសការងារអភិវឌ្ឍនៅតាមសាលារៀនមកពិភាក្សា និងដោះស្រាយជាប្រចាំ
- ក្រុមប្រឹក្សាក្រុង ស្រុកមួយចំនួនបានដាក់ចេញនូវដីកាដើម្បីចាត់វិធានការគ្រប់គ្រងអនាម័យសុវត្ថិភាពចំណីអាហារ និងបរិស្ថាននៅតាមសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ចំណុចអវិជ្ជមាន និងបញ្ហាប្រឈម

ក្នុងការជួបពិភាក្សាជាមួយក្រុមការងារបច្ចេកទេសអន្តរក្រសួង ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនក៏បានលើកឡើងនូវចំណុចអវិជ្ជមាន និងបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តដោះស្រាយ និងកែលម្អរួមមាន៖

- ថ្វីត្បិតតែថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុកបានបង្ហាញអំពីឆន្ទៈ និងការទទួលខុសត្រូវខ្ពស់ក្នុងការគាំទ្រ និងជំរុញការអភិវឌ្ឍតាមសាលារៀនឱ្យបានកាន់តែល្អប្រសើរ ក៏ប៉ុន្តែថ្នាក់ដឹកនាំរដ្ឋបាល ក្រុង ស្រុកពុំទាន់មានការយល់ដឹងច្បាស់អំពីគោលការណ៍ វិធីសាស្ត្រ និងនិយាមក្នុងការគ្រប់គ្រង និងអភិវឌ្ឍសាលារៀន ដែលជាហេតុធ្វើឱ្យការគ្រប់គ្រង និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុកនៅមានចំណុចធកល្វែងមួយចំនួន
- ទោះបីរដ្ឋបាលក្រុង ស្រុកផ្តោតការយកចិត្តទុកដាក់លើការការពារសន្តិសុខ របៀបរៀបរយ និងសណ្តាប់ធ្នាប់សាធារណៈនៅតាមសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ក៏នៅមានការលើកឡើងអំពីការភ័យខ្លាច និងព្រួយបារម្ភចំពោះសកម្មភាពក្មេងទំនើង ប្រើប្រាស់គ្រឿងញៀននៅក្បែរសាលារៀនជាដើម
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងអំពីការថែរក្សាអនាម័យ និងបរិស្ថាននៅតាមសាលារៀនមួយចំនួននៅមិនទាន់មានភាពល្អប្រសើរនៅឡើយ ដោយសារបញ្ហាប្រឈមនៃការគ្រប់គ្រងសំរាម (មានឡដុតសំរាមតែមិនអាចប្រើប្រាស់បាន ពេលខ្លះមានការរៀបចំកម្មវិធីតន្ត្រីក្បែរសាលារៀនធ្វើឱ្យមានការពង្រាយសំរាមនៅក្បែរបរិវេណសាលារៀន..)
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងអំពីបញ្ហាលំបាក និងភាពយឺតយ៉ាវមួយចំនួនពាក់ព័ន្ធការរៀបចំលិខិតស្នាមរដ្ឋបាល ការធ្វើចរាចរណ៍លិខិត ភាពមិនទាន់ច្បាស់លាស់នៃការប្រើប្រាស់ត្រារបស់សាលារៀននីមួយៗ ដែលតម្រូវឱ្យមានការណែនាំឱ្យបានជាក់លាក់បន្ថែមទៀត។

### ៧.២.៣. ការគ្រប់គ្រងបុគ្គលិកអប់រំ

ពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពនៃការគ្រប់គ្រងបុគ្គលិក ផ្អែកតាមការស្ទង់មតិពីអ្នកពាក់ព័ន្ធចំនួន**៣២០នាក់**បានបង្ហាញឱ្យឃើញថា មតិ**៦៨%**យល់ឃើញថាល្អជាងមុន មតិ**២៩%**យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ៣%យល់ឃើញថាអន់ជាងមុន។




លទ្ធផលនៃការស្ទង់មតិអំពីស្ថានភាពគ្រប់គ្រងបុគ្គលិកអប់រំដែលបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក តាមស្ថានភាពរដ្ឋបាលនៃការគ្រប់គ្រងបុគ្គលិកបានបង្ហាញក្នុងតារាងខាងក្រោម៖

| ល. | ស្ថានភាពរដ្ឋបាល | ចំនួនអ្នកផ្តល់ព័ត៌មាន | ការយល់ឃើញ | | |
|---|---|---|---|---|---|
| | | | ល្អជាងមុន | ដូចមុន | អន់ជាងមុន |
| ១ | ការតែងតាំង | 320 | 234 (73%) | 75 (23%) | 11 (3%) |
| ២ | ការដំឡើងថ្នាក់/ឋានន្តរស័ក្តិ | 320 | 251 (78%) | 65 (20%) | 4 (1%) |
| ៣ | ការផ្លាស់ប្តូរ | 320 | 159 (50%) | 130 (41%) | 31 (9%) |
| ៤ | ការចូលនិវត្តន៍ | 317 | 215 (68%) | 96 (30% | 6 (2%) |
| ៥ | ការគ្រប់គ្រងវត្តមានបុគ្គលិក | 320 | 230 (72%) | 86 (27%) | 4 (1%) |
| ៦ | ការដឹកនាំគ្រប់គ្រងបុគ្គលិក | 389 | 261 (67%) | 119 (31%) | 9 (2%) |

ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ថ្នាក់ឃុំ សង្កាត់ និងសហគមន៍បានបង្ហាញឱ្យឃើញអំពីស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំបន្ទាប់ពីបានផ្ទេរឱ្យមកក្លាយជាបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ដូចមានលទ្ធផលខាងក្រោម៖

#### ចំណុចវិជ្ជមាន៖

- ក្រុមអ្នកផ្តល់ព័ត៌មានស្ទើរទាំងអស់ដែលក្រុមការងារបច្ចេកទេសបានជួបពិភាក្សា បានបង្ហាញនូវភាពពេញចិត្តចំពោះការផ្ទេរបុគ្គលិកអប់រំមកជាបុគ្គលិករបស់រដ្ឋបាល ក្រុង ស្រុក ដែលបានធ្វើឱ្យស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំទាំងនោះមានលក្ខណៈល្អប្រសើរជាងមុន ដោយសារគោលការណ៍ បែបបទ និងនីតិវិធីនៃគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុកមានភាពងាយស្រួល តម្លាភាព ប្រសិទ្ធភាព និងឆាប់រហ័ស ដែលការសម្រេចនានាត្រូវធ្វើឡើងនៅថ្នាក់

ក្រុង ស្រុកតែម្តង ដោយពុំចាំបាច់បញ្ជូនឯកសារទៅថ្នាក់មន្ទីរ ថ្នាក់ខេត្ត និងថ្នាក់ក្រសួងដើម្បីធ្វើការសម្រេចដូចពេលមុនឡើយ។

- ក្រុមអ្នកផ្តល់ព័ត៌មានជាច្រើនបានលើកឡើងថា បន្ទាប់ពីការផ្ទេរបុគ្គលិកអប់រំមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ការតែងតាំង ការផ្លាស់ប្តូរ ការឡើងថ្នាក់ ឋានន្តរស័ក្តិ ការចូលនិវត្តន៍ និងការស្នើសុំលិខិតស្នាមផ្សេងៗពាក់ព័ន្ធនឹងការងារបុគ្គលិកបានលឿន ត្រឹមត្រូវ និងឆាប់រហ័សជាងមុនពេលផ្ទេរ ដោយហេតុថា រដ្ឋបាលក្រុង ស្រុកនៅកៀកជិតជាមួយបុគ្គលិកអប់រំ បានទទួលព័ត៌មាន និងយល់ដឹងច្បាស់អំពីស្ថានភាពរបស់បុគ្គលិកទាំងនោះ។ ទន្ទឹមគ្នានេះ រដ្ឋបាលក្រុង ស្រុកតែងតែផ្តល់ការណែនាំដល់បុគ្គលិកអប់រំ រួមមានបុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡា និងគ្រូបង្រៀននៅតាមសាលារៀនអំពីកិច្ចការដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក ជាពិសេសការឡើងថ្នាក់ ឋានន្តរស័ក្តិ ការដាក់ឱ្យចូលនិវត្តន៍ ដែលប្រការនេះធ្វើឱ្យបុគ្គលិកអប់រំទទួលបានព័ត៌មានច្បាស់លាស់ហើយអាចបំពេញបែបបទនានាតាមគោលការណ៍កំណត់បានត្រឹមត្រូវ និងទាន់ពេលវេលា។
- ក្រុមអ្នកផ្តល់ព័ត៌មានក៏បានលើកឡើងថា ការគ្រប់គ្រងវត្តមានរបស់បុគ្គលិកអប់រំ គ្រូបង្រៀនត្រូវបានពង្រឹងតាមរយៈការរៀបចំបញ្ជីវត្តមាន និងការត្រួតពិនិត្យជាទៀងទាត់ដោយការិយាល័យអប់រំ យុវជន និងកីឡា ការិយាល័យគ្រប់គ្រងធនធានមនុស្ស និងការចុះត្រួតពិនិត្យនៅតាមសាលារៀនផ្ទាល់ដោយថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា រដ្ឋបាលក្រុង ស្រុកមានទំនាក់ទំនងការងារល្អជាមួយមន្ទីរមុខងារសាធារណៈខេត្តក្នុងកិច្ចដំណើរការគ្រប់គ្រងបុគ្គលិកតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់ ហើយមន្ទីរមុខងារសាធារណៈខេត្តក៏តែងតែបានផ្តល់ការណែនាំ សម្របសម្រួល និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើកិច្ចការគ្រប់គ្រងបុគ្គលិក។ ប្រការនេះបានជំរុញការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុកមានដំណើរការប្រកបដោយភាពរលូន ឆាប់រហ័ស និងប្រសិទ្ធភាព។
- ក្រុមអ្នកផ្តល់ព័តមានក៏បានលើកឡើងដែរថា ការិយាល័យគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលក្រុង ស្រុកតែងតែបានសហការជាមួយការិយាល័យអប់រំ យុវជន និងកីឡាក្នុងការអនុវត្តការងារគ្រប់គ្រងបុគ្គលិកអប់រំ ដែលជាការរួមចំណែកដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងបុគ្គលិកបានល្អប្រសើរជាងមុន។

### ចំណុចអវិជ្ជមាន និងបញ្ហាប្រឈម៖

- ការខ្វះចំនួនបុគ្គលិកដែលបម្រើការងារនៅការិយាល័យអប់រំ យុវជន និងកីឡា និងការខ្វះចំនួនគ្រូបង្រៀននៅតាមសាលារៀនត្រូវបានលើកឡើងថា ជាចំណុចអវិជ្ជមាន និងជាបញ្ហាប្រឈមខ្លាំងស្ទើរនៅគ្រប់រដ្ឋបាលក្រុង ស្រុកដែលក្រុមការងារបច្ចេកទេសអន្តរក្រសួងបានចុះទៅសិក្សាវាយតម្លៃ។ ការខ្វះបុគ្គលិកអប់រំនេះអាចបណ្តាលមកពីមូលហេតុមួយចំនួន រួមមានដូចជា៖

- ការចូលនិវត្តន៍របស់បុគ្គលិកអប់រំ ដោយពុំបានរៀបចំបុគ្គលិកជំនួសឱ្យបានគ្រប់តាមចំនួនដែលត្រូវការ
- រដ្ឋបាលក្រុង ស្រុកមួយចំនួនបានតែងតាំង ឬចាត់តាំងបុគ្គលិកអប់រំមួយចំនួនឱ្យទៅបម្រើការងារនៅការិយាល័យ និងអង្គភាពផ្សេងក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ដែលមានតម្រូវការបុគ្គលិកជាចាំបាច់
- ការណែនាំពីថ្នាក់ជាតិឱ្យរដ្ឋបាលក្រុង ស្រុកផ្អាកការផ្លាស់ប្តូរ ឬការផ្ទេរបុគ្គលិកអប់រំទៅបម្រើការងារនៅក្រៅរដ្ឋបាលក្រុង ស្រុកសាមីនីមួយៗ។ ប្រការនេះបានធ្វើឱ្យរដ្ឋបាលក្រុង ស្រុកដែលខ្វះចំនួនបុគ្គលិកអប់រំ ហើយមានតម្រូវការជាចាំបាច់សម្រាប់បំពេញការងារអប់រំ មិនអាចទទួលបានបុគ្គលិកអប់រំដែលមានបំណងផ្ទេរមកពីរដ្ឋបាលក្រុង ស្រុកដែលមានចំនួនបុគ្គលិកអប់រំច្រើនបានឡើយ។

- ក្រុមអ្នកផ្តលព័ត៌មានមួយចំនួនបានលើកឡើងអំពីបញ្ហាប្រឈម និងការលំបាករបស់ការិយាល័យគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលក្រុង ស្រុក ដែលមានបន្ទុកការងារច្រើន ដោយសារបុគ្គលិកអប់រំដែលបានផ្ទេរមករដ្ឋបាលក្រុង ស្រុកមានចំនួនច្រើន ហើយចំនួនបុគ្គលិកដែលបម្រើការងារក្នុងការិយាល័យនេះមានចំនួនតិច (១ទៅ២នាក់)
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា នៅតាមសាលារៀនមួយចំនួនជួបការលំបាកក្នុងការរៀបចំគ្រូបង្រៀនថ្នាក់ពីរពេល ថ្នាក់គួប និងគ្រូជំនួស ក្នុងករណីមានគ្រូផ្លាស់ចេញ ឬបោះបង់ការងារ ឬការលំហែរមាតុភាព ឬការចូលនិវត្តន៍។ បញ្ហាប្រឈមនេះក៏ធ្លាប់កើតមានឡើងមុនពេលផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ហើយអូសបន្លាយមកដល់ពេលនេះ។
- អ្នកផ្តល់ព័ត៌មានមួយចំនួនក៏បានលើកឡើងថា បច្ចុប្បន្ន រដ្ឋបាលក្រុង ស្រុកពុំទាន់មានផែនការច្បាស់លាស់សម្រាប់អភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន ជាពិសេសលើចំណេះដឹងផ្នែកព័ត៌មានវិទ្យា និងគរុកោសល្យលើមត្តេយ្យសិក្សា និងបឋមសិក្សា

### ៧.២.៤. ការគ្រប់គ្រង និងការប្រើប្រាស់ថវិកា

### ក. ការគ្រប់គ្រងថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡា

ផ្អែកតាមការស្ទង់មតិពីអ្នកពាក់ព័ន្ធចំនួន **១៧៦**នាក់បានបង្ហាញឱ្យឃើញថា មានមតិ៤៤% យល់ឃើញថាមានស្ថានភាពនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បានល្អជាងមុន មតិ ៤០%យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ ១៦%យល់ឃើញថាមានស្ថានភាពអន់ជាងមុន។




ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុកបានបង្ហាញឱ្យឃើញអំពីស្ថានភាពនៃការគ្រប់គ្រង ការចាត់ចែង ការប្រើប្រាស់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុកមានដូចខាងក្រោម៖

**ចំណុចវិជ្ជមាន៖**

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា ការគ្រប់គ្រង និងការប្រើប្រាស់កញ្ចប់ថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាបច្ចុប្បន្នកាន់តែមានតម្លាភាព និងគណនេយ្យភាព ដោយសារថវិកានេះត្រូវបានដាក់ឱ្យអនុវត្តតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ដែលបង្កលក្ខណៈងាយស្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រង ការចាត់ចែង ការប្រើប្រាស់ ការតាមដាន និងការត្រួតពិនិត្យ។
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា រដ្ឋបាលក្រុង ស្រុកបានផ្តល់អាទិភាពក្នុងការបើកផ្តល់ថវិកាបុរេប្រទាន និងសម្ភារៈនានាឱ្យការិយាល័យអប់រំ យុវជន និងកីឡាតាមចំនួនកំណត់ និងតាមការស្នើសុំរបស់ការិយាល័យអប់រំ យុវជន និងកីឡា ដើម្បីធានាឱ្យការិយាល័យអប់រំ យុវជន និងកីឡាមានថវិកា និងសម្ភារៈសមស្របសម្រាប់អនុវត្តភារកិច្ចរបស់ខ្លួន
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងអំពីការរៀបចំឯកសារបើកប្រាក់បៀវត្សរបស់បុគ្គលិកអប់រំបានងាយស្រួល និងបានលឿនជាងមុន ដោយសារឯកសារសម្រាប់បើកប្រាក់បៀវត្សរបស់បុគ្គលិកអប់រំទាំងនោះត្រូវរៀបចំដោយរដ្ឋបាលក្រុង ស្រុកសាមីនីមួយៗហើយបញ្ជូនត្រង់ទៅមន្ទីរមុខងារសាធារណៈតែម្តង ដោយពុំចាំបាច់បញ្ជូនឱ្យមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីបូកសរុបរួចហើយទើបបញ្ជូនទៅមន្ទីរមុខងារសាធារណៈដូចមុនទៀតឡើយ
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានកត់សម្គាល់ឃើញថា រដ្ឋបាលក្រុង ស្រុកមួយចំនួនបានប្រើប្រាស់ថវិកាឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីគាំទ្របន្ថែមដល់ការអនុវត្តសកម្មភាពអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក រួមមានដូចជាការផ្តល់ប្រាក់បេសកកម្មដល់បុគ្គលិកអប់រំដែលត្រូវទៅបំពេញបេសកកម្មចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងព្រឹត្តិការណ៍ពាក់ព័ន្ធនានានៅក្រៅរដ្ឋបាលក្រុង ស្រុក ការផ្តល់ថវិកាសម្រាប់គាំទ្រដល់សកម្មភាពរបស់គណៈកម្មការគាំទ្រការ

អនុវត្តមុខងារអប់រំ ជាដើម។ ជាមួយគ្នានេះ រដ្ឋបាលក្រុង ស្រុកមួយចំនួនក៏បានបែងចែកប្រាក់រង្វាន់លើកទឹកចិត្តពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុកជូនដល់បុគ្គលិកអប់រំបម្រើការងារក្នុងការិយាល័យអប់រំ យុវជន និងកីឡាផងដែរ

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនក៏បានលើកឡើងថា ក្នុងកិច្ចដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុតែងតែសហការជាមួយបុគ្គលិកទទួលបន្ទុកហិរញ្ញវត្ថុនៃការិយាល័យអប់រំ យុវជន និងកីឡាក្នុងការរៀបចំគម្រោងថវិកាសម្រាប់គាំទ្រដល់ការអនុវត្តមុខងារក្នុងវិស័យអប់រំដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក។

## ចំណុចអវិជ្ជមាន និងបញ្ហាប្រឈមៈ

- ទោះបីការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានដាក់ឱ្យអនុវត្តតាមប្រព័ន្ធគ្រប់គ្រង និងនីតិវិធីហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុកតែមួយក៏ដោយ ក៏ផ្អែកតាមការអនុវត្តជាក់ស្តែង ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់កញ្ចប់ថវិកានេះត្រូវបានរកឃើញថា មានស្ថានភាពផ្សេងៗគ្នានៅតាមរដ្ឋបាលក្រុង ស្រុកនីមួយៗជាអាទិ៍ (១) រដ្ឋបាលស្រុកមួយចំនួនបានផ្តល់រជ្ជទេយ្យបុរេប្រទាន៣០%ទៅឱ្យការិយាល័យអប់រំ យុវជន និងកីឡាសម្រាប់កិច្ចដំណើរការរដ្ឋបាលតិចតួច (២) រដ្ឋបាលក្រុង ស្រុកមួយចំនួនបានផ្តល់រជ្ជទេយ្យបុរេប្រទានជាសាច់ប្រាក់ជូនការិយាល័យអប់រំ យុវជន និងកីឡាសម្រាប់យកទៅប្រើប្រាស់ទាំងសម្រាប់ដំណើរការរដ្ឋបាលតិចតួច និងទាំងសម្រាប់ទិញឧបករណ៍ សម្ភារៈការិយាល័យ និង (៣) រដ្ឋបាលក្រុង ស្រុកមួយចំនួនមិនបានផ្តល់រជ្ជទេយ្យបុរេប្រទានសាច់ប្រាក់ទៅឱ្យការិយាល័យអប់រំ យុវជន និងកីឡាឡើយ គឺតម្រូវឱ្យអនុវត្តតាមកិច្ចលទ្ធកម្មរួម និងការស្នើសុំទូទាត់ពីរដ្ឋបាលក្រុង ស្រុក។
- ការអនុវត្តថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡា តាមប្រព័ន្ធនិងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានលើកឡើងថា មានការលំបាក និងមានភាពយឺតយ៉ាវជាងមុន ដោយហេតុថា មុនពេលផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានអនុវត្តតាមការផ្តល់រជ្ជទេយ្យបុរេប្រទានទាំងអស់(១០០%)ពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តមកគណនីរបស់ការិយាល័យអប់រំ យុវជន និងកីឡាគ្រង់តែម្តង (បុរេប្រទាន១ឆមាសម្តង) ហើយការិយាល័យអប់រំ យុវជន និងកីឡាជាអ្នកប្រើប្រាស់រជ្ជទេយ្យបុរេប្រទានទាំងនេះដោយខ្លួនឯងផ្ទាល់សម្រាប់ចំណាយលើមុខចំណាយនានា (បេសកកម្ម សម្ភារៈការិយាល័យ ការជួសជុលតូចតាច និងប្រតិបត្តិការរដ្ឋបាល) តាមការកំណត់ ដោយពុំចាំបាច់ស្នើសុំការទូទាត់ទៅរតនាគារ និងធ្វើកិច្ចលទ្ធកម្មឡើយ។ ប្រការនេះបានបង្កលក្ខណៈងាយស្រួលដល់ការិយាល័យអប់រំ យុវជន និងកីឡាដកថវិកានេះយកមកប្រើប្រាស់តាមតម្រូវការបានភ្លាមៗ។ បន្ទាប់ពីការផ្ទេរមុខងារអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និង

កីឡាត្រូវបានដាក់បញ្ចូលក្នុងថវិការួមរបស់រដ្ឋបាលក្រុង ស្រុក ហើយត្រូវអនុវត្តតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ដែលក្នុងនោះ ថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាចំនួន៣០%ត្រូវបានបើកផ្តល់ពីរតនាគារខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុកតាមរយៈរដ្ឋទេយ្យបុរេប្រទាន។ បន្ទាប់មក រដ្ឋបាលក្រុង ស្រុកត្រូវបន្តបើកផ្តល់រដ្ឋទេយ្យបុរេប្រទាននេះជូនការិយាល័យអប់រំ យុវជន និងកីឡាសម្រាប់ប្រើប្រាស់លើចំណាយដំណើរការរដ្ឋបាលតិចតួចតាមការកំណត់។ ថវិកាគាំទ្រប្រតិបត្តិការរបស់ការិយាល័យអប់រំ យុវជន និងកីឡាចំនួន៧០%ទៀត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ត្រង់ពីរតនាគារខេត្ត រួមមានថវិកាសម្រាប់បេសកកម្ម និងសម្រាប់ការទិញឧបករណ៍ សម្ភារៈនានាតាមរយៈកិច្ចលទ្ធកម្មសាធារណៈ និងផ្អែកតាមការបោះផ្សាយអាណត្តិបើកប្រាក់របស់រដ្ឋបាលក្រុង ស្រុកនីមួយៗ។

- ការិយាល័យអប់រំ យុវជន និងកីឡាទទួលបានឧបករណ៍ សម្ភារៈការិយាល័យតិចជាងមុន ការជួសជុលឧបករណ៍នានាយឺតយ៉ាវជាងមុន ដោយសាររដ្ឋបាលក្រុង ស្រុកត្រូវធ្វើលទ្ធកម្មឧបករណ៍ សម្ភារៈរួមគ្នា ហើយរដ្ឋបាលក្រុង ស្រុកមួយចំនួនបានចែករំលែកសម្ភារៈការិយាល័យមួយចំនួនតូចឱ្យទៅអង្គភាពផ្សេងទៀត។ ពេលមុនធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាមករដ្ឋបាលក្រុង ស្រុក ខណ្ឌ កញ្ចប់ថវិកានេះត្រូវបានគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ដោយការិយាល័យអប់រំ យុវជន និងកីឡាផ្ទាល់តែម្តង មានន័យថា ការទិញ ឧបករណ៍ សម្ភារៈ ការជួសជុល និងការចំណាយលើមុខចំណាយដែលបានកំណត់ ត្រូវធ្វើឡើងដោយការិយាល័យ អប់រំ យុវជន និងកីឡា
- ការបើកប្រាក់បេសកកម្មរបស់បុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានលើកឡើងថាមានភាពយឺតយ៉ាវជាងមុន ដោយហេតុថាការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុកពុំមានលទ្ធភាពរៀបចំឯកសារទូទាត់ប្រាក់បេសកកម្មជូនបុគ្គលិកម្នាក់ៗបានភ្លាមៗបន្ទាប់បុគ្គលិកទាំងនោះចុះទៅបំពេញបេសកកម្មឡើយ គឺត្រូវរៀបចំឯកសារ និងទូទាត់ប្រាក់បេសកកម្មជូនបុគ្គលិករួមគ្នាប្រចាំត្រីមាស ឬប្រចាំឆមាស។ មុនពេលផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ការិយាល័យអប់រំ យុវជន និងកីឡាមានលទ្ធភាពបើកប្រាក់បេសកកម្មឱ្យបុគ្គលិកចុះទៅបំពេញការងារនៅតាមសាលារៀនមុនពេលចុះទៅបំពេញបេសកកម្ម ឬបន្ទាប់ពីបានបំពេញបេសកកម្មភ្លាមៗ ដោយសារកញ្ចប់ថវិកាសម្រាប់បើកប្រាក់បេសកកម្មទាំងនេះមានតម្កល់នៅក្នុងគណនីធនាគារឯកជនរបស់ការិយាល័យអប់រំ យុវជន និងកីឡាផ្ទាល់តែម្តង
- ការប្រើប្រាស់ថវិកាប្រចាំឆ្នាំសម្រាប់ប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាចំនួនប្រមាណ៣០លានរៀលក្នុង១ឆ្នាំៗដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ ត្រូវបានរាយការណ៍ថា ពុំបានចំណាយគ្រប់ចំនួនទាំងអស់សម្រាប់គាំទ្រប្រតិបត្តិការនៃការិយាល័យអប់រំ យុវជន និងកីឡាឡើយ ដោយសារថវិកានេះត្រូវបានដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិការួមរបស់រដ្ឋបាលក្រុង ស្រុក និងពុំបានកំណត់ច្បាស់លាស់ថាជាកញ្ចប់ថវិកាមានភ្ជាប់លក្ខខណ្ឌ

សម្រាប់រ៉ាប់រងតែទៅលើចំណាយគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាឡើយ អាស្រ័យហេតុនេះរដ្ឋបាលក្រុង ស្រុកមួយចំនួនបានចែករំលែកថវិកានេះសម្រាប់រ៉ាប់រងលើការចំណាយគាំទ្រប្រតិបត្តិការការិយាល័យ ឬអង្គភាពផ្សេងទៀត

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងអំពីការបែងចែកថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាដែលមានចំនួនប្រមាណ៣០លានរៀលក្នុងមួយឆ្នាំ គឺពុំទាន់សមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់ការិយាល័យអប់រំ យុវជន និងកីឡានៅតាមរដ្ឋបាលក្រុង ស្រុកនីមួយៗឡើយ ព្រមទាំងពុំទាន់មានសមធម៌ឡើយ ដោយហេតុថា ក្រុង ស្រុកនីមួយៗមានចំនួនគ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងចំនួនបុគ្គលិកអប់រំនៃការិយាល័យអប់រំ យុវជន និងកីឡាមិនដូចគ្នាឡើយ។ ក្នុងន័យនេះ ចំពោះក្រុង ស្រុកដែលមានគ្រឹះស្ថានសិក្សាស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនមានចំនួនច្រើន គឺត្រូវការថវិកាសម្រាប់ចុះត្រួតពិនិត្យ និងគាំទ្របច្ចេកទេសនៅតាមសាលារៀន និងថវិកាសម្រាប់រ៉ាប់រងលើបន្ទុកការងាររបស់ការិយាល័យអប់រំ យុវជន និងកីឡាច្រើនជាងក្រុង ស្រុកដែលមានគ្រឹះស្ថានសិក្សាចំនួនតិច។ ដូច្នេះការបែងចែកថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាដែលមានចំនួនស្មើៗនេះត្រូវបានរាយការណ៍ថាមានបញ្ហាកង្វះថវិកាសម្រាប់រដ្ឋបាលក្រុង ស្រុកដែលមានបន្ទុកការងារអប់រំច្រើន
- ក្រុមផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងអំពីការលំបាកក្នុងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរប្រតិភូកម្មឱ្យរដ្ឋបាលក្រុង ស្រុក ដូចជា មុខងារគាំទ្រកិច្ចការរដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ មុខងារអភិវឌ្ឍយុវជន និងមុខងារអប់រំកាយ និងកីឡាជាដើម ដោយហេតុថា ពុំមានការផ្ទេរថវិកាជាក់លាក់មកឱ្យរដ្ឋបាលក្រុង ស្រុកសម្រាប់អនុវត្តមុខងារដែលបានផ្ទេរប្រតិភូកម្មទាំងនេះឡើយ ពោលគឺថវិកាទាំងនេះស្ថិតនៅក្នុងកញ្ចប់ថវិការបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ក្នុងការអនុវត្តមុខងារដែលបានផ្ទេរប្រតិភូកម្មទាំងនេះ រដ្ឋបាលក្រុង ស្រុក និងការិយាល័យអប់រំ យុវជន និងកីឡាបានខិតខំកៀរគរធនធានពីស្ថាប័ននានា សប្បុរសជន អង្គការសង្គមស៊ីវិល និងផ្នែកឯកជន ឬប្រើប្រាស់ធនធានផ្ទាល់ខ្លួនសម្រាប់គាំទ្របន្ថែមលើកិច្ចការទាំងនេះ។

### ខ. ការគ្រប់គ្រងថវិកាដំណើរការសាលារៀន

ផ្អែកតាមការស្ទង់មតិពីអ្នកពាក់ព័ន្ធចំនួន ៣៩០នាក់បានបង្ហាញឱ្យឃើញថា មតិ៦២% យល់ឃើញថាមានស្ថានភាពល្អជាងមុន មតិ៣៦% យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ២%យល់ឃើញថាមានស្ថានភាពអន់ជាងមុន។

ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងសហគមន៍បានបង្ហាញឱ្យឃើញអំពីចំណុចវិជ្ជមាន និងបញ្ហាប្រឈមនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាដំណើរការសាលារៀនដូចខាងក្រោម៖




**ចំណុចវិជ្ជមាន៖**

- ការផ្ទេរថវិកាដំណើរការរបស់សាលារៀនត្រូវបានរាយការណ៍ថា បានផ្ទេរកញ្ចប់ថវិកានេះទៅគណនីរបស់សាលារៀននីមួយៗបានលឿនជាងមុន ដោយសាររដ្ឋបាលក្រុង ស្រុកនីមួយៗជាអ្នកបោះផ្សាយអាណត្តិបើកប្រាក់ដើម្បីផ្ទេរថវិកានេះទៅគណនីសាលារៀននីមួយៗក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលកាលពីមុន ការបោះផ្សាយអាណត្តិបើកប្រាក់ទាំងនេះត្រូវធ្វើឡើងដោយមន្ទីរអប់រំ យុវជន និងកីឡា ដែលត្រូវទទួលខុសត្រូវកិច្ចការទាំងនេះសម្រាប់សាលារៀនទាំងអស់ទូទាំងខេត្តដែលមានចំនួនច្រើន និងបន្ទុកការងារច្រើន
- បើទោះបីថវិកានេះត្រូវបានផ្ទេរមកក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុកក៏ដោយ ក៏សាលារៀននីមួយៗត្រូវបានរក្សាស្វ័យភាពក្នុងការចាត់ចែង និងការប្រើប្រាស់ថវិកាទាំងនេះដោយផ្ទាល់តាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលជាហេតុធ្វើឱ្យសាលារៀននីមួយៗអាចចាត់ចែងថវិកាទាំងនេះបានទាន់ពេលវេលា
- ក្រុមអ្នកផ្តល់ព័ត៌មានដែលជាតំណាងគណៈកម្មការគ្រប់គ្រងសាលារៀន និងរដ្ឋបាលឃុំ សង្កាត់បានទទួលស្គាល់ថា ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកានៅតាមសាលារៀនកាន់តែត្រូវបានកែលម្អពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈការចូលរួមពីគណៈកម្មការ និងអ្នកពាក់ព័ន្ធនានា ព្រមទាំងការគាំទ្រ ការតាមដាន ត្រួតពិនិត្យដោយការិយាល័យអប់រំ យុវជន និងកីឡា និងថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក
- ក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធមួយចំនួនកត់សម្គាល់ឃើញថា ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់គាំទ្រមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលជាសកម្មភាពអប់រំក្រៅប្រព័ន្ធត្រូវបានអនុវត្តដូចស្ថានភាពមុនផ្ទេរមុខងារនេះឱ្យមករដ្ឋបាលក្រុង ស្រុកដែរ ដោយតម្រូវឱ្យរដ្ឋបាលក្រុង ស្រុកត្រូវបើកផ្តល់ និងផ្ទេរថវិកានេះទៅគណនីធនាគាររបស់គ្រូទទួលបន្ទុកលើការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍។

**ចំណុចអវិជ្ជមាន និងបញ្ហាប្រឈម៖**

- ការបើកផ្តល់ថវិកាសម្រាប់ឧបត្ថម្ភដល់គ្រូបង្រៀនជំនួស ឬថ្នាក់គួប រួមទាំងថវិកាលំហែរមាតុភាពសម្រាប់គ្រូជំនួសក៏ត្រូវបានលើកឡើងថាមានភាពយឺតយ៉ាវជាងមុន។ រដ្ឋបាលក្រុង ស្រុកមួយចំនួនមិនអាចបើកថវិកាទាំងនេះជូនគ្រូបង្រៀនជំនួសតែម្តង។ មានមូលហេតុជាច្រើនត្រូវបានលើកឡើង ដោយក្រុមអ្នកផ្តល់ព័ត៌មាន ដូចជា៖
  - រដ្ឋបាលក្រុង ស្រុកពុំទាន់ដឹងអំពីគោលការណ៍ និងនីតិវិធីសម្រាប់ស្នើសុំថវិកាទាំងនេះ
  - គោលការណ៍ និងនីតិវិធីមានភាពស្មុគស្មាញខ្លាំងដោយតម្រូវឱ្យមានការពិនិត្យ និងឯកភាពពីក្រសួងមុខងារសាធារណៈ។
- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់អនុវត្តសកម្មភាពអប់រំក្រៅប្រព័ន្ធត្រូវបានលើកឡើងថា មានភាពយឺតយ៉ាវខ្លាំងក្នុងការបើកប្រាក់ឧបត្ថម្ភជូនគ្រូបង្រៀនអប់រំក្រៅប្រព័ន្ធដែលត្រូវបានបើកផ្តល់ឱ្យម្តងក្នុង១ឆ្នាំ។ ភាពយឺតយ៉ាវនេះត្រូវបានលើកឡើងថាជាបញ្ហាដែលបានកើតឡើងតាំងពីមុនពេលផ្ទេរមុខងារនេះមករដ្ឋបាលក្រុង ស្រុក។

### ៧.២.៨. ការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិ

ផ្អែកតាមការស្ទង់មតិពីអ្នកពាក់ព័ន្ធចំនួន៣៩០ នាក់បានបង្ហាញឱ្យឃើញថា មតិ**៤៣%**យល់ឃើញថាមានស្ថានភាពល្អជាងមុន មតិ**៥៥%** យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ**២%**យល់ឃើញថាមានស្ថានភាពអន់ជាងមុន។




ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងសហគមន៍បានបង្ហាញឱ្យឃើញអំពីស្ថានភាពនៃការគ្រប់គ្រង ការប្រើប្រាស់ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារៈសម្រាប់អនុវត្តមុខងារដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុកដូចខាងក្រោម៖

**ចំណុចវិជ្ជមាន ៖**

- ទោះបីជាទ្រព្យសម្បត្តិពុំទាន់ត្រូវបានផ្ទេរជាផ្លូវការមកឱ្យរដ្ឋបាលក្រុង ស្រុកក៏ដោយ ក៏រដ្ឋបាលក្រុង ស្រុកមួយចំនួនបានរៀបចំឱ្យមានការចុះត្រួតពិនិត្យអគារ ឧបករណ៍ និងសម្ភារៈនៅតាមសាលារៀន និងការិយាល័យអប់រំ យុវជន និងកីឡា ព្រមទាំងបានណែនាំឱ្យការិយាល័យអប់រំ យុវជន និងកីឡាឱ្យរៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌនៅតាមសាលារៀន និងការិយាល័យអប់រំ យុវជន និងកីឡា
- ក្រុមអ្នកផ្តល់ព័ត៌មានភាគច្រើនបានលើកឡើងថា ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារៈសម្រាប់អនុវត្តមុខងារអប់រំមិនត្រូវបានយកទៅប្រើប្រាស់សម្រាប់សកម្មភាពផ្សេងក្រៅពីមុខងារអប់រំឡើយ
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានសង្កេតឃើញថា រដ្ឋបាលក្រុង ស្រុកមួយចំនួនបានសម្របសម្រួលជាមួយឃុំ សង្កាត់បានប្រើប្រាស់ថវិការបស់ខ្លួន និងបានកៀរគរធនធាននានា

សម្រាប់ការសាងសង់សាលារៀន ការជួសជុលសាលារៀន ការចាក់ដីបំពេញទីធ្លាសាលារៀន ឧបករណ៍ សម្ភារៈបន្ថែមសម្រាប់ផ្តល់ឱ្យការិយាល័យអប់រំ យុវជន និងកីឡា និងសាលារៀនផងដែរ រួមមានដូចជា កុំព្យូទ័រ តុ កៅអីសិស្ស និងសម្ភារៈផ្សេងទៀត។ ឧទាហរណ៍ជាក់ស្តែងដែលបានលើកឡើងរួមមាន ស្រុកថ្មគោលបានទិញតុសិស្សឱ្យសាលាបឋមសិក្សាតាម៉ឺន និងទិញកុំព្យូទ័រឱ្យការិយាល័យអប់រំ យុវជន និងកីឡា ស្រុកគាស់ក្រឡបានទិញកុំព្យូទ័រ និងម៉ាស៊ីនព្រីនឱ្យការិយាល័យអប់រំ យុវជន និងកីឡា ខេត្តមណ្ឌលបានទិញស៊ីម៉ងត៍សម្រាប់ជួសជុលការិយាល័យអប់រំ យុវជន និងកីឡា ក្រុងបាត់ដំបងបានទិញកុំព្យូទ័រ២គ្រឿងឱ្យការិយាល័យអប់រំ យុវជន និងកីឡា។

### ចំណុចអវិជ្ជមាន និងបញ្ហាប្រឈម៖

- ទ្រព្យសម្បត្តិដែលត្រូវផ្ទេរភ្ជាប់នឹងមុខងារក្នុងវិស័យអប់រំ ពុំទាន់ត្រូវបានផ្ទេរជាផ្លូវការឱ្យទៅរដ្ឋបាលក្រុង ស្រុកនៅឡើយ។ ភាពយឺតយ៉ាវនៃការផ្ទេរទ្រព្យសម្បត្តិទាំងនេះ បានធ្វើឱ្យរដ្ឋបាលក្រុង ស្រុកមិនទាន់មានភាពម្ចាស់ការច្បាស់លាស់ក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនេះប្រកបដោយការទទួលខុសត្រូវឱ្យបានពេញលេញនៅឡើយ
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានរាយការណ៍ថា ការិយាល័យអប់រំ យុវជន និងកីឡាមួយចំនួនពុំមានឧបករណ៍ និងសម្ភារគ្រប់គ្រាន់សម្រាប់បំពេញការងាររបស់ខ្លួន ដោយសារឧបករណ៍ និងសម្ភារៈមួយចំនួនបានប្រើប្រាស់អស់រយៈពេលយូរឆ្នាំមកហើយ ឧបករណ៍មួយចំនួនចាស់ៗ ហើយខូចប្រើប្រាស់លែងកើត ព្រមទាំងរដ្ឋបាលក្រុង ស្រុកមួយចំនួនពុំមានថវិកាសម្រាប់ទិញឧបករណ៍ថ្មីមកជំនួសឧបករណ៍ដែលប្រើប្រាស់លែងកើតទាំងនោះផងដែរ
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា មុនពេលផ្ទេរមុខងារមកឱ្យរដ្ឋបាលក្រុង ស្រុក ថវិកាសម្រាប់ទិញឧបករណ៍ សម្ភារៈនានាស្ថិតក្នុងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ហើយមន្ទីរអប់រំ យុវជន និងកីឡាខេត្តជាអ្នកផ្តល់ឧបករណ៍ សម្ភារៈជូនមកការិយាល័យអប់រំ យុវជន និងកីឡា។ បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ថវិកាសម្រាប់រ៉ាប់រងលើការទិញឧបករណ៍សម្ភារៈទាំងនេះក៏មិនត្រូវបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ហើយមន្ទីរអប់រំ យុវជន និងកីឡាខេត្តក៏លែងផ្តល់ឧបករណ៍ សម្ភារៈមកឱ្យការិយាល័យអប់រំ យុវជន និងកីឡា ដោយលើកហេតុផលថា ការិយាល័យអប់រំ យុវជន និងកីឡាពុំមែនជាអង្គភាពខ្សែបណ្តោយរបស់ខ្លួនទៀតឡើយ គឺបានក្លាយជាអង្គភាពរបស់រដ្ឋបាលក្រុង ស្រុក អាស្រ័យហេតុនេះមន្ទីរអប់រំ យុវជន និងកីឡាមានការលំបាកពាក់ព័ន្ធនឹងគោលការណ៍ និងនីតិវិធីនៃចុះបញ្ជីសារពើភណ្ឌដែលមិនអាចអនុញ្ញាតឱ្យមន្ទីរផ្តល់ឧបករណ៍ សម្ភារៈទៅឱ្យការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុកបានដូចពេលមុនទៀតឡើយ។

### ៧.២.៦. ទំនាក់ទំនងការងារ និងគណនេយ្យភាព

### ក. ទំនាក់ទំនងការងាររវាងរដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរអប់រំ យុវជន និងកីឡា

ផ្អែកតាមការស្ទង់មតិអំពីទំនាក់ទំនងការងារ និងការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្នុងចំណោម៣៩០នាក់បានបង្ហាញឱ្យឃើញថា៦៥% យល់ឃើញថាមានស្ថានភាពល្អជាងមុន មតិ៣២% យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ៣% យល់ឃើញថាមានស្ថានភាពអន់ជាងមុន។




ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងសហគមន៍បានបង្ហាញឱ្យឃើញអំពីស្ថានភាពនៃទំនាក់ទំនងការងារ និងការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរអប់រំ យុវជន និងកីឡាក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុកមានដូចខាងក្រោម៖

**ចំណុចវិជ្ជមាន៖**

- ស្ថានភាពនៃទំនាក់ទំនងការងារ និងគណនេយ្យភាពរវាងរដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្រូវបានលើកឡើងថាបានកែលម្អជាបណ្តើរៗទៅតាមការទទួលខុសត្រូវ និងខ្សែគណនេយ្យភាពក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ ដែលបានផ្ទេរមកឱ្យរដ្ឋបាលថ្នាក់រដ្ឋបាលក្រុង ស្រុក ដោយហេតុថា មន្ត្រីនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុកមានការយល់ដឹងកាន់តែច្បាស់អំពីទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពថ្មីដែលត្រូវអនុវត្តតាមគោលការណ៍វិមជ្ឈការ
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា ទោះបីការិយាល័យអប់រំ យុវជន និងកីឡាត្រូវធ្វើទំនាក់ទំនងការងារជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាមរយៈរដ្ឋបាលក្រុង ស្រុកដែលមានលក្ខណៈខុសពីពេលមុនក៏ដោយ ក៏ការិយាល័យអប់រំ យុវជន និងកីឡាបានសម្របសម្រួលជាមួយរដ្ឋបាលក្រុង ស្រុកក្នុងការឆ្លើយតបតាមតម្រូវការនានារបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តបានទាន់ពេលវេលា ដូចជា ការផ្តល់ទិន្នន័យពាក់ព័ន្ធនានា ការរៀបចំ និងធ្វើរបាយការណ៍ និងការងារផ្សេងៗជាដើម។

**ចំណុចអវិជ្ជមាន និងបញ្ហាប្រឈម៖**

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងអំពីបញ្ហាលំបាកចំពោះទំនាក់ទំនងការងារ និងការធ្វើគណនេយ្យភាពក្នុងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលក្រុង ស្រុកដែលពុំទាន់មានការបែងចែកតួនាទី ភារកិច្ច និងទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងរដ្ឋបាលក្រុង ស្រុក ជាមួយមន្ទីរអប់រំ យុវជន និងកីឡា ជាពិសេសលើមុខងារគាំទ្រដល់គ្រឹះស្ថានមធ្យមសិក្សា

- ក្រុមអ្នកផ្តល់ព័ត៌មានចំនួនបានលើកឡើងថា សកម្មភាពក្នុងវិស័យអប់រំមួយចំនួនដែលបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុករួចហើយ ក៏នៅតែត្រូវបានអនុវត្តដោយមន្ទីរអប់រំ យុវជន និងកីឡា ដោយពុំបានជូនដំណឹងមករដ្ឋបាលក្រុង ស្រុកឡើយ។ ករណីខ្លះត្រូវបានអនុវត្តជាន់គ្នា ឬមិនបានអនុវត្ត ដោយសារតែភាពមិនច្បាស់លាស់នៃការទទួលខុសត្រូវ និងការបែងចែកសមត្ថកិច្ចរវាងមន្ទីរអប់រំ យុវជន និងកីឡាជាមួយរដ្ឋបាលក្រុង ស្រុកលើការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្ម
- រដ្ឋបាលក្រុង ស្រុកបានលើកឡើងអំពីការលំបាកក្នុងការគ្រប់គ្រង ការចាត់ចែង ការអនុវត្តមុខងារអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ជាពិសេសការធ្វើទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដោយហេតុថា ពុំទាន់សេចក្តីណែនាំបច្ចេកទេស និងការបណ្តុះបណ្តាលអំពីគោលការណ៍ បែបបទ និងនីតិវិធីនៃការអនុវត្តមុខងារអប់រំដែលបានប្រគល់ និងធ្វើប្រតិភូកម្ម។

### ខ. គណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកជាមួយប្រជាពលរដ្ឋ

ការស្ទង់មតិអំពីការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកចំពោះប្រជាពលរដ្ឋក្នុងការអនុវត្តមុខងារអប់រំ ក្នុងចំណោមអ្នកពាក់ព័ន្ធ ២៤៦នាក់បានបង្ហាញឱ្យឃើញថា មានមតិ ៦៨% យល់ឃើញថាមានស្ថានភាពល្អជាងមុន មតិ២៩% យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ៣%យល់ឃើញថាមានស្ថានភាពអន់ជាងមុន។




ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងសហគមន៍បានបង្ហាញឱ្យឃើញអំពីស្ថានភាពនៃការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកចំពោះប្រជាពលរដ្ឋក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុករួមមានដូចខាងក្រោម៖

#### ចំណុចវិជ្ជមាន៖

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានកត់សម្គាល់ឃើញថា បន្ទាប់ពីការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ក្រុមប្រឹក្សាក្រុង ស្រុកបានចាប់ផ្តើមទទួលខុសត្រូវក្នុងភាពម្ចាស់ការលើការដឹកនាំ ការគ្រប់គ្រងមុខងារអប់រំ តាមរយៈការលើកយកបញ្ហានានាដែលពាក់ព័ន្ធនឹងការងារអប់រំមកពិនិត្យ ពិភាក្សា និងដោះស្រាយបញ្ហាក្នុងកិច្ចប្រជុំប្រចាំខែរបស់ខ្លួន និងបានដាក់ចេញនូវសេចក្តីសម្រេចចិត្តនានាក្នុងការគាំទ្រ ការតាមដានត្រួតពិនិត្យនិងដោះស្រាយលើការអនុវត្តការងារក្នុងវិស័យអប់រំ
- ក្រុមអ្នកផ្តល់ព័ត៌មានភាគច្រើនបានទទួលស្គាល់អំពីការផ្លាស់ប្តូរជាវិជ្ជមានរបស់រដ្ឋបាលក្រុង ស្រុកក្នុងការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះការអនុវត្តមុខងារអប់រំដែលបានប្រគល់មកឱ្យរដ្ឋបាលក្រុង ស្រុក ដោយហេតុថា បន្ទាប់ពីផ្តល់ការទទួលខុសត្រូវច្បាស់លាស់

មកឱ្យរដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រងមុខងារក្នុងវិស័យអប់រំ ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកសាមីនីមួយៗបានយកចិត្តទុកដាក់ប្រកបដោយភាពម្ចាស់ការលើការផ្តល់អន្តរាគមន៍ដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើងនៅតាមសាលារៀនដូចជា ការគ្រប់គ្រងសាលារៀន ការគ្រប់គ្រងវត្តមានគ្រូ ការគ្រប់គ្រងសិស្ស ការចាត់វិធានការការពារសុវត្ថិភាពការធ្វើដំណើររបស់សិស្សានុសិស្ស ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ បរិស្ថានក្នុងបរិវេណសាលារៀន ការសាងសង់ ការជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ទៅកាន់សាលារៀន ជាដើម

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា ក្នុងវេទិកាសាធារណៈនានា ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកតែងបានចូលរួមផ្សព្វផ្សាយ និងប្រមូលសំណើសំណូមពររបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានអំពីបញ្ហានានាពាក់ព័ន្ធនឹងសេវាអប់រំ។ ជាទូទៅ មានការកត់សម្គាល់ថា សំណើសំណូមពរនានាពាក់ព័ន្ធនឹងការងារអប់រំភាគច្រើនត្រូវបានរដ្ឋបាលក្រុង ស្រុកយកចិត្តទុកដាក់សម្របសម្រួលដោះស្រាយប្រកបដោយការទទួលខុសត្រូវបានឆាប់រហ័ស និងមានប្រសិទ្ធភាព
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានសង្កេតឃើញថា ក្រោមការដឹកនាំ និងសម្របសម្រួលរបស់រដ្ឋបាលក្រុង ស្រុកបានជំរុញឱ្យមានការចូលរួមពីរដ្ឋបាលឃុំ សង្កាត់ សហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិលក្នុងសកម្មភាពពាក់ព័ន្ធនឹងការងារអប់រំឱ្យកាន់តែមានភាពសកម្មផុលផុស។ ករណីជាច្រើនត្រូវបានលើកឡើងថា រដ្ឋបាលក្រុង ស្រុកបានសម្របសម្រួល ពិគ្រោះយោបល់ និងកៀរគរធនធាននានាពីស្ថាប័ន សប្បុរសជន អង្គការសង្គមស៊ីវិល មាតាបិតាសិស្សដើម្បីចូលរួមអភិវឌ្ឍសាលារៀន ដូចជា ការសាងសង់ ការជួសជុលសាលារៀន ការរៀបចំសួនច្បារ ការចាក់ដីបំពេញទីធ្លាសាលាដែលលិចទឹក ការជួសជុល និងសាងសង់របង ការរៀបចំបន្ទប់អនាម័យ និងដងទង់ជាតិ ការសាងសង់ និងការជួសជុលផ្លូវទៅកាន់សាលារៀន ការផ្តល់សម្ភារៈឧបករណ៍ជាដើម។ ឧទាហរណ៍ជាក់ស្តែងមួយចំនួនដែលបានលើកឡើងពាក់ព័ន្ធនឹងការកៀរគរធនធាននេះ រួមមានដូចជាស្រុកគាស់ក្រឡបានកៀរគរអង្គការដៃគូ និងសប្បុរសជនដើម្បីកសាងសាលាចំនួន៩សាលា ស្មើ១២ខ្នង និងផ្ទះសំណាក់គ្រូ ១ខ្នង ស្រុកបវេលបានកសាងសាលា៨ខ្នង និងបន្ទប់អនាម័យចំនួន៨បន្ទប់ ស្រុកថ្មគោលបានកៀរគរថវិកាសរុបជាង ២០ម៉ឺនដុល្លារ ស្រុកកំរៀងបានប្រើប្រាស់មូលនិធិឃុំសាងសង់សាលារៀនបាន៣បន្ទប់ ស្រុករតនមណ្ឌលបានកៀរគរសប្បុរសជនគិតជាទឹកប្រាក់ជាង១៥ម៉ឺនដុល្លារ ដើម្បីកសាងសាលា ៤ខ្នង ជាដើម
- រដ្ឋបាលក្រុង ស្រុកមួយចំនួនបានសម្របសម្រួល សហការជាមួយអង្គការសង្គមស៊ីវិលក្នុងការរៀបចំ និងអនុវត្តកម្មវិធីផ្តល់អាហារពេលព្រឹកនៅតាមសាលារៀនមួយចំនួនក្នុងគោលបំណងជួយឱ្យកូនសិស្សមកចូលរៀនបានទៀងទាត់ និងចំនួនសិស្សដែលមករៀនមានការកើនឡើង
- រដ្ឋបាលក្រុង ស្រុកមួយចំនួន ក្រៅពីប្រើប្រាស់យន្តការគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ក៏បានបង្កើតគណៈកម្មការផ្សេងទៀតដើម្បីជួយជំរុញ គាំទ្រ និងលើកកម្ពស់សេវាអប់រំនៅតាមសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ព្រមទាំង

បានចាត់វិធានការជំរុញ និងគាំទ្រដល់កុមារដែលគ្រប់អាយុ និងកុមារដែលបានបោះបង់ចោលការសិក្សាឱ្យចូលរៀន




- រដ្ឋបាលក្រុង ស្រុកខ្លះក៏បានរៀបចំ និងដាក់ឱ្យអនុវត្តនូវដីកាស្តីពីការធានាសុវត្ថិភាពចំណីអាហារនៅតាមសាលារៀននានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីលើកកម្ពស់សុខភាពសិស្សានុសិស្ស។

**ចំណុចអវិជ្ជមាន និងបញ្ហាប្រឈម៖**

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា ទោះបីរដ្ឋបាលក្រុង ស្រុកបានខិតខំ ប្រឹងប្រែង សហការជាមួយរដ្ឋបាលឃុំ សង្កាត់ សហគមន៍មូលដ្ឋាន មាតាបិតាសិស្សក្នុងការធានាសុវត្ថិភាពនៅតាមសាលារៀនក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តដោះស្រាយ ដូចជា សកម្មភាពក្មេងប្រើប្រាស់គ្រឿងញៀននៅក្បែរសាលារៀន ដែលអាចបង្កឱ្យមានការភ័យខ្លាច និងព្រួយបារម្ភណ៍របស់សិស្ស និងមាតាបិតាសិស្ស។ ជារួម បញ្ហាប្រឈមទាំងនេះត្រូវបានដោះស្រាយជាបណ្តើរៗ ហើយរហូតដល់ឆ្នាំ២០២២សកម្មភាពនៃការប្រើប្រាស់គ្រឿងញៀននៅក្បែរសាលារៀនត្រូវបានទប់ស្កាត់ និងលុបបំបាត់ស្ទើរតែទាំងស្រុង
- រដ្ឋបាលក្រុង ស្រុកមានលទ្ធភាពតិចតួចក្នុងការប្រើប្រាស់ថវិកាសម្រាប់គាំទ្របន្ថែមលើការជំរុញ និងលើកកម្ពស់ការអនុវត្តមុខងារអប់រំដែលបានផ្ទេរឱ្យ ដោយសារថវិកាធន្ទានុសិទ្ធិរបស់រដ្ឋបាលក្រុង ស្រុកនៅមានកម្រិត។

## ៧.៣.លទ្ធផលនៃការរកឃើញនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងខេត្តក្រចេះ និងខេត្តកំពត ÷

### ៧.៣.១. ការគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡា

ផ្អែកតាមព័ត៌មានដែលទទួលបានពីការស្ទង់មតិយោបល់ និងការយល់ឃើញអំពីកម្រិតនៃភាពពេញចិត្តចំពោះការធ្វើសមាហរណកម្មការិយាល័យអបរំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុកដើម្បីធ្វើជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុកបានបង្ហាញឱ្យឃើញថា ក្នុងចំណោមមន្ត្រីថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក និងមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡា ចំនួន១៤៦នាក់ មានមតិចំនួន៣៤%យល់ថាពេញចិត្តខ្លាំង មតិចំនួន៥១%យល់ថាពេញចិត្តធម្មតា និងមតិចំនួន១៥%យល់ថា ពុំពេញចិត្ត។

ផ្អែកតាមព័ត៌មានដែលទទួលបានពីការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានា ទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុកបានបង្ហាញឱ្យឃើញនូវចំណុចវិជ្ជមាន និងបញ្ហាប្រឈមនៃស្ថានភាពគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡាដូចខាងក្រោម៖

**ចំណុចវិជ្ជមាន៖**

- ក្រុមអ្នកផ្តល់ព័ត៌មានភាគច្រើនបានលើកឡើងថា បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុកបានធ្វើឱ្យរដ្ឋបាល ក្រុង ស្រុកងាយស្រួលក្នុងការដឹកនាំ គ្រប់គ្រង និងមានទំនាក់ទំនងការងារកាន់តែជិតស្និទ្ធជាមួយមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡា
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា រដ្ឋបាលក្រុង ស្រុកមានបែបបទ នីតិវិធីរដ្ឋបាល និងចរន្ត ឬលំហូរឯកសាររដ្ឋបាល និងមានរបបប្រជុំច្បាស់លាស់។ មន្ត្រីថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា និងប្រជុំនានារបស់រដ្ឋបាលក្រុង ស្រុកជាទៀងទាត់។ តាមរយៈការចូលរួមកិច្ចប្រជុំទាំងនេះ បានផ្តល់ឱកាសឱ្យមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡាអាចធ្វើសេចក្តីរាយការណ៍ និងលើកឡើងនូវបញ្ហាប្រឈមនានាក្នុងវិស័យអប់រំជូនថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ដើម្បីផ្តល់អន្តរាគមន៍ដោះស្រាយបានលឿន និងឆាប់រហ័ស ដោយសារពេលផ្ទេរមុខងារអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ការិយាល័យអប់រំ យុវជន និងកីឡាត្រូវរាយការណ៍ និងសុំការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តដែលនៅឆ្ងាយជាងរដ្ឋបាលក្រុង ស្រុក
- រដ្ឋបាលក្រុង ស្រុកនីមួយៗបានចាត់តាំងឱ្យអភិបាលរងម្នាក់ទទួលបន្ទុកការងារអប់រំ។ ប្រការនេះបានធ្វើឱ្យការដឹកនាំ ការគ្រប់គ្រង និងការអនុវត្តការងារអប់រំកាន់តែមានភាពល្អប្រសើរដោយថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុកអាចក្តាប់បានច្បាស់អំពីស្ថានភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការងារអប់រំ បញ្ហាប្រឈម និងសំណើសំណូមពរនានាដែលត្រូវបន្តដោះស្រាយ។

**ចំណុចអវិជ្ជមាន និងបញ្ហាប្រឈម៖**

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា ក្នុងឆ្នាំដំបូងៗបន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាបានជួបប្រទះការលំបាកក្នុងការបំពេញការងាររបស់ខ្លួន ជាពិសេសពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាល ដូចជា ការរៀបចំលិខិតស្នាមពុំទាន់មានឯកភាពគ្នាអំពីទម្រង់នៃឯកសាររដ្ឋបាល ការពុំទាន់យល់ដឹងអំពីចរន្ត ឬលំហូរឯកសាររបស់រដ្ឋបាលក្រុង ស្រុក ភាពប្រទាំងប្រទើសក្នុងការប្រើប្រាស់ត្រា ដោយសារមុនការធ្វើសមាហរណកម្ម ការិយាល័យអប់រំ យុវជន និងកីឡាមានសិទ្ធិប្រើប្រាស់ត្រារបស់ខ្លួន តែក្រោយសមាហរណកម្មត្រារបស់ការិយាល័យអប់រំ យុវជន និងកីឡាពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ទៀតឡើយ។ ប្រការទាំងនេះបានធ្វើឱ្យការអនុវត្តការងារមួយចំនួនមានការលំបាក និងមានភាពយឺតយ៉ាវ។ ទោះយ៉ាងនេះក្តី មកដល់ពេលនេះ បញ្ហាទាំងនេះត្រូវបានសម្របសម្រួល និងដោះស្រាយជាបណ្តើរៗ និងធ្វើ

ឱ្យចរន្តការងាររដ្ឋបាលមានស្ថានភាពល្អជាងមុន

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា រដ្ឋបាលក្រុង ស្រុកពុំបានផ្តល់ការបណ្តុះបណ្តាលអំពីទំនាក់ទំនងការងារ បែបបទ នីតិវិធីគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុកដល់បុគ្គលិក ដែលបានផ្ទេរមកឱ្យមានការយល់ដឹងច្បាស់លាស់ឡើយ អាស្រ័យហេតុនេះ ការរៀបចំលិខិតស្នាមនានានៅជួបការលំបាក ដោយត្រូវពិនិត្យ និងកែតម្រូវទៅវិញទៅមកច្រើនលើកច្រើនសារ និងប្រើប្រាស់ពេលវេលាយូរ
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា បន្ទាប់ការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក បុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡាទទួលបានការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡាតិចជាងមុន ព្រមទាំងពុំទទួលបានការគាំទ្រច្រើនគ្រប់គ្រាន់ពីរដ្ឋបាលក្រុង ស្រុកផងដែរ ដោយសារតែមន្ទីរអប់រំ យុវជន និងកីឡាខេត្តយល់ថា ការិយាល័យអប់រំ យុវជន និងកីឡាមិនមែនជាអង្គភាពខ្សែបណ្តោយរបស់ខ្លួនទៀតឡើយ ហើយរដ្ឋបាលក្រុង ស្រុកពុំទាន់មានការយល់ដឹងច្បាស់អំពីគោលការណ៍ នីតិវិធី និងស្តង់ដានៃការដឹកនាំ និងគ្រប់គ្រងការងារក្នុងវិស័យអប់រំ និងដោយគិតថា ការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក គឺជាតួនាទី និងការទទួលខុសត្រូវរបស់ការិយាល័យអប់រំ យុវជន និងកីឡា
- ផ្អែកតាមការពិភាក្សាក្នុងសិក្ខាសាលាពិគ្រោះយោបល់បានបង្ហាញថា ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួនបានប្រគល់ការងារឱ្យបុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡាបំពេញការងារផ្សេងខុសពីការងារអប់រំ ដូចជាការងារគ្រប់គ្រងបុគ្គលិក ការងាររដ្ឋបាល និងការចូលរួមលើការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៅតាមមូលដ្ឋាន ជាពិសេសនៅតាមរដ្ឋបាលខណ្ឌក្នុងរាជធានីភ្នំពេញ ដែលបានធ្វើឱ្យបុគ្គលិកទាំងនេះមិនអាចបំពេញការងារអប់រំបានពេញលេញ។

### ៧.៣.២.ការគ្រប់គ្រងនៅតាមសាលារៀន

ផ្អែកតាមព័ត៌មានដែលទទួលបានពីការស្ទង់មតិយោបល់ក្នុងចំណោមអ្នកពាក់ព័ន្ធចំនួន៣០៥នាក់បានបង្ហាញឱ្យឃើញថាមតិចំនួន**៥៥%**បានយល់ឃើញថាស្ថានភាពទូទៅនៅតាមសាលារៀន**មានភាពល្អជាងមុន** មតិ**៣៩%**បានយល់ឃើញថាមានស្ថានភាពល្អដូចពេលមុន និងមតិ**៦%**បានយល់ថាមានស្ថានភាពមិនល្អជាងមុន។




ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ថ្នាក់ឃុំ សង្កាត់ និងសហគមន៍បានបង្ហាញឱ្យឃើញថាស្ថានភាពគ្រប់គ្រងជាទូទៅនៅសាលារៀនមានការប្រែប្រួលដូចខាងក្រោម៖

**ចំណុចវិជ្ជមាន៖**

- បន្ទាប់ពីការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យអប់រំ ក្រុមប្រឹក្សាក្រុង ស្រុកមួយចំនួនត្រូវបានរាយការណ៍ថា បានលើកយកបញ្ហាក្នុងវិស័យអប់រំមកពិភាក្សាក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាបានញឹកញាប់ ដោយសារក្រុមប្រឹក្សាក្រុង ស្រុកយល់ឃើញថា ការងារអប់រំបច្ចុប្បន្នគឺស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អាស្រ័យហេតុនេះ ក្រុមប្រឹក្សាក្រុង ស្រុកត្រូវតែដឹង និងត្រូវតែជួយជំរុញការងារអប់រំទាំងនេះ
- ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុកមួយចំនួនបានចុះផ្តល់ការណែនាំ និងជំរុញឱ្យមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាចុះត្រួតពិនិត្យ ទប់ស្កាត់ និងបញ្ឈប់សកម្មភាពមិនស្របច្បាប់នានារបស់គ្រូបង្រៀននៅតាមសាលារៀន ដូចជា ការលក់ដូរចំណីក្នុងថ្នាក់រៀន និងការបង្រៀនគួរក្នុងម៉ោង និងក្នុងសាលារៀនសាធារណៈដើម្បីយកកម្រៃផ្ទាល់ខ្លួន ជាដើម
- ក្រុមប្រឹក្សានៃរដ្ឋបាលក្រុង ស្រុកមួយចំនួនបានយកចិត្តទុកដាក់ជាងមុនលើការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន (រោងចក្រ) ក្នុងការរៀបចំឱ្យកុមារដែលជាកូនចៅរបស់កម្មករនៅតាមតំបន់ឆ្ងាយឱ្យមានឱកាសបានចូលរៀនត្រឹមត្រូវដូចតំបន់ផ្សេងទៀត
- រដ្ឋបាលក្រុង ស្រុកមួយចំនួនបានសហការជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងការផ្តល់អន្តរាគមន៍តាមការស្នើសុំរបស់ការិយាល័យអប់រំ យុវជន និងកីឡា និងនាយកសាលានានាក្នុងការសម្របសម្រួលចរាចរណ៍ពេលសិស្សចូល និងចេញពីសាលារៀន (ម្តងម្កាលមិនជាប្រចាំឡើយ)។
- រដ្ឋបាលក្រុង ស្រុកមួយចំនួនត្រូវបានរាយការណ៍ថា បានសម្របសម្រួលកៀរគរការគាំទ្រពីសប្បុរសជន អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍតាមសាលារៀនដែលនៅតំបន់ដាច់ស្រយ៉ាលមួយចំនួនផងដែរ។

**ចំណុចអវិជ្ជមាន និងបញ្ហាប្រឈម៖**

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា ស្ថានភាពគ្រប់គ្រងនៅតាមសាលារៀនហាក់នៅដដែល ឬមានស្ថានភាពគួរឱ្យព្រួយបារម្ភ ជាពិសេសពាក់ព័ន្ធនឹងការងារសន្តិសុខ សកម្មភាពក្មេងប្រើប្រាស់ថ្នាំញៀនក្បែរៗសាលារៀន ការលួច និងបំផ្លាញទ្រព្យសម្បត្តិសាលារៀនជាដើម ដោយសារថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុកពុំបានផ្តល់អន្តរាគមន៍គាំទ្រ ឬចាត់វិធានការការពារ ទប់ស្កាត់ឱ្យបានដិតដល់នៅឡើយ គឺពឹងផ្អែកទៅលើការិយាល័យអប់រំ យុវជន និងកីឡា។ ប្រការនេះធ្វើឱ្យនាយកសាលា និងគ្រូបង្រៀននៅតាមសាលារៀនហាក់បាត់បង់នូវភាពកក់ក្តៅ ឬជំនឿទុកចិត្តទាំងមកលើរដ្ឋបាលក្រុង ស្រុក និងទៅលើមន្ទីរអប់រំ យុវជន និងកីឡាខេត្តផងដែរ។ មូលហេតុដែលធ្វើឱ្យមានបញ្ហាប្រឈមបែបនេះកើតឡើង គឺដោយសារសាលារៀន និងគ្រូបម្រើការងារនៅតាមសាលារៀនពុំត្រូវបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុកឡើយ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដែលក្នុងករណីនេះ រដ្ឋបាលក្រុង ស្រុកពុំទាន់បានផ្តោតការយកចិត្តទុកដាក់ឱ្យបានដិតដល់ក្នុងការដោះស្រាយបញ្ហាប្រឈមនានានៅតាមសាលារៀន រីឯមន្ទីរអប់រំ យុវជន និងកីឡាខេត្តក៏ជួបការលំបាកក្នុងការផ្តល់ការគាំទ្រផ្ទាល់មកសាលារៀនដូចពេលមុន ដោយសារតែ

ការិយាល័យអប់រំ យុវជន និងកីឡាលែងស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា រដ្ឋបាលក្រុង ស្រុកទទួលយកសំណើ សំណូមពរពីការិយាល័យអប់រំ យុវជន និងកីឡា និងពីនាយកសាលារៀន ក៏ប៉ុន្តែជាទូទៅពុំបានផ្តល់អន្តរាគមន៍ដោះស្រាយទាន់ពេលវេលា ហើយករណីភាគច្រើនបានស្នើឱ្យរដ្ឋបាលឃុំ សង្កាត់ផ្តល់អន្តរាគមន៍ដោះស្រាយជំនួស ឬស្នើឱ្យនាយកសាលារៀនចាត់ចែងការងារយាមកាមដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់នៅតាមសាលារៀនដោយខ្លួនឯង
- ជាទូទៅ ស្ថានភាពគ្រប់គ្រងនៅតាមសាលារៀនត្រូវបានលើកឡើងថា ពុំត្រូវបានយកចិត្តទុកដាក់ និងការគាំទ្រឱ្យបានជិតដល់ពីរដ្ឋបាលក្រុង ស្រុក និងពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដោយសារការផ្ទេរមុខងារក្នុងវិស័យអប់រំនេះមកឱ្យរដ្ឋបាលក្រុង ស្រុកពុំបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវពេលលេញមកឱ្យរដ្ឋបាលក្រុង ស្រុក។

### ៧.៣.៣. ការគ្រប់គ្រងបុគ្គលិកអប់រំ

#### ក. ការគ្រប់គ្រងបុគ្គលិកអប់រំដែលបម្រើការងារក្នុងការិយាល័យអប់រំ យុវជន និងកីឡា

ចំពោះស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកដែលបម្រើការងារក្នុងការិយាល័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលក្រុង ស្រុក ផ្អែកតាមការស្ទង់មតិពីអ្នកពាក់ព័ន្ធចំនួន **១៧០នាក់**បានបង្ហាញឱ្យឃើញថា មតិ៤៨% យល់ឃើញថាល្អជាងមុន មតិ៤៦%យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ៦% យល់ឃើញថាអន់ជាងមុន។




លទ្ធផលនៃការស្ទង់មតិអំពីស្ថានភាពពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកអប់រំដែលបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកតាមសកម្មភាពសំខាន់ៗនៃការគ្រប់គ្រងបុគ្គលិកមានបង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ចំនួនអ្នកផ្តល់ព័ត៌មាន | ការយល់ឃើញ | | |
|---|---|---|---|---|---|
| | | | ល្អជាងមុន | ដូចមុន | អន់ជាងមុន |
| ១ | ការតែងតាំង | 177 | 97 (55%) | 61 (34%) | 19 (11%) |
| ២ | ការដំឡើងថ្នាក់/ឋានន្តរស័ក្តិ | 177 | 101 (57%) | 70 (40%) | 6 (3%) |
| ៣ | ការផ្លាស់ប្តូរ | 176 | 71 (40%) | 90 (51%) | 15 (9%) |
| ៤ | ការចូលនិវត្តន៍ | 178 | 73 (41%) | 101 (57%) | 4 (2%) |
| ៥ | ការគ្រប់គ្រងវត្តមានបុគ្គលិក | 177 | 81 (46%) | 90 (51%) | 6 (3%) |

#### ខ. ការគ្រប់គ្រងបុគ្គលិកអប់រំ និងគ្រូបង្រៀនដែលបម្រើការងារនៅតាមសាលារៀនដែលពុំបានផ្ទេរមកជាបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក

ចំពោះស្ថានភាពនៃការគ្រប់គ្រងបុគ្គលិក និងគ្រូបង្រៀនដែលបម្រើការងារនៅតាមសាលារៀន ផ្អែកតាមការស្ទង់មតិពីអ្នកពាក់ព័ន្ធចំនួនជាង**៣០០នាក់**បានបង្ហាញឱ្យឃើញថា មតិ**៤៥%**យល់ឃើញថាល្អជាងមុន មតិ**៥១%**យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ៤% យល់ឃើញថាអន់ជាងមុន។




លទ្ធផលនៃការស្ទង់មតិអំពីស្ថានភាពពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រូបង្រៀនបម្រើការងារតាមសាលារៀនដែលពុំទាន់បានផ្ទេរមកជាបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក តាមសកម្មភាពសំខាន់ៗនៃការគ្រប់គ្រងបុគ្គលិកមានបង្ហាញក្នុងតារាងខាងក្រោម៖

| ល. | សកម្មភាព | ចំនួនអ្នកផ្តល់ព័ត៌មាន | ការយល់ឃើញ | | |
|---|---|---|---|---|---|
| | | | ល្អជាងមុន | ដូចមុន | អន់ជាងមុន |
| ១ | ការតែងតាំង | 262 | 127 (48%) | 118 (45%) | 17 (6%) |
| ២ | ការដំឡើងថ្នាក់/ឋានន្តរស័ក្តិ | 267 | 129 (48%) | 131 (49%) | 7 (3%) |
| ៣ | ការផ្លាស់ប្តូរ | 262 | 98 (37%) | 153 (58%) | 11 (4%) |
| ៤ | ការចូលនិវត្តន៍ | 262 | 113 (43%) | 142 (54%) | 7 (3%) |
| ៥ | ការគ្រប់គ្រងវត្តមានបុគ្គលិក | 305 | 146 (48%) | 147 (48%) | 12 (4%) |

ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ថ្នាក់ឃុំ សង្កាត់ និងសហគមន៍បានបង្ហាញឱ្យឃើញថាស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំដែលបម្រើការងារក្នុងការិយាល័យអប់រំ យុវជន និងកីឡា និងបុគ្គលិក គ្រូបង្រៀនដែលបម្រើការងារនៅតាមសាលារៀនមានសង្ខេបដូចខាងក្រោម៖

**ចំណុចវិជ្ជមាន៖**

- ក្រុមអ្នកផ្តល់ព័ត៌មានភាគច្រើនបានទទួលស្គាល់ថា ការគ្រប់គ្រងបុគ្គលិកនៃការិយាល័យអប់រំ យុវជន និងកីឡា ជាទូទៅ មានលក្ខណៈល្អប្រសើរ មានប្រសិទ្ធភាព និងឆាប់រហ័ស ដោយសាររដ្ឋបាលក្រុង ស្រុកមានគោលការណ៍ និងនីតិវិធីគ្រប់គ្រងបុគ្គលិករបស់ខ្លួន ប្រកបដោយភាពងាយស្រួល និងឆាប់រហ័ស ហើយការសម្រេចនានាត្រូវធ្វើឡើងនៅថ្នាក់ក្រុង ស្រុកតែម្តងដោយពុំចាំបាច់បញ្ជូនឯកសារទៅថ្នាក់ខេត្ត និងថ្នាក់ក្រសួងដើម្បីធ្វើការសម្រេចដូចពេលមុនឡើយ។
- ចំពោះការគ្រប់គ្រងបុគ្គលិកអប់រំ ជាពិសេសគ្រូបង្រៀននៅតាមសាលារៀនត្រូវបានរាយការណ៍ថាពុំមានស្ថានភាពប្រែប្រួល ដោយសារតែបុគ្គលិកទាំងនេះពុំទាន់ត្រូវបានផ្ទេរមកជា

បុគ្គលិករបស់រដ្ឋបាលក្រុង ស្រុកនៅឡើយ គឺនៅជាបុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡាដដែល។

**ចំណុចអវិជ្ជមាន និងបញ្ហាប្រឈម៖**

- ការខ្វះបុគ្គលិកបម្រើការងារក្នុងការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានលើកឡើងស្ទើរគ្រប់រដ្ឋបាលក្រុង ស្រុកទាំងអស់ដែលក្រុមការងារបានចុះទៅសិក្សា ថាជាបញ្ហាប្រឈមខ្លាំង។ ការខ្វះបុគ្គលិកអប់រំនេះអាចបណ្តាលមកពីមូលហេតុមួយចំនួន រួមមានដូចជា៖
  - ការចូលនិវត្តន៍របស់បុគ្គលិកអប់រំ និងការជ្រើសរើសបុគ្គលិកជំនួសពុំគ្រប់តាមចំនួនត្រូវការ
  - រដ្ឋបាលក្រុង ស្រុកមួយចំនួនបានតែងតាំង ឬចាត់តាំងបុគ្គលិកអប់រំមួយចំនួនឱ្យទៅបម្រើការងារនៅការិយាល័យ និងអង្គភាពផ្សេងក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ដែលមានតម្រូវការបុគ្គលិកជាចាំបាច់
  - ការណែនាំពីថ្នាក់ជាតិឱ្យរដ្ឋបាលក្រុង ស្រុកផ្អាកការផ្លាស់ប្តូរ ឬការផ្ទេរបុគ្គលិកអប់រំទៅបម្រើការងារនៅក្រៅរដ្ឋបាលក្រុង ស្រុកសាមីនីមួយៗ
- បញ្ហាខ្វះបុគ្គលិកត្រូវបានរាយការណ៍ជូនអភិបាលក្រុង ស្រុកតែគ្មានដំណោះស្រាយ ដោយសាររដ្ឋបាលក្រុង ស្រុកពុំមានសិទ្ធិក្នុងការជ្រើសរើសបុគ្គលិកអប់រំ
- រដ្ឋបាលក្រុង ស្រុកមួយចំនួនបានផ្លាស់ប្តូរបុគ្គលិកអប់រំពីការិយាល័យអប់រំ យុវជន និងកីឡាទៅបម្រើការងារនៅការិយាល័យផ្សេង ដោយពុំបានពិគ្រោះយោបល់ជាមួយប្រធានការិយាល័យអប់រំ យុវជន និងកីឡា
- ការតែងតាំងនាយកសាលា និងការរៀបចំដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការផ្លាស់ប្តូរ ការដាក់ឱ្យចូលនិវត្តដល់បុគ្គលិក និងគ្រូបង្រៀនបម្រើការងារតាមសាលារៀនមួយចំនួន ត្រូវបានលើឡើងថាមានការយឺតយ៉ាវខ្លាំង ហើយបញ្ហាប្រឈមនេះបានកើតឡើងតាំងពីមុនពេលផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

### ៧.៣.៤. ការគ្រប់គ្រង និងការប្រើប្រាស់ថវិកា

#### ក. ស្ថានភាពនៃការគ្រប់គ្រងថវិកាគាំទ្រការិយាល័យអប់រំ យុវជន និងកីឡា




ផ្អែកតាមការស្ទង់មតិពីអ្នកពាក់ព័ន្ធចំនួន **១៧៧**នាក់បានបង្ហាញឱ្យឃើញថា មតិ**៣៣%** យល់ឃើញថាមានស្ថានភាពល្អជាងមុន មតិ**៣២%**យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ**៣៥%**យល់ឃើញថាអន់ជាងមុន។

ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងសហគមន៍ បានបង្ហាញឱ្យឃើញអំពី

ស្ថានភាពនៃការគ្រប់គ្រង ការប្រើប្រាស់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុកមានសង្ខេបដូចខាងក្រោម៖

**ចំណុចវិជ្ជមាន៖**

- ក្រុមអ្នកផ្ដល់ព័ត៌មានមួយចំនួនបានលើកឡើងថា ការគ្រប់គ្រង និងការប្រើប្រាស់កញ្ចប់ថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាបច្ចុប្បន្នមានតម្លាភាព និងគណនេយ្យភាព ដោយសារថវិកានេះត្រូវបានដាក់ឱ្យអនុវត្តតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ដែលបង្កលក្ខណៈងាយស្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រង ការចាត់ចែង ការប្រើប្រាស់ ការតាមដាន និងការត្រួតពិនិត្យ។
- ក្រុមអ្នកផ្ដល់ព័ត៌មានមួយចំនួនបានលើកឡើងថា រដ្ឋបាលក្រុង ស្រុកបានផ្ដល់អាទិភាពក្នុងការបើកផ្ដល់ថវិកាបុរេប្រទាន និងសម្ភារៈនានាឱ្យការិយាល័យអប់រំ យុវជន និងកីឡាតាមការស្នើសុំរបស់ការិយាល័យអប់រំ យុវជន និងកីឡាដើម្បីធានាឱ្យការិយាល័យអប់រំ យុវជន និងកីឡាមានថវិកា និងសម្ភារៈសមស្របសម្រាប់អនុវត្តភារកិច្ចរបស់ខ្លួន
- ក្រុមអ្នកផ្ដល់ព័ត៌មានមួយចំនួនបានកត់សម្គាល់ឃើញថា រដ្ឋបាលក្រុង ស្រុកមួយចំនួនបានប្រើប្រាស់ថវិកាឆន្ទានុសិទ្ធិរបស់រដ្ឋបាលក្រុង ស្រុកដើម្បីគាំទ្របន្ថែមដល់ការអនុវត្តសកម្មភាពក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក រួមមានដូចជាការផ្ដល់ប្រាក់បេសកកម្មដល់បុគ្គលិកអប់រំដែលត្រូវទៅបំពេញបេសកកម្មចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងព្រឹត្តិការណ៍ពាក់ព័ន្ធនានានៅក្រៅរដ្ឋបាលក្រុង ស្រុកជាដើម។ ជាមួយគ្នានេះ រដ្ឋបាលក្រុង ស្រុកមួយចំនួនក៏បានបែងចែកប្រាក់រង្វាន់លើកទឹកចិត្តពីការផ្ដល់សេវានានារបស់រដ្ឋបាលក្រុង ស្រុកជូនដល់បុគ្គលិកអប់រំបម្រើការងារក្នុងការិយាល័យអប់រំ យុវជន និងកីឡាផងដែរ។
- ក្រុមអ្នកផ្ដល់ព័ត៌មានមួយចំនួនបានលើកឡើងថា ក្នុងកិច្ចដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុតែងតែសហការជាមួយបុគ្គលិកទទួលបន្ទុកហិរញ្ញវត្ថុនៃការិយាល័យអប់រំ យុវជន និងកីឡាក្នុងការរៀបចំគម្រោងថវិកាសម្រាប់គាំទ្រដល់ការអនុវត្តមុខងារក្នុងវិស័យអប់រំដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក។

**ចំណុចអវិជ្ជមាន និងបញ្ហាប្រឈម៖**

- ការអនុវត្តថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡា តាមប្រព័ន្ធនិងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានលើកឡើងថា មានការលំបាក និងមានភាពយឺតយ៉ាវជាងមុន ដោយហេតុថា មុនពេលផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានអនុវត្តតាមការផ្ដល់រជ្ជទេយ្យបុរេប្រទានទាំងអស់(១០០%)ពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តមកគណនីរបស់ការិយាល័យអប់រំ យុវជន និងកីឡាត្រង់តែម្ដង (បុរេប្រទាន១ឆមាសម្ដង) ហើយការិយាល័យអប់រំ យុវជន និងកីឡាជាអ្នកប្រើប្រាស់រជ្ជទេយ្យបុរេប្រទានទាំងនេះដោយខ្លួនឯង

ផ្ទាល់សម្រាប់ចំណាយលើមុខចំណាយនានា (បេសកកម្ម សម្ភារៈការិយាល័យ ការជួសជុលតូចតាច និងប្រតិបត្តិការរដ្ឋបាល) តាមការកំណត់ ដោយពុំចាំបាច់ស្នើសុំការទូទាត់ទៅរតនាគារ និងធ្វើកិច្ចលទ្ធកម្មឡើយ។ ប្រការនេះបានបង្កលក្ខណៈងាយស្រួលដល់ការិយាល័យអប់រំ យុវជន និងកីឡាដកថវិកានេះយកមកប្រើប្រាស់តាមតម្រូវការបានភ្លាមៗ។ បន្ទាប់ពីការផ្ទេរមុខងារអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡា ត្រូវបានដាក់បញ្ចូលក្នុងថវិការួមរបស់រដ្ឋបាលក្រុង ស្រុក ហើយត្រូវអនុវត្តតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ដែលក្នុងនោះ ថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាចំនួន៣០%ត្រូវបានបើកផ្តល់ពីរតនាគារខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុកតាមរយៈរដ្ឋទេយ្យបុរេប្រទាន។ បន្ទាប់មក រដ្ឋបាលក្រុង ស្រុកត្រូវបន្តបើកផ្តល់រដ្ឋទេយ្យបុរេប្រទាននេះជូនការិយាល័យអប់រំ យុវជន និងកីឡាសម្រាប់ប្រើប្រាស់លើចំណាយដំណើរការរដ្ឋបាលតិចតួចតាមការកំណត់។ ថវិកាគាំទ្រប្រតិបត្តិការរបស់ការិយាល័យអប់រំ យុវជន និងកីឡាចំនួន៧០% ត្រូវអនុវត្តតាមនីតិវិធីទូទាត់ត្រង់ពីរតនាគារខេត្ត រួមមានថវិកាសម្រាប់បេសកកម្ម និងសម្រាប់ការទិញឧបករណ៍ សម្ភារៈនានាតាមរយៈកិច្ចលទ្ធកម្មសាធារណៈ និងផ្អែកតាមការបោះផ្សាយអាណត្តិបើកប្រាក់របស់រដ្ឋបាលក្រុង ស្រុកនីមួយៗ។ អាស្រ័យហេតុនេះ ការទិញសម្ភារៈ ឧបករណ៍ និងការទូទាត់ចំណាយនានាតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុកមានភាពយឺតយ៉ាវ។

- ការិយាល័យអប់រំ យុវជន និងកីឡាទទួលបានឧបករណ៍ សម្ភារៈការិយាល័យតិចជាងមុន ការជួសជុលឧបករណ៍នានាមានភាពយឺតយ៉ាវជាងមុន ដោយសាររដ្ឋបាលក្រុង ស្រុកត្រូវធ្វើលទ្ធកម្មឧបករណ៍ សម្ភារៈរួមគ្នា ហើយរដ្ឋបាលក្រុង ស្រុកមួយចំនួនបានចែករំលែកសម្ភារៈការិយាល័យ មួយចំនួនឱ្យទៅអង្គភាពផ្សេងទៀត។ ពេលមុនធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាមករដ្ឋបាលក្រុង ស្រុក ខណ្ឌ កញ្ចប់ថវិកានេះត្រូវបានគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ដោយការិយាល័យអប់រំ យុវជន និងកីឡាផ្ទាល់តែម្តង មានន័យថា ការទិញឧបករណ៍ សម្ភារៈ ការជួសជុល និងការចំណាយលើមុខចំណាយដែលបានកំណត់ ត្រូវធ្វើឡើងដោយការិយាល័យ អប់រំ យុវជន និងកីឡា
- ការបើកប្រាក់បេសកកម្មរបស់បុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានលើកឡើងថាមានភាពយឺតយ៉ាវជាងមុន ដោយហេតុថាការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុកពុំមានលទ្ធភាពរៀបចំឯកសារទូទាត់ប្រាក់បេសកកម្មជូនបុគ្គលិកម្នាក់ៗបានភ្លាមៗបន្ទាប់បុគ្គលិកទាំងនោះចុះទៅបំពេញបេសកកម្មឡើយ គឺត្រូវរៀបចំឯកសារ និងទូទាត់ប្រាក់បេសកកម្មជូនបុគ្គលិករួមគ្នាប្រចាំត្រីមាស ឬប្រចាំឆមាស។ ភាពយឺតយ៉ាវនៃការផ្តល់ប្រាក់បេសកកម្មបានធ្វើឱ្យការចុះពិនិត្យ តាមដានសកម្មភាពរបស់គ្រូនៅតាមសាលារៀនត្រូវបានកាត់បន្ថយយ៉ាងច្រើន ប្រការនេះផ្តល់ផលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំ។ មុនពេលផ្ទេរមុខងារក្នុងវិស័យ អប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ការិយាល័យអប់រំ យុវជន និង

កីឡាមានលទ្ធភាពបើកប្រាក់បេសកកម្មឱ្យបុគ្គលិកចុះទៅបំពេញការងារនៅតាមសាលារៀន មុនពេលចុះទៅបំពេញបេសកកម្ម ឬបន្ទាប់ពីបានបំពេញបេសកកម្មភ្លាមៗ ដោយសារកញ្ចប់ថវិកាសម្រាប់បើកប្រាក់បេសកកម្មទាំងនេះមានតម្កល់នៅក្នុងគណនីធនាគារឯកជនរបស់ការិយាល័យអប់រំ យុវជន និងកីឡាផ្ទាល់តែម្តង

- ផ្អែកតាមការពិភាក្សាក្នុងសិក្ខាសាលាពិគ្រោះយោបល់បានលើកឡើងថា បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានធ្វើឱ្យការិយាល័យអប់រំ យុវជន និងកីឡាមួយចំនួនពុំបានទទួល ឬទទួលបានថវិកា និងឧបករណ៍ សម្ភារៈសម្រាប់ប្រតិបត្តិការការិយាល័យមានចំនួនមិនគ្រប់គ្រាន់ ឬតិចតួចបំផុត។ ទន្ទឹមគ្នានេះ មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាមួយចំនួនក៏បានលើកឡើងថា ខ្លួនពុំដែលទទួលបានប្រាក់បេសកកម្ម ឬទទួលបានប្រាក់បេសកកម្មក្នុងកម្រិតតិចតួចសម្រាប់ការចុះតាមដាន ត្រួតពិនិត្យ នៅតាមសាលារៀន ដូចមុនពេលធ្វើសមាហរណកម្មឡើយ។ បញ្ហានេះអាចកើតឡើង ដោយសារមិនមានការជូនដំណឹងច្បាស់លាស់អំពីលក្ខខណ្ឌនៃការប្រើប្រាស់ថវិកាសម្រាប់ប្រតិបត្តិការការិយាល័យអប់រំ (៣០លានរៀល/១ឆ្នាំ) ថ្នាក់ដឹកនាំក្រុង ស្រុក ខណ្ឌ និងប្រធានការិយាល័យអប់រំមួយចំនួនខ្វះការជជែកពិភាក្សាដើម្បីដោះស្រាយបញ្ហាប្រើប្រាស់ថវិកាសម្រាប់គាំទ្រការិយាល័យអប់រំ យុវជន និងកីឡា រដ្ឋបាលក្រុង ស្រុក ខណ្ឌខ្លះបានប្រើប្រាស់កញ្ចប់ថវិកាអប់រំមួយចំណែកសម្រាប់គាំទ្រការិយាល័យ និងអង្គភាពផ្សេងទៀត។
- ការប្រើប្រាស់ថវិកាប្រចាំឆ្នាំសម្រាប់ប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាចំនួនប្រមាណ៣០លានរៀលក្នុង១ឆ្នាំៗដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ ត្រូវបានរាយការណ៍ថា ពុំបានចំណាយគ្រប់ចំនួនទាំងអស់សម្រាប់គាំទ្រប្រតិបត្តិការនៃការិយាល័យអប់រំ យុវជន និងកីឡាឡើយ ដោយសារថវិកានេះត្រូវបានដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិការួមរបស់រដ្ឋបាលក្រុង ស្រុក និងពុំបានកំណត់ច្បាស់លាស់ថាជាកញ្ចប់ថវិកាមានភ្ជាប់លក្ខខណ្ឌសម្រាប់រ៉ាប់រងតែទៅលើចំណាយគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាឡើយ អាស្រ័យហេតុនេះរដ្ឋបាលក្រុង ស្រុកមួយចំនួនបានចែករំលែកថវិកានេះសម្រាប់រ៉ាប់រងលើការចំណាយគាំទ្រប្រតិបត្តិការការិយាល័យ ឬអង្គភាពផ្សេងទៀត
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងអំពីការបែងចែកថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាដែលមានចំនួនប្រមាណ៣០លានរៀលក្នុងមួយឆ្នាំ គឺពុំទាន់សមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់ការិយាល័យអប់រំ យុវជន និងកីឡានៅតាមរដ្ឋបាលក្រុង ស្រុកនីមួយៗឡើយ។
- ការបើកផ្តល់ថវិកាសម្រាប់ឧបត្ថម្ភដល់គ្រូបង្រៀនជំនួស ឬថ្នាក់គួប រួមទាំងថវិកាលំហែមាតុភាពសម្រាប់គ្រូជំនួសក៏ត្រូវបានលើកឡើងថាមានភាពយឺតយ៉ាវខ្លាំងជាងមុន។

### ខ. ការគ្រប់គ្រងថវិកាដំណើរការសាលារៀន




ផ្អែកតាមការស្ទង់មតិពីអ្នកពាក់ព័ន្ធចំនួន៣០៥ នាក់បានបង្ហាញឱ្យឃើញថា មតិ៤១% យល់ឃើញថាមានស្ថានភាពល្អជាងមុន មតិ៥៤% យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ៥%យល់ឃើញថាមានស្ថានភាពអន់ជាងមុន។

ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងសហគមន៍បានបង្ហាញឱ្យឃើញអំពីស្ថានភាពនៃការគ្រប់គ្រង ការប្រើប្រាស់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការសាលារៀនមិនមានការប្រែប្រួលគួរឱ្យកត់សម្គាល់ឡើយ គឺមានស្ថានភាពដូចមុនដោយហេតុថា ក្នុងក្របខណ្ឌនៃការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាដំណើរការសាលារៀននៅរក្សាការអនុវត្តតាមលក្ខខណ្ឌ គោលការណ៍ បែបបទ និងនីតិវិធីដដែលដូចមុនពេលធ្វើប្រតិភូកម្ម។

### ៧.៣.៥. ការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិ




ផ្អែកតាមការស្ទង់មតិពីអ្នកពាក់ព័ន្ធចំនួន៣០៥ នាក់បានបង្ហាញឱ្យឃើញថា **មតិ៤២%**យល់ឃើញថាមានស្ថានភាពល្អជាងមុន មតិ៥៣% យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ៥%យល់ឃើញថាមានស្ថានភាពអន់ជាងមុន។

ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងសហគមន៍បានបង្ហាញឱ្យឃើញថា ដោយសារទ្រព្យសម្បត្តិទាំងនេះពុំទាន់ត្រូវបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក អាស្រ័យហេតុនេះស្ថានភាពនៃការគ្រប់គ្រង ការប្រើប្រាស់ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារៈគឺពុំមានការប្រែប្រួលឡើយ ដោយរក្សាស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តដដែល។

ទោះយ៉ាងនេះក្តី បញ្ហាប្រឈមដែលបានលើកឡើង គឺបន្ទាប់ពីការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមក មន្ទីរអប់រំ យុវជន និងកីឡាខេត្តក៏ឈប់ផ្តល់សម្ភារៈ និងឧបករណ៍ចាំបាច់នានាមកឱ្យការិយាល័យអប់រំ យុវជន និងកីឡាដែរ ដោយលើកហេតុផលថានឹងមានបញ្ហាក្នុងការចុះបញ្ជីសារពើភ័ណ្ឌ ដោយសារតែការិយាល័យអប់រំ យុវជន និងកីឡាពុំមែនជាអង្គភាពខ្សែបណ្តោយរបស់ក្រសួងអប់រំ យុវជន និងកីឡាទៀតឡើយ។ ដោយឡែក មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញត្រូវបានរាយការណ៍ថា បានបន្តផ្តល់ឧបករណ៍ សម្ភារៈចាំបាច់នានាដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលខណ្ឌ បើទោះបីការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌក៏ដោយ។

### ៧.៣.៦. ទំនាក់ទំនងការងារ និងគណនេយ្យភាព

ក្នុងលក្ខខណ្ឌនៃការផ្ទេរប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងការអនុវត្តមុខងារក្នុងវិស័យអប់រំ រដ្ឋបាលក្រុង ស្រុកត្រូវមានភារកិច្ច និងការទទួលខុសត្រូវលើការអនុវត្តមុខងារដែលបានផ្ទេរប្រតិភូកម្មទាំងនេះ តាមគោលការណ៍ និងស្តង់ដាដែលបានកំណត់ក្នុងនាមជាភ្នាក់ងាររបស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងករណីនេះ រដ្ឋបាលក្រុង ស្រុកពុំអាចធ្វើគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋក្នុងការអនុវត្តមុខងារដែលបានផ្ទេរប្រតិភូកម្មនោះឡើយ។ ក្នុងន័យនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួងពុំផ្តោតការវាយតម្លៃលើស្ថានភាពនៃការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកចំពោះប្រជាពលរដ្ឋលើការអនុវត្តមុខងារអប់រំដែលបានផ្ទេរប្រតិភូកម្មឱ្យរដ្ឋបាលក្រុង ស្រុកឡើយ ដោយផ្តោតតែការវាយតម្លៃទៅលើស្ថានភាពនៃទំនាក់ទំនងការងារ និងការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរ/ក្រសួងអប់រំ យុវជន និងកីឡាតែប៉ុណ្ណោះ។

ផ្អែកតាមការស្ទង់មតិអំពីទំនាក់ទំនងការងារ និងការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរ/ក្រសួងអប់រំ យុវ ជន និងកីឡា ក្នុងចំណោមអ្នកពាក់ព័ន្ធចំនួន៣០៥នាក់បានបង្ហាញឱ្យឃើញថាមានមតិ៤៤%យល់ឃើញថាស្ថានភាពល្អជាងមុន មតិ៤៣% យល់ឃើញថាមានស្ថានភាពដូចមុន និងមតិ១៣%យល់ឃើញថាមានស្ថានភាពអន់ជាងមុន។




ផ្អែកតាមការពិភាក្សាជាមួយក្រុមអ្នកផ្តល់ព័ត៌មានពាក់ព័ន្ធនានាទាំងនៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងសហគមន៍បានបង្ហាញឱ្យឃើញអំពីស្ថានភាពនៃទំនាក់ទំនងការងារ និងការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរអប់រំ យុវជន និងកីឡាក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុករួមមានសង្ខេបដូចខាងក្រោម៖

#### ចំណុចវិជ្ជមាន៖

- ស្ថានភាពនៃទំនងទំនងការងារ និងគណនេយ្យភាពរវាងរដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្រូវបានលើកឡើងថាបានកែលម្អជាបណ្តើរៗពីមួយឆ្នាំទៅមួយឆ្នាំ ស្របតាមការទទួលខុសត្រូវ និងខ្សែគណនេយ្យភាពក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ ដែលបានផ្ទេរប្រតិភូកម្មមកឱ្យរដ្ឋបាលថ្នាក់រដ្ឋបាលក្រុង ស្រុក ដោយហេតុថា មន្ត្រីនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ព្រមទាំងថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកមានការយល់ដឹងកាន់តែច្បាស់លាស់អំពីទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពថ្មីដែលត្រូវអនុវត្តក្នុងក្របខណ្ឌនៃការផ្ទេរប្រតិភូកម្មមុខងារអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក

ចំណុចអវិជ្ជមាន និងបញ្ហាប្រឈមៈ

- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងថា ក្នុងដំណាក់កាលដំបូងនៃការចាប់ផ្តើមអនុវត្តមុខងារអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុកបានជួបបញ្ហាប្រឈមមួយចំនួនក្នុងការធ្វើទំនាក់ទំនងការងារ និងធ្វើគណនេយ្យភាពក្នុងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មទាំងនេះ។ ដោយសារ ក្នុងបណ្តាឆ្នាំដំបូងៗនៃការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មនេះមន្ទីរអប់រំ យុវជន និងកីឡានៅតែបន្តទំនាក់ទំនងការងារជាផ្លូវការដោយផ្ទាល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡា ដូចជាការចាត់តាំងបុគ្គលិកនៃការិយាល័យអប់រំ យុវជន និងកីឡាទៅបំពេញបេសកកម្មនានា ការស្នើឱ្យការិយាល័យអប់រំ យុវជន និងកីឡាផ្តល់ទិន្នន័យ និងរបាយការណ៍ពាក់ព័ន្ធនានាដោយផ្ញើត្រង់ទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តជាដើម។ ប្រការបានធ្វើឱ្យរដ្ឋបាលក្រុង ស្រុកជួបការលំបាកក្នុងការគ្រប់គ្រងបុគ្គលិក និងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មឱ្យ
- ក្រុមអ្នកផ្តល់ព័ត៌មានមួយចំនួនបានលើកឡើងអំពីបញ្ហាប្រឈមជាចំពោះការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក ដោយសារតែរដ្ឋបាលក្រុង ស្រុកពុំផ្តោតការយកចិត្តទុកដាក់ពេញលេញលើការណែនាំ និងគាំទ្រដល់បុគ្គលិកអប់រំបម្រើការងារនៅតាមសាលារៀន ព្រោះបុគ្គលិកទាំងនោះមិនស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ខ្លួន ហើយមន្ទីរអប់រំ យុវជន និងកីឡាខេត្តក៏ជួបការលំបាកក្នុងការផ្តល់អន្តរាគមន៍គាំទ្រដល់សាលារៀនផងដែរ ព្រោះគិតថា កិច្ចការទាំងនោះត្រូវបានធ្វើប្រតិភូកម្មឱ្យទៅរដ្ឋបាលក្រុង ស្រុករួចអស់ហើយ និងការិយាល័យអប់រំ យុវជន និងកីឡាក៏ពុំមែនជាអង្គភាពខ្សែបណ្តោយរបស់ខ្លួនដូចមុនទៀតឡើយ ។ ការតាមដាន ត្រួតពិនិត្យ និងគាំទ្រពុំបានជិតដល់បែបនេះអាចធ្វើឱ្យប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំនៅតាមសាលារៀនធ្លាក់ចុះ និងមានហានិភ័យ ក្នុងករណីគ្មានដំណោះស្រាយទាន់ពេលវេលា។

## ៨. ការវិភាគ និងអនុសាសន៍

### ៨.១. ការវិភាគ

ភាពជោគជ័យនៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាស្រ័យទៅលើកត្តាសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- សិទ្ធិអំណាច និងការទទួលខុសត្រូវដែលបានផ្តល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តមុខងារដែលបានផ្ទេរឱ្យទាំងនោះ
- រចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវរៀបចំឡើងសម្រាប់អនុវត្តមុខងារដែលបានផ្ទេរឱ្យ
- ធនធានមនុស្សដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមាន (ចំនួនបុគ្គលិក សមត្ថភាព ឆន្ទៈ និងគុណវុឌ្ឍិ) សម្រាប់អនុវត្តមុខងារដែលបានផ្ទេរឱ្យ

- ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវការសម្រាប់អនុវត្តមុខងារដែលបានផ្ទេរឱ្យ
- លិខិតូបករណ៍សម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានដូចជា សេចក្តីណែនាំបច្ចេកទេស និយាម និងស្តង់ដាសេវាជាដើម
- យន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារដែលបានផ្ទេរឱ្យ។

ក្នុងការសិក្សាវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ផ្អែកលើការរកឃើញសំខាន់ៗដូចបានបរិយាយក្នុងផ្នែកខាងលើ ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានធ្វើការវិភាគ ពិនិត្យ ផ្ទះបញ្ចាំងទៅតាមកត្តាសំខាន់ៗទាំង៦ ដើម្បីកំណត់ចំណុចខ្លាំង និងចំណុចខ្សោយក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកដូចខាងក្រោម៖

### ក. សិទ្ធិអំណាច និងការទទួលខុសត្រូវ

កត្តាសិទ្ធិអំណាច និងការទទួលខុសត្រូវដែលលើកយកមកវិភាគនេះ គឺសំដៅទៅលើកម្រិតនៃសិទ្ធិអំណាច និងការទទួលខុសត្រូវដែលបានផ្តល់ឱ្យទៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌក្នុងក្របខណ្ឌនៃការប្រគល់មុខងារ និងក្នុងក្របខណ្ឌនៃការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការវាយតម្លៃដោយប្រៀបធៀបប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌតាមកម្រិតនៃសិទ្ធិអំណាចដែលបានផ្តល់ឱ្យក្នុងក្របខណ្ឌនៃការប្រគល់ និងក្នុងក្របខណ្ឌនៃការធ្វើប្រតិភូកម្មមុខងារអប់រំទាំងនោះ។

ពាក់ព័ន្ធនឹងការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវនេះ ផ្អែកតាមអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌបានកំណត់ជាគោលការណ៍រួមឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធដោយត្រូវធានាថា រាល់ការសម្រេច និងរាល់សកម្មភាព ឬទង្វើរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវអនុវត្តតាមគោលការណ៍ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវាដែលបានកំណត់ដោយថ្នាក់ជាតិ។

ផ្អែកតាមមាត្រា៤នៃប្រកាសអន្តរក្រសួងលេខ ៥២១ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ បានកំណត់ឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុកត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពខាងលទ្ធផលចំពោះរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលបានប្រគល់ឱ្យស្របតាមគោលនយោបាយអាទិភាពវិស័យអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ កម្មវិធីកែទម្រង់វិស័យអប់រំ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងត្រូវមានគណនេយ្យភាពចំពោះប្រជាជនក្នុងការផ្តល់សេវាអប់រំក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងន័យនេះ រដ្ឋបាលក្រុង ស្រុកត្រូវបានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញលើការអនុវត្តមុខងារដែលបានប្រគល់ជាងការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវលើការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្ម។

សិទ្ធិអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺជាកត្តាដែលបានជំរុញ និងលើកកម្ពស់ភាពម្ចាស់ការ និងគំនិតផ្តួចផ្តើមនានាផ្អែកតាមស្ថានភាពជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗក្នុងការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានផ្ទេរឱ្យទាំងនោះឱ្យទទួលបានជោគជ័យតាមលក្ខខណ្ឌនានាដែលបានកំណត់។ ពាក់ព័ន្ធនឹងកត្តានេះ ផ្អែកតាមរបកគំហើញក្រុមការងារបច្ចេកទេសអន្តរក្រសួងអាចឆ្លុះបញ្ចាំង និងប្រៀបធៀបលទ្ធផលនៃការអនុវត្តនៅតាមរដ្ឋបាលក្រុង ស្រុកដែលបានចុះទៅសិក្សា រួមមានដូចខាងក្រោម៖

- **ការប្រគល់មុខងារ**ទាំង៣ រួមមាន ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលបានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងបានធ្វើឱ្យរដ្ឋបាលក្រុង ស្រុកទាំងនេះមានភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់ក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានប្រគល់ទាំងនោះឱ្យទទួលបានលទ្ធផលល្អប្រសើរ ដោយទទួលបានការពេញចិត្ត និងការគាំទ្រពីស្ថាប័ន និងអ្នកពាក់ព័ន្ធនានា រួមមាន ក្រុមប្រឹក្សា គណៈអភិបាល លោកគ្រូ អ្នកគ្រូ នាយកសាលា មេឃុំ/ចៅសង្កាត់ ថ្នាក់ដឹកនាំភូមិ តំណាងគណៈកម្មការគ្រប់គ្រងសាលា និងសហគមន៍មូលដ្ឋាន។ ទន្ទឹមគ្នានេះ រដ្ឋបាលក្រុង ស្រុកក៏បានធ្វើគណនេយ្យភាពច្បាស់លាស់ជាមួយប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងការដឹកនាំ គ្រប់គ្រង ចាត់ចែងមុខងារដែលបានប្រគល់ឱ្យទាំងនោះផងដែរ។ ភស្តុតាងជាច្រើនដែលបានរកឃើញពាក់ព័ន្ធនឹងភាពជោគជ័យ និងការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកចំពោះប្រជាពលរដ្ឋក្នុងការអនុវត្តមុខងារអប់រំដែលបានប្រគល់រួមមានដូចជា៖ រាល់កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុង ស្រុកតែងតែលើកយកបញ្ហាអប់រំមកពិនិត្យ ពិភាក្សា និងដោះស្រាយ។ ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុកនីមួយៗបានយកចិត្តទុកដាក់ផ្តល់ការអន្តរាគមន៍គាំទ្រ និងដោះស្រាយបញ្ហាប្រឈមនានានៅតាមសាលារៀន។ ក្នុងវេទិកាសាធារណៈនានា ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកតែងតែបានចូលរួមផ្សព្វផ្សាយ ពិគ្រោះយោបល់ និងប្រមូលសំណើសំណូមពររបស់ប្រជាពលរដ្ឋ និងសហគមន៍អំពីបញ្ហាពាក់ព័ន្ធនឹងសេវាអប់រំ។ រដ្ឋបាលក្រុង ស្រុកបានសម្របសម្រួល និងជំរុញការចូលរួមពីរដ្ឋបាលឃុំ សង្កាត់ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធក្នុងសកម្មភាពអប់រំ ព្រមទាំងបានសម្របសម្រួល និងកៀរគរធនធានពីសប្បុរសជន អង្គការសង្គមស៊ីវិល មាតាបិតាសិស្សដើម្បីអភិវឌ្ឍសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ឧទាហរណ៍ស្រុកគាស់ ក្រឡបានកៀរគរធនធានសាងសង់សាលារៀនចំនួន៩កន្លែងស្មើ១២ខ្នង និងផ្ទះសំណាក់គ្រូ១ខ្នង ស្រុកបវេលបានកសាងសាលារៀន៨ខ្នង និងបន្ទប់អនាម័យចំនួន៨ ស្រុកថ្មគោលបានកៀរគរថវិកាសរុបជាង២០ម៉ឺនដុល្លារសម្រាប់សាងសង់សាលារៀន និងបំពាក់សម្ភារៈឧបករណ៍នានា ស្រុកកំរៀងបានសម្របសម្រួលរដ្ឋបាលឃុំសាងសង់សាលារៀនបាន៣បន្ទប់ ស្រុករតនមណ្ឌលបានកៀរគរសប្បុរសជនសម្រាប់កសាងសាលាបាន៤ខ្នង (គិតជាទឹកប្រាក់

ជាង១៥ម៉ឺនដុល្លារ) ស្រុកមោងឬស្សីបានកៀរគរធនធានពីមាតាបិតាសិស្សដើម្បីសាងសង់សាលាមត្តេយ្យ១ខ្នងមាន៣បន្ទប់ជាដើម។

- **ការធ្វើប្រតិភូកម្មមុខងារអប់រំទាំង៦**ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្តផ្សេងទៀតក្រៅពីខេត្តបាត់ដំបងដែលបានផ្តល់ការទទួលខុសត្រូវមួយផ្នែកទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនោះ បានបង្ហាញឱ្យឃើញថាលទ្ធផលនៃការគ្រប់គ្រង និងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មទាំងនោះក៏មានស្ថានភាពល្អជាងមុនដែរ ក៏ប៉ុន្តែពុំទទួលបានលទ្ធផលល្អប្រសើរដូចការអនុវត្តមុខងារដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងឡើយ។ ទន្ទឹមគ្នានេះ ក៏មានបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងទំនាក់ទំនងការងារមិនច្បាស់លាស់រវាងរដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងជាមួយសាលារៀនផងដែរ ដែលប្រការនេះបានធ្វើឱ្យការអនុវត្តមុខងារអប់រំដែលបានធ្វើប្រតិភូកម្មឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌជួបការលំបាកមួយចំនួនក្នុងការអនុវត្ត និងមានការទទួលខុសត្រូវច្បាស់លាស់ក្នុងចំណោមស្ថាប័នពាក់ព័ន្ធទាំងនេះ។ ក្នុងក្របខណ្ឌនៃការអនុវត្តមុខងារអប់រំដែលបានធ្វើប្រតិភូកម្ម រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនេះត្រូវបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវពេញលេញតែលើការគ្រប់គ្រងការិយាល័យអប់រំ យុវជន និងកីឡាដែលបានធ្វើសមាហរណកម្មមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រីឯគ្រឹះស្ថានបឋមសិក្សា និងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈគឺនៅស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។ អាស្រ័យហេតុនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ជួបការលំបាកក្នុងការដឹកនាំ ការគ្រប់គ្រង និងការជំរុញដល់គ្រូបង្រៀនដែលជាអ្នកផ្តល់សេវាអប់រំផ្ទាល់នៅតាមសាលារៀននីមួយៗ។ ទន្ទឹមគ្នានេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តក៏ជួបការលំបាកក្នុងការផ្តល់អន្តរាគមន៍គាំទ្រទៅដល់គ្រឹះស្ថានបឋមសិក្សា និងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈទាំងនោះផងដែរ ដោយសារការិយាល័យអប់រំ យុវជន និងកីឡាត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំមែនជាអង្គភាពខ្សែបណ្តោយរបស់ខ្លួនទៀតឡើយ អាស្រ័យហេតុនេះ មន្ទីរអប់រំ យុវជន និងកីឡាពុំមានលទ្ធភាពពេញលេញសម្រាប់ចុះតាមដាន ត្រួតពិនិត្យ និងគាំទ្រនៅតាមសាលារៀនទូទាំងរាជធានី ខេត្តបានឡើយ។
- ជារួម ការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងក្របខណ្ឌនៃការធ្វើប្រតិភូកម្មពុំបានជំរុញ និងលើកកម្ពស់ភាពម្ចាស់ការ និងការទទួលខុសត្រូវឱ្យបានពេញលេញដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការជំរុញការអនុវត្តមុខងារអប់រំដែលបានធ្វើប្រតិភូកម្មទាំងនោះឱ្យទទួលបានលទ្ធផលល្អប្រសើរដូចការអនុវត្តមុខងារអប់រំដែលបានប្រគល់ឡើយ ហើយគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈដែលជាកន្លែងផ្តល់សេវាអប់រំផ្ទាល់ជូនប្រជាជនទទួលបានការគាំទ្រ និងការតាមដាន ត្រួតពិនិត្យពុំបានជិតដល់ទាំងពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងពីរដ្ឋបាលក្រុង ស្រុក។

ខាងស្តាំនេះគឺជាក្រាហ្វិកប្រៀបធៀបលទ្ធផលនៃការគ្រប់គ្រង និងការអនុវត្តមុខងារដែលបានប្រគល់ និងមុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង។




ខាងស្តាំនេះគឺជាក្រាហ្វិកប្រៀបធៀបលទ្ធផលនៃការគ្រប់គ្រង និងការអនុវត្តមុខងារដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង និងមុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តក្រចេះ និងខេត្តកំពត។




## ខ. រចនាសម្ព័ន្ធគ្រប់គ្រង

រចនាសម្ព័ន្ធគ្រប់គ្រងដែលលើកយកមកវិភាគនេះ សំដៅលើរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានរៀបចំឡើងសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។

ផ្អែកតាមអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ បានតម្រូវឱ្យរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងពាក់ព័ន្ធនឹងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានលក្ខណៈផ្សេងគ្នារវាងរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងដែលត្រូវអនុវត្តមុខងារដែលបានប្រគល់ឱ្យ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី និងខេត្តផ្សេងដែលត្រូវអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មឱ្យ។ រចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងពាក់ព័ន្ធនឹងការអនុវត្តមុខងារអប់រំរួមមាន ការិយាល័យអប់រំ យុវជន និងកីឡា គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ។ ដោយឡែក រចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី និងខេត្តដទៃពាក់ព័ន្ធនឹងការអនុវត្តមុខងារក្នុងវិស័យអប់រំ គឺមានតែការិយាល័យអប់រំ យុវជន និងកីឡាប៉ុណ្ណោះ រីឯគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈនៅស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

ផ្អែកតាមរបកគំហើញ ក្រុមការងារបច្ចេកទេសអន្តរក្រសួងអាចវិភាគ និងវាយតម្លៃលើលទ្ធផលនៃការអនុវត្តជាក់ស្តែងនៅតាមរដ្ឋបាលក្រុង ស្រុកដែលបានចុះទៅសិក្សាដូចខាងក្រោម៖

- ការរៀបចំរចនាសម្ព័ន្ធពេញលេញសម្រាប់អនុវត្តមុខងារអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងបានធ្វើឱ្យមានយន្តការស្ថាប័ន និងមានខ្សែគណនេយ្យភាពច្បាស់លាស់រវាងសាលារៀនជាមួយការិយាល័យអប់រំ យុវជន និងកីឡា រវាងការិយាល័យអប់រំ យុវជន និងកីឡាជាមួយរដ្ឋបាលក្រុង ស្រុក និងរវាងរដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរក្រសួងអប់រំ យុវជន និងកីឡា។ ប្រការនេះបានជំរុញឱ្យការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានប្រគល់មកឱ្យរដ្ឋបាលក្រុង ស្រុកមានលក្ខណៈងាយស្រួល មានទំនាក់ទំនងការងារ និងឋានានុក្រមច្បាស់លាស់ និងទទួលបានលទ្ធផលល្អប្រសើរ។
- ចំពោះការរៀបចំរចនាសម្ព័ន្ធនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌនៃរាជធានី ខេត្តផ្សេងទៀត ដែលបានធ្វើសមាហរណកម្មតែការិយាល័យអប់រំ យុវជន និងកីឡាមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយរក្សាគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តបានធ្វើឱ្យខ្សែគណនេយ្យភាព និងទំនាក់ទំនងការងារពុំមានភាពច្បាស់លាស់រវាងគ្រឹះស្ថានបឋមសិក្សា និងមត្តេយ្យសិក្សាសាធារណៈជាមួយការិយាល័យអប់រំ យុវជន និងកីឡា និងជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរវាងការិយាល័យអប់រំ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានធ្វើប្រតិភូកម្ម។ ប្រការនេះបានធ្វើឱ្យការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌពុំទទួលបានលទ្ធផលល្អប្រសើរដូចការអនុវត្តមុខងារអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង។
- ជារួម មានភស្តុតាងជាច្រើនបានរកឃើញថា បន្ទាប់ពីការផ្ទេរគ្រឹះស្ថានបឋមសិក្សា និងមត្តេយ្យសិក្សាសាធារណៈមកជាអង្គភាពចំណុះរបស់រដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង បានជំរុញ ឱ្យថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកផ្តោតការយកចិត្តទុកដាក់ប្រកបដោយភាពម្ចាស់ការក្នុងការសម្របសម្រួល និងផ្តល់អន្តរាគមន៍គាំទ្រ តាមដាន ត្រួតពិនិត្យសកម្មភាពនានានៅតាមសាលារៀន រួមមានដូចជា ការផ្តល់សេវាអប់រំតាមសាលារៀន ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការធានាសុវត្ថិភាពចរាចរណ៍របស់សិស្សពេលចេញចូលសាលារៀន ការការពារថែរក្សាបរិស្ថាននិងអនាម័យចំណីអាហារ ការពង្រឹងទំនាក់ទំនងការងារជាមួយគ្រូបង្រៀន និងការត្រួតពិនិត្យវត្តមានគ្រូបង្រៀន ការគោរពវិន័យ សកម្មភាពអភិវឌ្ឍយុវជន ការអប់រំកាយ និងកីឡានៅតាមសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានស្ថានភាពល្អប្រសើរជាងស្ថានភាពនៃការគ្រប់គ្រងសាលារៀននានាក្នុងរដ្ឋបាលក្រុង ស្រុកនៃខេត្តផ្សេងទៀត។

### គ. ធនធានមនុស្ស

កត្តាធនធានមនុស្សដែលលើកយកមកវិភាគនេះ គឺផ្តោតទៅលើការវាយតម្លៃអំពី (១) ប្រសិទ្ធភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបុគ្គលិកអប់រំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡាសម្រាប់អនុវត្តមុខងារអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង(២) ប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ផ្អែកលើធនធានមនុស្ស (បុគ្គលិកអប់រំ) ដែលបានផ្ទេរទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌទាំងនោះ។

ផ្អែកតាមអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌបានតម្រូវឱ្យមានការផ្ទេរបុគ្គលិកអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុកមានលក្ខណៈខុសគ្នារវាងការផ្ទេរបុគ្គលិកអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងសម្រាប់អនុវត្តមុខងារដែលបានប្រគល់ និងការផ្ទេរបុគ្គលិកអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តផ្សេងទៀតសម្រាប់អនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មឱ្យ។

ចំពោះរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង បុគ្គលិកអប់រំទាំងអស់ រួមមានបុគ្គលិកបម្រើការងារនៅការិយាល័យអប់រំ យុវជន និងកីឡា បុគ្គលិកដែលជាគ្រូបង្រៀនបម្រើការងារនៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវបានផ្ទេរមកជាបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុកដោយត្រូវគ្រប់គ្រងតាមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

ចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្តដទៃទៀតត្រូវបានផ្ទេរតែបុគ្គលិកដែលបម្រើការងារនៅការិយាល័យអប់រំ យុវជន និងកីឡាប៉ុណ្ណោះមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ រីឯបុគ្គលិកដែលជាគ្រូបង្រៀនបម្រើការងារនៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ពុំត្រូវបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឡើយ។

ផ្អែកតាមរបកគំហើញ ក្រុមការងារបច្ចេកទេសអន្តរក្រសួងអាចឆ្លុះបញ្ចាំងបានថា៖

- ក្នុងក្របខណ្ឌនៃការផ្ទេរមុខងារអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំដែលបានផ្ទេរមកក្លាយជាបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌមានលក្ខណៈល្អប្រសើរជាងស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំដែលពុំទាន់បានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ជារួម ទាំងបុគ្គលិកបម្រើការងារនៅការិយាល័យអប់រំ យុវជន និងកីឡា និងគ្រូបង្រៀនបម្រើការងារនៅតាមសាលារៀននានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងបានបង្ហាញនូវភាពពេញចិត្តចំពោះការគ្រប់គ្រងបុគ្គលិកដោយរដ្ឋបាលក្រុង ស្រុក ដូចជាការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការគ្រប់គ្រងវត្តមាន និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលផ្សេងទៀតរបស់បុគ្គលិក ដែលត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស ស្របតាមគោលការណ៍ និងនីតិវិធីគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុកយ៉ាងច្បាស់លាស់ ហើយការសម្រេចនានាលើការគ្រប់គ្រងបុគ្គលិកទាំងនេះត្រូវធ្វើដោយរដ្ឋបាលក្រុង ស្រុកសាមីនីមួយៗផ្ទាល់តែម្តង ដោយពុំចាំបាច់បញ្ជូនឯកសារ និងសុំការពិនិត្យសម្រេចពីមន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡាឡើយ។

ប្រការនេះបានជំរុញលើកទឹកចិត្តឱ្យបុគ្គលិកអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងមានការជឿជាក់លើការដឹកនាំ និងការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក និងកាន់តែមានឆន្ទៈមោះមុតក្នុងការបំពេញការងាររបស់ខ្លួន។ ជាមួយគ្នានេះ រដ្ឋបាលក្រុង ស្រុកក៏មានសិទ្ធិ និងការទទួលខុសត្រូវពេញលេញក្នុងការគាំទ្រ តាមដាន ត្រួតពិនិត្យលើការពង្រឹងការបំពេញតួនាទី និងការទទួលខុសត្រូវថ្នាក់ដឹកនាំសាលា គ្រូបង្រៀននៅតាមសាលារៀននីមួយៗ។ ប្រការនេះបានជំរុញឱ្យគ្រូបង្រៀនមកបង្រៀនបានយ៉ាងទៀងទាត់ និងគោរពវិន័យក្រមសីលធម៌គ្រូបង្រៀនបានល្អប្រសើរស្របតាមស្តង់ដារបស់ក្រសួងអប់រំ។ ម្យ៉ាងវិញទៀត ការផ្ទេរបុគ្គលិកអប់រំ ដែលរួមមានទាំងការផ្ទេរបុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡា និងទាំងគ្រូបង្រៀនបម្រើការងារនៅតាមសាលារៀនមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកបាន បង្កលក្ខណៈងាយស្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំ ចាត់ចែងផ្លាស់ប្តូរបុគ្គលិកអប់រំពីសាលារៀនដែលមានចំនួនគ្រូបង្រៀនច្រើនទៅសាលារៀនដែលត្រូវការគ្រូបង្រៀនបន្ថែម ឬផ្ទេរមកបំពេញការងារនៅការិយាល័យអប់រំ យុវជន និងកីឡាដែលខ្វះបុគ្គលិក។ ទោះយ៉ាងនេះក្តី ការផ្ទេរបុគ្គលិកអប់រំទៅឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុកក៏អាចបង្កឱ្យមានបញ្ហាប្រឈមមួយចំនួនផងដែរ ដោយសាររដ្ឋបាលក្រុង ស្រុកមួយចំនួនបានផ្ទេរបុគ្គលិកអប់រំទៅបំពេញការងារនៅការិយាល័យ/អង្គភាពផ្សេង និងចាត់តាំងបុគ្គលិកអប់រំឱ្យទៅបំពេញការងារផ្សេងៗដែលអាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តការងារអប់រំ។

- ដោយឡែក ការគ្រប់គ្រងគ្រូបង្រៀនដែលបម្រើការងារនៅតាមសាលារៀនក្នុងក្រុង ស្រុក ខណ្ឌនៃរាជធានី ខេត្តដទៃទៀត ជាពិសេសក្នុងខេត្តក្រចេះ និងខេត្តកំពតដែលក្រុមការងារបានចុះទៅសិក្សាវាយតម្លៃ បានបង្ហាញឱ្យឃើញថា ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលផ្សេងទៀតរបស់គ្រូបង្រៀននៅតាមសាលារៀន មានភាពយឺតយ៉ាវជាងការគ្រប់គ្រងគ្រូបង្រៀននៅតាមសាលារៀន ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង ដោយសារការសម្រេចចិត្តនានាលើការគ្រប់គ្រងបុគ្គលិកទាំងនេះត្រូវពិនិត្យ សម្រេចដោយរដ្ឋបាលរាជធានី ខេត្ត តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា (ការធ្វើប្រតិភូកម្មលើការងារតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងបុគ្គលិកតាមអនុក្រឹត្យលេខ២៤០) និងការពិនិត្យសម្រេចពីក្រសួងអប់រំ យុវជន និងកីឡា (ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលផ្សេងទៀត)។

ខាងស្តាំនេះជាក្រាហ្វិកដែលបង្ហាញនូវការប្រែប្រួលលើស្ថានភាពគ្រប់គ្រងគ្រូបង្រៀនដែលបានផ្ទេរមករដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង និងស្ថានភាពនៃការគ្រប់គ្រងគ្រូបង្រៀនដែលបម្រើការងារនៅតាមសាលារៀនក្នុងខេត្តក្រចេះ និងខេត្តកំពតដែលក្រុមការងារបានចុះទៅសិក្សាវាយតម្លៃ។




### ឃ. ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

កត្តាធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលលើកយកមកវិភាគនេះ គឺផ្តោតទៅលើការវាយតម្លៃអំពីប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាំងក្នុងក្របខណ្ឌធនធានដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងធនធានដែលនៅស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ និងអប់រំយុវជន និងកីឡា។

ការផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺជាលក្ខខណ្ឌចាំបាច់មួយក្នុងចំណោមលក្ខខណ្ឌចាំបាច់នានា។ ការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមាន៖

- ការផ្ទេរថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡា (ប្រមាណ៣០លានរៀលក្នុង១ឆ្នាំៗទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់ទូទាំងប្រទេស)
- ការផ្ទេរថវិកាគាំទ្រកិច្ចដំណើរការសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលជាកញ្ចប់ថវិកាមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបង
- ថវិកាគាំទ្រកិច្ចដំណើរការសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្តដទៃទៀតក្រៅពីខេត្តបាត់ដំបងពុំបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនោះឡើយ គឺនៅរក្សាទុកក្នុងកញ្ចប់ថវិការបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តដូចពេលមុនផ្ទេរមុខងារដដែល ដោយសារសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ពុំបានធ្វើសមាហរណកម្មមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌឡើយ។

ផ្អែកតាមរបកគំហើញ ក្រុមការងារបច្ចេកទេសអន្តរក្រសួងអាចវិភាគ និងវាយតម្លៃបានថា៖

- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់គាំទ្រកិច្ចដំណើរការសាលារៀន

ដែលបានផ្ទេរដាកញ្ចប់ថវិកាមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង មានស្ថានភាពកាន់តែល្អប្រសើរ និងពុំមានបញ្ហាប្រឈមគួរឱ្យកត់សម្គាល់ឡើយ។ មូលហេតុដែលជំរុញឱ្យការប្រើប្រាស់ថវិកាដំណើរការសាលារៀនកាន់តែល្អប្រសើរ រួមមាន៖

- ការផ្ទេរកញ្ចប់ថវិកានេះទៅគណនីរបស់សាលារៀននីមួយៗបានលឿនជាងមុនដោយសាររដ្ឋបាលក្រុង ស្រុកនីមួយៗជាអ្នកបោះផ្សាយអាណត្តិបើកប្រាក់ដើម្បីផ្ទេរថវិកានេះទៅក្នុងគណនីសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗតែម្តង
- សាលារៀននីមួយៗត្រូវបានរក្សាស្វ័យភាព និងការទទួលខុសត្រូវលើការចាត់ចែង និងប្រើប្រាស់ថវិកាទាំងនេះតាមគោលការណ៍ណែនាំដែលបានកំណត់
- មានការចូលរួមពិនិត្យ ផ្តល់យោបល់ និងតាមដានត្រួតពិនិត្យពីគណៈកម្មការគ្រប់គ្រងសាលា និងអ្នកពាក់ព័ន្ធ ព្រមទាំងមានការគាំទ្រ ការតាមដាន ត្រួតពិនិត្យពីការិយាល័យអប់រំ យុវជន និងកីឡា និងថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក។ ទន្ទឹមនឹងនោះ រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ក៏បានកៀរគរធនធានបន្ថែម (ថវិកា ការសាងសង់ការជួសជុលសាលារៀន ឧបករណ៍ សម្ភារ និងការអភិវឌ្ឍសាលារៀនផ្សេងទៀត)សម្រាប់គាំទ្រដល់សាលារៀនផងដែរ។

– ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាដំណើរការសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌនៃរាជធានី ខេត្តដទៃផ្សេងទៀតពុំមានស្ថានភាពប្រែប្រួលគួរឱ្យកត់សម្គាល់ឡើយ គឺមានស្ថានភាពដូចពេលមុនផ្ទេរមុខងារ ដោយសារគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិកានេះពុំមានការផ្លាស់ប្តូរទេ គ្រាន់តែប្រតិភូកម្មការងារមួយចំនួនឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌជួយសម្របសម្រួល ជំរុញ គាំទ្រ និងតាមដានការអនុវត្តថវិកានេះតែប៉ុណ្ណោះ។

– ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាគាំទ្រប្រតិបត្តិការរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌត្រូវបានវាយតម្លៃថាមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវដោះស្រាយ។ បញ្ហាប្រឈមទាំងនោះអាចកើតចេញពីមូលហេតុមួយចំនួនដូចខាងក្រោម៖

- ទោះជាថវិកានេះត្រូវបានផ្តល់ឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់បម្រើការងារអប់រំជាអាទិភាព ក៏ប៉ុន្តែពុំបានកំណត់ច្បាស់លាស់ថាជាកញ្ចប់ថវិកាមានភ្ជាប់លក្ខខណ្ឌដែលត្រូវប្រើប្រាស់សម្រាប់គាំទ្រតែការិយាល័យអប់រំ យុវជន និងកីឡា។ ប្រការនេះ បានធ្វើការប្រើប្រាស់កញ្ចប់ថវិកានេះពុំទាន់ត្រឹមត្រូវពេញលេញតាមគោលបំណង ដែលចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់លាស់ថាថវិកាគាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡា គឺជាថវិកាមានភ្ជាប់លក្ខខណ្ឌដែលត្រូវប្រើប្រាស់សម្រាប់គាំទ្រកិច្ចដំណើរការរបស់ការិយាល័យអប់រំ យុវជន និងកីឡាសម្រាប់គាំទ្រ តាមដាន ត្រួតពិនិត្យ វាយតម្លៃការផ្តល់សេវាអប់រំនានានៅតាមសាលារៀនក្នុងនាមជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់កញ្ចប់ថវិកានេះតាមគោលការណ៍ និងនីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុកបានបង្កឱ្យមានការលំបាកដល់ការបំពេញការងាររបស់ការិយាល័យអប់រំ យុវជន និងកីឡា។ ភាពយឺតយ៉ាវក្នុងការបើកប្រាក់បេសកកម្ម ការបើកផ្តល់សម្ភារការិយាល័យមិនគ្រប់តាមតម្រូវការរបស់ការិយាល័យអប់រំ អាចជះផលប៉ះពាល់ជាអវិជ្ជមានដល់សកម្មភាពចុះត្រួតពិនិត្យ តាមដាន និងគាំទ្របច្ចេកទេសដល់សាលារៀននានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ

– ជារួម ភាពយឺតយ៉ាវ និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការនៃការិយាល័យអប់រំ យុវជន និងកីឡា គឺបណ្តាលមកពីការផ្លាស់ប្តូរនីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាទាំងនេះ ព្រមទាំងពុំបានកំណត់ឱ្យច្បាស់លាស់អំពីលក្ខខណ្ឌនៃការប្រើប្រាស់ថវិកានេះ ដែលប្រការនេះបានធ្វើឱ្យការិយាល័យអប់រំ យុវជន និងកីឡាដែលបានធ្វើសមាហរណកម្មមកក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួនក្នុងរាជធានី ខេត្តផ្សេងទៀតក្រៅពីខេត្តបាត់ដំបង បានទទួលថវិកាគាំទ្រមួយចំនួន ឬពុំទទួលបានថវិកាគាំទ្រតែម្តង ជាពិសេសក្នុងឆ្នាំ២០២១ដែលកំពុងមានវិបត្តិកូវីដ-១៩

– ការវិភាជន៍ថវិកាសម្រាប់គាំទ្រប្រតិបត្តិការ ការិយាល័យអប់រំ យុវជន និងកីឡាដែលមានចំនួនប្រហាក់ប្រហែលគ្នាប្រមាណ៣០លានរៀលក្នុងមួយឆ្នាំក្នុងមួយក្រុង ស្រុក ខណ្ឌ គឺពុំទាន់សមស្របទៅនឹងតម្រូវការជាក់ស្តែងនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗឡើយ ដោយហេតុថា ក្រុង ស្រុក ខណ្ឌនីមួយៗមានចំនួនគ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងចំនួនបុគ្គលិកអប់រំនៃការិយាល័យអប់រំ យុវជន និងកីឡាមិនដូចគ្នាឡើយ។ ក្នុងន័យនេះ ចំពោះក្រុង ស្រុក ខណ្ឌដែលមានគ្រឹះស្ថានសិក្សាច្រើន គឺត្រូវការថវិកាសម្រាប់ចុះត្រួតពិនិត្យ និងគាំទ្របច្ចេកទេសនៅតាមសាលារៀន និងថវិកាសម្រាប់រ៉ាប់រងលើបន្ទុកការងាររបស់ការិយាល័យអប់រំ យុវជន និងកីឡាច្រើនជាងក្រុង ស្រុក ខណ្ឌដែលមានចំនួនគ្រឹះស្ថានសិក្សាតិច។ ដូច្នេះ ការបែងចែកថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាដែលមានចំនួនប្រហាក់ប្រហែលគ្នានេះ គួរត្រូវបានពិនិត្យ និងកែសម្រួលឡើងវិញឱ្យសមស្របទៅតាមបន្ទុកការងារ និងស្ថានភាពជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ដោយមានរូបមន្ត និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់។

– ចំពោះទ្រព្យសម្បត្តិ ទោះបីជាទ្រព្យសម្បត្តិ និងឧបករណ៍នានានៅពុំទាន់ត្រូវបានផ្ទេរជាផ្លូវការទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ដោយ ក៏ទ្រព្យសម្បត្តិ និងឧបករណ៍ទាំងនោះត្រូវបានប្រើប្រាស់សម្រាប់អនុវត្តមុខងារអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយពុំត្រូវបានយកទៅប្រើប្រាស់សម្រាប់សកម្មភាពក្រៅពីការងារអប់រំឡើយ។ ទោះយ៉ាងនេះក្តី ការពុំបានផ្ទេរជាផ្លូវការនូវទ្រព្យសម្បត្តិ និងឧបករណ៍ទាំងនោះមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌបានធ្វើឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅតែពុំមានសិទ្ធិ និងការទទួលខុសត្រូវពេញលេញលើការ

គ្រប់គ្រងទ្រព្យសម្បត្តិទាំងនោះប្រកបដោយភាពម្ចាស់ការ និងមានប្រសិទ្ធភាពឡើយ។

### ង. លិខិតតុបករណ៍

លិខិតតុបករណ៍ដែលលើកយកមកវិភាគក្នុងការសិក្សាវាយតម្លៃនេះ សំដៅទៅលើការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធ និងសេចក្តីណែនាំបច្ចេកទេសស្តីពីគោលការណ៍ និងនីតិវិធីសម្រាប់អនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌអំពីលិខិតបទដ្ឋាន និងសេចក្តីណែនាំបច្ចេកទេសទាំងនេះ ដើម្បីជានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានការយល់ដឹង និងមានសមត្ថភាពសមស្របក្នុងការដឹកនាំ គ្រប់គ្រង និងចាត់ចែងលើការអនុវត្តមុខងារទាំងនោះប្រកបដោយប្រសិទ្ធភាព ស្របតាមនិយាម និងស្តង់ដាសេវាអប់រំដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

ផ្អែកតាមរបកគំហើញ បានបង្ហាញថា បន្ទាប់ពីការផ្ទេរមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ថ្នាក់ដឹកនាំ និងបុគ្គលិកពាក់ព័ន្ធមួយចំនួននៃរដ្ឋបាលក្រុង ស្រុក ខណ្ឌបានចូលរួមក្នុងពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលក្នុងពិធីប្រកាសផ្សព្វផ្សាយនេះ ថ្នាក់ដឹកនាំ និងបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌទទួលបានព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងគោលការណ៍សំខាន់ៗក្នុងការដឹកនាំ ការគ្រប់គ្រង និងការចាត់ចែងមុខងារអប់រំដែលបានផ្ទេរឱ្យតែប៉ុណ្ណោះ ដោយពុំទាន់មានការយល់ដឹងច្បាស់អំពីនីតិវិធីលម្អិតសម្រាប់អនុវត្តមុខងារអប់រំដែលបានផ្ទេរឱ្យទាំងនោះទេឡើយ។

ក្នុងស្ថានភាពនៃការអនុវត្តជាក់ស្តែងរហូតមកដល់ពេលនេះ ថ្នាក់ដឹកនាំ និងបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅពុំទាន់ទទួលបានការបណ្តុះបណ្តាលជាក់លាក់អំពីគោលការណ៍ បែបបទ និងនីតិវិធីលម្អិតនៃការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មទៅឱ្យនៅឡើយ។ ទោះយ៉ាងនេះក្តី តាមរយៈការចុះទៅតាមដាន ត្រួតពិនិត្យ និងការគាំទ្រផ្នែកបច្ចេកទេសម្តងម្កាលរបស់ក្រុមការងារពីថ្នាក់ជាតិ រួមមាន ក្រុមការងារក្រសួងអប់រំ យុវជន និងកីឡា ក្រុមការងារក្រសួងមហាផ្ទៃ ក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប. បានធ្វើឱ្យរដ្ឋបាលក្រុង ស្រុក ជាពិសេស រដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងទទួលបានការយល់ដឹងមួយចំនួនបន្ថែមទៀតសម្រាប់ដឹកនាំ គ្រប់គ្រង ចាត់ចែងមុខងារអប់រំដែលបានផ្ទេរឱ្យទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាព។

លិខិតតុបករណ៍ពាក់ព័ន្ធសំខាន់ៗដែលបានរៀបចំសម្រាប់បម្រើឱ្យការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌរួមមាន៖

- ប្រកាសអន្តរក្រសួងលេខ៥២១ សហវ ប្រ.ក. ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ផ្ទេរធនធានមានភ្ជាប់លក្ខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- សារាចរណែនាំ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីនីតិវិធីអនុវត្តថវិកា បញ្ជិកាគណនេយ្យ និងចលនាឥណទានថវិកានៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង

ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ

- សៀវភៅណែនាំស្តីពីគោលការណ៍ នីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលក្រុង ស្រុក (ឆ្នាំ ២០២២)
- គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិសាលារៀនសាធារណៈ (ឆ្នាំ២០១៨)

ក្រៅពីលិខិតតូបករណ៍ខាងលើ សេចក្តីណែនាំបច្ចេកទេសស្តីពីនីតិវិធីសម្រាប់អនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ បាន និងកំពុងរៀបចំដោយក្រុមការងារអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា និងលេខាធិការដ្ឋាន គ.ជ.អ.ប.។

ជារួម ក្រុមការងារបច្ចេកទេសអន្តរក្រសួងអាចវាយតម្លៃបានថា ភាពយឺតយ៉ាវនៃការរៀបចំ និងការបណ្តុះបណ្តាលអំពីសេចក្តីណែនាំបច្ចេកទេសស្តីពីនីតិវិធីអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនេះ គឺជាមូលហេតុចម្បងមួយដែលធ្វើឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌជួបការលំបាក ឬមានភាពស្រពិចស្រពិលក្នុងការដឹកនាំ គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យ ប្រកបដោយភាពរលូន និងមានប្រសិទ្ធភាពខ្ពស់។ ក្នុងន័យនេះ ដើម្បីធានាដល់ការបន្តជំរុញដល់ការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌប្រកបដោយភាពរលូន និងប្រសិទ្ធភាពខ្ពស់ គឺចាំបាច់ និងជាបន្ទាន់ត្រូវរៀបចំបញ្ចប់សេចក្តីណែនាំបច្ចេកទេសពីនីតិវិធីអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រូវរៀបចំការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធនានាអំពីសេចក្តីណែនាំបច្ចេកទេសនេះឱ្យបានឆាប់នៅក្នុងឆ្នាំ២០២៣នេះ។

### ច. យន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

យន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ សំដៅទៅលើការរៀបចំយន្តការទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់រាជធានី ខេត្តដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ការផ្ទេរមុខងារអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនាចុងឆ្នាំ២០១៩ គឺចំពេលដែលប្រទេសកម្ពុជាក៏ដូចជាប្រទេសនានាលើសកលលោកបានជួបវិបត្តិនៃការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ដែលតម្រូវឱ្យរាជរដ្ឋាភិបាលត្រូវមានវិធានការសុខាភិបាលនានាក្នុងការបិទខ្ទប់តំបន់មួយចំនួន ការផ្អាកការធ្វើដំណើរឆ្លងកាត់ពីតំបន់មួយទៅតំបន់មួយ និងការផ្អាកការធ្វើទំនាក់ទំនងដោយផ្ទាល់ជាដើម ដែលប្រការនេះបានធ្វើក្រសួង ស្ថាប័នពាក់ព័ន្ធនានាជួបការលំបាកក្នុងការចុះផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងតាមដានត្រួតពិនិត្យឱ្យបានញឹកញាប់ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌលើការអនុវត្តមុខងារអប់រំដែលបានផ្ទេរឱ្យ។ ទោះយ៉ាងនេះក្តី ផ្អែកតាមរបកគំហើញ ក្រុមការងារបច្ចេកទេសអន្តរក្រសួងអាចវិភាគ និងវាយតម្លៃបានថា៖

- ទោះបីក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិពុំទាន់បានរៀបចំយន្តការ និងពុំអាចរៀបចំ និងអនុវត្តផែនការសកម្មភាពជាក់លាក់សម្រាប់គាំទ្របច្ចេកទេស ការចុះតាមដាន ត្រួតពិនិត្យជាប្រចាំលើការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ដោយ ក៏ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិបានរៀបចំកិច្ចប្រជុំអនឡាញ (Online) មួយចំនួនជាមួយ

រដ្ឋបាលក្រុង ស្រុកនានាក្នុងខេត្តបាត់ដំបង ព្រមទាំងបានចុះគាំទ្រ តាមដាន ត្រួតពិនិត្យនៅតាមរដ្ឋបាលក្រុង ស្រុកមួយចំនួនបន្ទាប់ពីស្ថានភាពនៃវិបត្តិកូវីដ-១៩បានធូរស្រាយ ដើម្បីពិនិត្យ និងដោះស្រាយបញ្ហាប្រឈមជាគន្លឹះមួយចំនួនពាក់ព័ន្ធការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក

- នៅថ្នាក់រាជធានី ខេត្ត ទោះបីពុំទាន់បានរៀបចំជាយន្តការរួមមួយសម្រាប់សម្របសម្រួលការគាំទ្រផ្នែកបច្ចេកទេស និងតាមដាន ត្រួតពិនិត្យលើការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ដោយ ក៏រដ្ឋបាលរដ្ឋបាលរាជធានី ខេត្ត និងមន្ទីរពាក់ព័ន្ធបានផ្ដល់ការគាំទ្រផ្នែកបច្ចេកទេសមួយចំនួនក្នុងក្របខណ្ឌនៃដែនសមត្ថកិច្ចរបស់ខ្លួនដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមានដូចជា មន្ទីរអប់រំ យុវជន និងកីឡាបានអញ្ជើញថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុកចូលរួមកិច្ចប្រជុំនានាដើម្បីផ្សព្វផ្សាយ និងបង្កើនការយល់ដឹងអំពីការងារអប់រំ មន្ទីរមុខងារសាធារណៈបានផ្ដោតការគាំទ្រផ្នែកបច្ចេកទេសលើការងារបុគ្គលិកដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីបែបបទ និងនីតិវិធីនៃការគ្រប់គ្រងថវិកាអប់រំ រដ្ឋបាលខេត្តបានផ្ដោតលើការជំរុញ និងជួយដោះស្រាយបញ្ហាប្រឈមជាគន្លឹះពាក់ព័ន្ធការងារអប់រំដែលបានស្នើឡើងដោយរដ្ឋបាលក្រុង ស្រុក តាមរយៈកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ហើយរដ្ឋបាលខេត្តបាត់ដំបងក៏បានរៀបចំការសិក្សាវាយតម្លៃលើការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកផងដែរ
- ស្ថានភាពនៃការផ្ដល់ការគាំទ្រផ្នែកបច្ចេកទេស ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងមានភាពសកម្ម និងមានលក្ខណៈល្អប្រសើរជាងការគាំទ្របច្ចេកទេស និងការតាមដានត្រួតពិនិត្យលើការអនុវត្តមុខងារអប់រំដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្តដទៃទៀត ប្រការនេះបានធ្វើឱ្យការអនុវត្តមុខងារអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងទទួលបានលទ្ធផលល្អប្រសើរ
- ជារួម ការគាំទ្រផ្នែកបច្ចេកទេស ការតាមដានត្រួតពិនិត្យជាប្រចាំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌគឺជាកត្តាចាំបាច់ដើម្បីធានាដល់ការបន្តជំរុញ និងលើកកម្ពស់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យមានប្រសិទ្ធភាពខ្ពស់ និងសម្រេចបានតាមនិយាម និងស្តង់ដាសេវាដែលបានកំណត់។ ការខកខាន ឬភាពយឺតយ៉ាវក្នុងការរៀបចំយន្តការគាំទ្រជាក់លាក់ទាំងនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្តដោយសារវិបត្តិកូវីដ-១៩ បានធ្វើឱ្យបញ្ហាប្រឈមមួយចំនួនដែលបានជួបប្រទះដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានអូសបន្លាយរហូតមកដល់ពេលនេះ ជាពិសេសបញ្ហាប្រឈមពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡាជាដើម។

## ៨.២. អនុសាសន៍

ផ្អែកតាមរបកគំហើញ និងការវិភាគខាងលើ ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការពង្រីកការផ្ទេរមុខងារទាំងនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដទៃទៀត ក្រុមការងារបច្ចេកទេសអន្តរក្រសួងសូមលើកអនុសាសន៍មួយចំនួនដូចខាងក្រោម៖

**ទីមួយ៖** ដើម្បីធានាដល់ការដោះស្រាយបញ្ហាប្រឈមចំពោះមុខនានា គួររៀបចំកិច្ចប្រជុំបន្ទាន់មួយដើម្បីផ្តល់ការណែនាំ និងជំរុញឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌបន្តផ្តោតការយកចិត្តទុកដាក់ឱ្យបានហ្មត់ចត់បន្ថែមទៀតលើការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេស ត្រូវផ្តោតទៅលើការពង្រឹងការយល់ដឹងអំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវជាក់លាក់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ អំពីបែបផែននៃការអនុវត្តមុខងារអប់រំដែលបានផ្ទេរឱ្យ អំពីការគ្រប់គ្រង និងការប្រើប្រាស់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡា និងអំពីខ្សែគណនេយ្យភាពនិងទំនាក់ទំនងការងាររវាងសាលារៀនជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌជាមួយមន្ទីរអប់រំ យុវជន និងកីឡា ជាដើម។ កិច្ចប្រជុំនេះ គួររៀបចំឱ្យបានឆាប់ៗតាមដែលអាចធ្វើទៅបានក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដោយមានកិច្ចសហការរវាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និងត្រូវអញ្ជើញប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង ស្រុក ខណ្ឌទាំងអស់ឱ្យចូលរួមកិច្ចប្រជុំនេះ។

**ទីពីរ៖** ត្រូវបន្តជំរុញឱ្យក្រុមការងារបច្ចេកទេសអន្តរក្រសួងរវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. រៀបចំបញ្ចប់សេចក្តីណែនាំបច្ចេកទេសស្តីពីគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរៀបចំការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធអំពីសេចក្តីណែនាំបច្ចេកទេសនេះឱ្យបានឆាប់ក្នុងឆ្នាំ២០២៣នេះ។

**ទីបី៖** ក្រោមការសម្របសម្រួលរបស់ គ.ជ.អ.ប. ក្រុមការងារអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃត្រូវរៀបចំការសិក្សា វាយតម្លៃឱ្យបានស៊ីជម្រៅបន្ថែមអំពីបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់គាំទ្រការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យកែសម្រួលការវិភាជន៍ថវិកាសម្រាប់គាំទ្រប្រតិបត្តិការរបស់ការិយាល័យអប់រំ យុវជន និងកីឡាឱ្យបានសមស្របទៅតាមបន្ទុកការងារ និងស្ថានភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ព្រមទាំងការពិនិត្យ និងកែសម្រួលគោលការណ៍ និងនីតិវិធីសម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិកានេះ ជាពិសេស ថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡា ដើម្បីធានាឱ្យបានថា ការិយាល័យអប់រំ យុវជន និងកីឡាទទួលបានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារក្នុងវិស័យអប់រំឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមគ្នានេះ ត្រូវរៀបចំការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនានានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌអំពីគោលការណ៍ និងនីតិវិធីសម្រាប់គ្រប់គ្រង

ចាត់ចែង និងប្រើប្រាស់ថវិកាអប់រំនេះឱ្យមានការយល់ដឹងច្បាស់លាស់ និងអនុវត្តឱ្យមានប្រសិទ្ធភាព។

**ទីបួន៖** ត្រូវបន្តជំរុញការផ្ទេរជាផ្លូវការនូវទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗមានការទទួលខុសត្រូវប្រកបដោយភាព ម្ចាស់ការក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះប្រកបដោយប្រសិទ្ធភាព។

**ទីប្រាំ៖** ក្រសួងមុខងារសាធារណៈត្រូវបន្តការផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌអំពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានការយល់ដឹងច្បាស់លាស់ និងមានសមត្ថភាពសមស្របក្នុងការរៀបចំ និងការគ្រប់គ្រងបុគ្គលិកអប់រំឱ្យចំទិសដៅក្នុងការងារអប់រំឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**ទីប្រាំមួយ៖** ពង្រឹង និងរៀបចំឱ្យមានយន្តការគាំទ្រច្បាស់លាស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ដើម្បីធានាដល់ការគាំទ្រផ្នែកបច្ចេកទេស ការអភិវឌ្ឍសមត្ថភាព និងការតាមដាន ត្រួតពិនិត្យជាប្រចាំ និងវាយតម្លៃដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ទីប្រាំពីរ៖** ផ្អែកតាមបរកគំហើញនៃមេរៀន បទពិសោធន៍ និងលទ្ធផលជាវិជ្ជមានក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបង ព្រមទាំងការគាំទ្រ និងពេញចិត្តរបស់អ្នកពាក់ព័ន្ធនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិអាចជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការពង្រីកការប្រគល់មុខងារក្នុងវិស័យអប់រំដូចដែលបានអនុវត្តនៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេសចាប់ពីឆ្នាំ២០២៤តទៅ។

## ៩. សេចក្តីសន្និដ្ឋាន

ផ្អែកតាមបរកគំហើញពីការសិក្សាវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រុមការងារបច្ចេកទេសអន្តរក្រសួងអាចសន្និដ្ឋានជារួមបានថា ទោះបីការផ្ទេរមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌចំពេលដែលជួបស្ថានភាពលំបាកនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ ក៏ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនោះពុំមានហានិភ័យធ្ងន់ធ្ងរឡើយ។ ផ្ទុយមកវិញស្ថានភាពនៃការគ្រប់គ្រងនៅតាមសាលារៀននីមួយៗ ជាពិសេសសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងកាន់តែមានស្ថានភាពល្អប្រសើរឡើង ដោយសារថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកមានឆន្ទៈ និងការទទួលខុសត្រូវប្រកបដោយភាពម្ចាស់ការ និងបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការគ្រប់គ្រង ការចាត់ចែង ការតាមដានត្រួតពិនិត្យ និងការដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារអប់រំទាំងនោះបានយ៉ាងឆាប់រហ័ស និងទាន់ពេលវេលា ព្រមទាំងបានកៀរគរការគាំទ្រ និងការជំរុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ រួមទាំងរដ្ឋបាលឃុំ សង្កាត់ សហគមន៍មូលដ្ឋាន និងសប្បុរសជននានាក្នុងការផ្តល់សេវាអប់រំដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានកាន់តែសកម្ម និងផុលផុស។

ទោះយ៉ាងនេះក្តី ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏បានជួបបញ្ហាប្រឈមជាគន្លឹះមួយចំនួនពាក់ព័ន្ធនឹងកម្រិតនៃសិទ្ធិអំណាចកិច្ចការរដ្ឋបាល និងការគ្រប់គ្រងធនធាន រួមមានទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលទាមទារឱ្យមានការពិនិត្យ និងកែសម្រួល រួមជាមួយនឹងការពង្រឹងយន្តការគាំទ្រ ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការដោះស្រាយបញ្ហាប្រឈមនានាឱ្យបានឆាប់រហ័សទាន់ពេលវេលា ដើម្បីធានាឱ្យការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌអាចអនុវត្តបានដោយរលូនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ជាពិសេសធានាបាននូវគុណភាពអប់រំល្អប្រសើរជាលំដាប់។

ការរៀបចំ និងការអនុវត្តតាមអនុសាសន៍ដូចបានកំណត់ក្នុងរបាយការណ៍នៃការសិក្សាវាយតម្លៃនេះ គឺជាវិធានការសមស្របមួយសម្រាប់ធានាដល់ការលើកកម្ពស់គុណភាពសេវាអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នោះគឺការបង្វិតសេវាឱ្យទៅកៀកជិតប្រជាពលរដ្ឋ។

# ឧបសម្ព័ន្ធទី១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប

ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ៖ .០៣១..[illegible]..../គ.ជ.អ.ប

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់សិក្សា វាយតម្លៃ លើការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២២ របស់ គ.ជ.អ.ប

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត ក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្រាប់សិក្សាវាយតម្លៃលើការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម ចាន់ សុផា | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និង ជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាប្រធាន |
| ២. ឯកឧត្តម ពេជ្រ វិជ្ជាគន្ធី | អនុរដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | ជាអនុប្រធាន |
| ៣. ឯកឧត្តម ទេព តិយ្យោរិទ្ធ | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា | ជាអនុប្រធាន |
| ៤. ឯកឧត្តម ហុក ប៉េងសែ | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៥. ឯកឧត្តម ប្អូន ហេង | ប្រធាននាយកដ្ឋានមុខងារ និងធនធាននៃ ក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៦. ឯកឧត្តម ឌី សុវណ្ណា | អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាល ថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧. លោក ប៉ុក សុគន្ធដារ៉ា | អគ្គលេខាធិការសមាគមក្រុមប្រឹក្សា រដ្ឋបាលថ្នាក់ក្រោមជាតិ | ជាសមាជិក |
| ៨. លោក ឈឹម សុភាគ | អគ្គលេខាធិការរងសមាគមក្រុមប្រឹក្សា រដ្ឋបាលថ្នាក់ក្រោមជាតិ | ជាសមាជិក |
| ៩. ឯកឧត្តមបណ្ឌិត នៀ សុផន | ប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងអប់រំ យុវជន និងកីឡា | ជាសមាជិក |
| ១០. ឯកឧត្តមបណ្ឌិត ស៊ន សេងហុក | ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងអប់រំ យុវជន និងកីឡា | ជាសមាជិក |
| ១១. លោក ជ័យ សម្បត្តិផល្លា | ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោល នយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក |
| ១២. លោក អុន ស៊ីទុធថា | ប្រធាននាយកដ្ឋានផែនការ ក្រសួងអប់រំ យុវជន និងកីឡា | ជាសមាជិក |
| ១៣. លោក លី យ៉ាសាក់ | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៤. លោក ឡាយ សុខឃៀង | ប្រធាននាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋាន ថវិកាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ១៥. លោក សិក ហេងឡុង | ប្រធានមជ្ឈមណ្ឌល ក្រសួងមុខងារសាធារណៈ | ជាសមាជិក |
| ១៦. លោក មុំ ណារ៉ែន | អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោល | |

នយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសមាជិក

១៧. លោកស្រី គង់ ប៊ុណ្ណា អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោល
នយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសមាជិក

១៨. លោកស្រី ហេង សិន្ធា អនុប្រធានអង្គភាពត្រួតពិនិត្យ វាយតម្លៃ
និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសមាជិក

១៩. លោក ហេង គង់ម៉េង អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក
ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ ជាសមាជិក

២០. លោក សួន សំរិទ្ធ អនុប្រធាននាយកដ្ឋានមុខងារ និងធនធាន
ក្រសួងមហាផ្ទៃ ជាសមាជិក

២១. លោក ឡុង ចាន់តុលា អនុប្រធាននាយកដ្ឋានតាមដាននិងវាយតម្លៃ
អគ្គនាយកដ្ឋានថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

២២. លោកស្រី ជា គីម អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ
យុវជន និងកីឡា ជាសមាជិក

២៣. លោក ហាន ជាលុយ អនុប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងអប់រំ
យុវជន និងកីឡា ជាសមាជិក

២៤. លោក ណុប ពិសិទ្ធ អនុប្រធាននាយកដ្ឋាន ក្រសួងមុខងារសាធារណៈ ជាសមាជិក

២៥. លោក លឹម សិរីឧត្តរី ប្រធានការិយាល័យនៃនាយកដ្ឋាននីតិកម្ម
ក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិក

២៦. លោក ប៊ុន ម៉ានិត ប្រធានការិយាល័យមុខងារនៃអង្គភាពវិភាគ
និងអភិវឌ្ឍន៍គោលនយោបាយ
លេខាធិការដ្ឋានគ.ជ.អ.ប ជាសមាជិក

២៧. លោក ខ្វាន់ ចន្ទីឧត្តម ប្រធានការិយាល័យនៃនាយកដ្ឋានកិច្ចការរដ្ឋបាល
រាជធានី ខណ្ឌ និងខេត្ត ក្រសួងមហាផ្ទៃ ជាសមាជិក

២៨. លោក ជា ម៉េង ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានថវិកា
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

២៩. លោក មុខ ពុទ្ធរស្មី ប្រធានការិយាល័យ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាល
ថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

៣០. លោក ចន ជឿន អនុប្រធានការិយាល័យមុខងារ និងធនធាន
ក្រសួងមហាផ្ទៃ ជាសមាជិក

៣១. លោកស្រី សោ សុជា	អនុប្រធានការិយាល័យមុខងារ និងធនធាន ក្រសួងមហាផ្ទៃ ជាសមាជិក

៣២. លោក សយ សិទ្ធិកា	មន្ត្រីគ្រប់គ្រងរដ្ឋបាល និងធនធានមនុស្ស នៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ជាសមាជិក។

**ប្រការ ២.-**

ក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម ៖

- រៀបចំឯកសារទស្សនទានសម្រាប់ការសិក្សាវាយតម្លៃលើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រៀបចំផែនការសកម្មភាពសម្រាប់ការសិក្សាវាយតម្លៃលើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- កំណត់វិធីសាស្ត្រសម្រាប់ការសិក្សាវាយតម្លៃ ដែលធានាឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ដោយមិនលំអៀងក្នុងកិច្ចដំណើរការនៃការសិក្សាវាយតម្លៃនេះ
- រៀបចំកម្រងបញ្ជីសំណួរនានាដើម្បីធានាដល់ការប្រមូលព័ត៌មានបានគ្រប់ជ្រុងជ្រោយពីក្រុមគោលដៅពាក់ព័ន្ធនានា
- ជ្រើសរើសរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងក្រុមគោលដៅពាក់ព័ន្ធនានាដែលត្រូវចុះជួបពិភាក្សា និងប្រមូលព័ត៌មាន មតិយោបល់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការវិភាគ ថ្លឹងថ្លែង និងវាយតម្លៃ
- បូកសរុបព័ត៌មាន និងរបកគំហើញនានា ដើម្បីវិភាគស្វែងរកចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងកំណត់អនុសាសន៍ និងជម្រើសនានាសម្រាប់ការកែលម្អ និងការពង្រីកការប្រគល់មុខងារក្នុងវិស័យអប់រំនេះទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌផ្សេងទៀត
- រៀបចំកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់ជាមួយតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាដើម្បីឆ្លុះបញ្ចាំងរបកគំហើញ និងអនុសាសន៍នានានៃការសិក្សាវាយតម្លៃ
- រៀបចំរបាយការណ៍អំពីលទ្ធផលនៃការសិក្សាវាយតម្លៃលើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់ដាក់ជូន គ.ជ.អ.ប ដើម្បីពិនិត្យ និងសម្រេច
- បំពេញការងារផ្សេងៗទៀត តាមការណែនាំ និងតាមការចាំបាច់។

**ប្រការ ៣.-**

ក្រុមការងារអន្តរក្រសួងនេះមានសិទ្ធិប្រើប្រាស់មន្ត្រី ទីប្រឹក្សា ឧបករណ៍ សម្ភារៈ មធ្យោបាយធ្វើដំណើរ និងថវិការបស់ក្រសួង ស្ថាប័ន និងអង្គភាពសាមីសម្រាប់អនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនក្នុងកិច្ចដំណើរការសិក្សាវាយតម្លៃនេះ។

**ប្រការ ៤.-**

ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ លេខាធិការដ្ឋាន គ.ជ.អ.ប. អគ្គលេខាធិការដ្ឋាននៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១ កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**សម្ដេចក្រឡាហោម ស ខេង**

កន្លែងទទួល ៖

- ទីស្ដីការគណរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប.
- រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ
- ដូចប្រការ ៤
- ឯកសារកាលប្បវត្តិ

## ឧបសម្ព័ន្ធទី២

## បញ្ជីសំណួរសម្រាប់រដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង

### I. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានពីក្រុមប្រឹក្សា អភិបាល អភិបាលរង នាយករដ្ឋបាល ប្រធាន និងមន្ត្រីនៃការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ការិយាល័យគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលក្រុង ស្រុក

### ក. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មាន/ស្វង់មតិជាលក្ខណៈបុគ្គល

សូមបំពេញចម្លើយដោយគូសសញ្ញា √ នៅក្នុងប្រអប់ ☐ ណាមួយដែលជាចម្លើយរបស់លោក លោក ស្រីចំពោះសំណួរដូចខាងក្រោម៖

<u>ព័ត៌មានទូទៅ៖</u>

១. តើលោក លោកស្រីពេញចិត្តលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ឱ្យរដ្ឋបាលក្រុង ស្រុកយ៉ាងដូចម្តេច? (មុខងារអប់រំកុមារតូច អប់រំបឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ)

ពេញចិត្តខ្លាំង ☐ ពេញចិត្តធម្មតា ☐ មិនពេញចិត្ត ☐

២. តើលោក លោកស្រីពេញចិត្តលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រតិភូកម្មឱ្យរដ្ឋបាលក្រុង ស្រុកយ៉ាងដូចម្តេច? (កិច្ចការរដ្ឋបាលគាំទ្រមធ្យមសិក្សាចំណេះទូទៅ ការអភិវឌ្ឍយុវជន និងការអប់រំកាយ និងកីឡា)

ពេញចិត្តខ្លាំង ☐ ពេញចិត្តធម្មតា ☐ មិនពេញចិត្តទេ ☐

៣. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះស្ថានភាពនៃការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់មកឱ្យរដ្ឋបាលក្រុង ស្រុក? (មុខងារអប់រំកុមារតូច អប់រំបឋមសិក្សា អប់រំក្រៅប្រព័ន្ធ)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៤. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក? (កិច្ចការរដ្ឋបាលគាំទ្រមធ្យមសិក្សាចំណេះទូទៅ ការអភិវឌ្ឍយុវជន និងអប់រំកាយ និងកីឡា)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

<u>ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកអប់រំ៖</u>

៥. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រងបុគ្គលិកអប់រំដែលបានធ្វើសមាហរណកម្មមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក?

| | | | |
|---|---|---|---|
| ៥.១. ការតែងតាំង៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៥.២. ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៥.៣. ការផ្លាស់ប្តូរ៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៥.៤. ការចូលនិវត្តន៍៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៥.៥. ការគ្រប់គ្រងវត្តមានបុគ្គលិកអប់រំ៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |

៥.៦. ជារួម តើសមត្ថភាពដឹកនាំគ្រប់គ្រងបុគ្គលិកអប់រំ របស់រដ្ឋបាលក្រុង ស្រុក ដូចម្តេច?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងថវិកាសម្រាប់អនុវត្តមុខងារអប់រំ៖

៦. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក (ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព)?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៧. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះស្ថានភាពនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់ប្រតិបត្តិការនៅតាមសាលារៀននីមួយៗដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក? (បង្កលក្ខណៈកាន់តែងាយស្រួល ឆាប់រហ័យ ដោះស្រាយបញ្ហាចំទិសដៅ)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំ៖

៨. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារនានាសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក?

ល្អប្រជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

ព័ត៌មានពាក់ព័ន្ធនឹងគណនេយ្យភាពក្នុងការផ្តល់សេវាអប់រំ៖

៩. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចអំពីការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកចំពោះប្រជាពលរដ្ឋក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក (ការពិគ្រោះយោបល់ និងការឆ្លើយតបទៅនឹងសំណើសំណូមពររបស់ប្រជាពលរដ្ឋចំពោះសេវាអប់រំ)?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

១០.តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចអំពីការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកចំពោះក្រសួង/មន្ទីរអប់រំ យុវជន និងកីឡាក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានផ្ទេរឱ្យ? (ការអនុវត្តតាមនីតិវិធី និងស្តង់ដាដែលបានកំណត់ ការធ្វើរបាយការណ៍...)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

ខ.បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានតាមរយៈកិច្ចប្រជុំពិភាក្សា

១. តើលោក លោកស្រីយល់ឃើញថាមានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះចំពោះការអនុវត្តមុខងារការអប់រំកុមារតូច មុខងារការអប់រំបឋមសិក្សា មុខងារការអប់រំក្រៅប្រព័ន្ធ បន្ទាប់ពីមុខងារទាំងនេះត្រូវបានប្រគល់មកឱ្យរដ្ឋបាលក្រុង ស្រុក? សូមបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ផង?

២. តើលោក លោកស្រីយល់ឃើញថាមានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះចំពោះការអនុវត្តមុខងារ មុខងារគាំទ្រកិច្ចការរដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សា ការអភិវឌ្ឍយុវជន និងការអប់រំកាយ និងកីឡា បន្ទាប់ពីមុខងារទាំងនេះត្រូវបានផ្ទេរប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក? សូមបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ផង?

៣. ក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់មកឱ្យរដ្ឋបាលក្រុង ស្រុក (មុខងារការអប់រំកុមារតូច មុខងារការអប់រំបឋមសិក្សា មុខងារការអប់រំក្រៅប្រព័ន្ធ) តើរដ្ឋបាលក្រុង ស្រុកបានជួបបញ្ហាប្រឈមជាគន្លឹះអ្វីខ្លះ? និងធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៤. ក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរប្រតិភូកម្មមកឱ្យរដ្ឋបាល ក្រុង ស្រុក (មុខងារគាំទ្រកិច្ចការរដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សា ការអភិវឌ្ឍយុវជន និងការអប់រំកាយ និងកីឡា) តើរដ្ឋបាលក្រុង ស្រុកបានជួបបញ្ហាប្រឈមជាគន្លឹះអ្វីខ្លះ? និងធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៥. តើរដ្ឋបាលក្រុង ស្រុកធ្លាប់បានផ្តួចផ្តើមគំនិត និងផ្តល់អន្តរាគមន៍គាំទ្រអ្វីខ្លះដើម្បីជំរុញ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ និងផ្ទេរប្រតិភូកម្មឱ្យ? (ការណែនាំតម្រង់ទិសអំពីប្រព័ន្ធគ្រប់គ្រងកិច្ចការរដ្ឋបាល ការបង្កើតយន្តការសម្រាប់គាំទ្របន្ថែម ការផ្តល់អាទិភាពដល់ការងារអប់រំ ការកៀរគរធនធានដើម្បីផ្តល់ការគាំទ្រការងារអប់រំ....)

៦. តើការគ្រប់គ្រងបុគ្គលិកអប់រំ (បុគ្គលិកការិយាល័យអប់រំ និងគ្រូបង្រៀននៅតាមសាលាបឋមសិក្សា មត្តេយ្យសាលា និងមជ្ឈមណ្ឌលសិក្សាសហគមន៍) មានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះ? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងតើធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៧. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការរៀបចំ ការគ្រប់គ្រង និងការប្រើប្រាស់កញ្ចប់ថវិកាសម្រាប់គាំទ្រការិយាល័យអប់រំ យុវជន និងកីឡា កញ្ចប់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការសាលារៀន ថវិកាសម្រាបគាំទ្រមជ្ឈមណ្ឌលសិក្សាសហគមន៍? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងតើធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៨. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារសម្រាប់អនុវត្តមុខងារអប់រំដែលបានប្រគល់ និងផ្ទេរប្រតិភូកម្មឱ្យ? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ?និងតើធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៩. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះទំនាក់ទំនងការងាររវាងការិយាល័យអប់រំ យុវជន និងកីឡាជាមួយនឹងការិយាល័យ អង្គភាពពាក់ព័ន្ធ នាយករដ្ឋបាល គណៈអភិបាល និងក្រុមប្រឹក្សានៃរដ្ឋបាលក្រុង ស្រុក? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងតើធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

១០.តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះទំនាក់ទំនងការងាររដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងតើធ្លាប់បានដោះស្រាយ

បញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

១១.តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រងមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ និងធ្វើប្រតិភូកម្មឱ្យទាំងនេះ? តើត្រូវមានការគាំទ្រអ្វីខ្លះបន្ថែមទៀតពីថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីជានាឱ្យរដ្ឋបាលក្រុង ស្រុកអាចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យកាន់តែមានប្រសិទ្ធភាព? (មានសេចក្តីណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងមុខងារទាំងនោះហើយ ឬនៅ?

១២.តើលោក លោកស្រីមានមេរៀន និងបទពិសោធន៍ល្អៗអ្វីខ្លះក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យ ដើម្បីផ្តល់អនុសាសន៍សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារទាំងនេះទៅពេលអនាគតផង និងសម្រាប់ពង្រីកការប្រគល់មុខងារទាំងនេះទៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្តដទៃទៀតផង?

## II. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានពីប្រធាន អនុប្រធាន មន្ត្រីការិយាល័យអប់រំ នាយកសាលាបឋមសិក្សា នាយកសាលាមត្តេយ្យសិក្សានៃរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង

### ក. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មាន/ស្ទង់មតិជាលក្ខណៈបុគ្គល

សូមបំពេញចម្លើយដោយគូសសញ្ញា √ នៅក្នុងប្រអប់ ☐ ណាមួយដែលជាចម្លើយរបស់លោក លោក ស្រីចំពោះសំណួរដូចខាងក្រោម៖

**ព័ត៌មានទូទៅ៖**

១. តើលោក លោកស្រីពេញចិត្តក្នុងការអនុវត្តតួនាទីសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុកលើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ឱ្យរដ្ឋបាលក្រុង ស្រុកយ៉ាងដូចម្តេច? (មុខងារអប់រំកុមារតូច អប់រំបឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ)

ពេញចិត្តខ្លាំង ☐ ពេញចិត្តធម្មតា ☐ មិនពេញចិត្តទេ ☐

២. តើលោក លោកស្រីពេញចិត្តក្នុងការអនុវត្តតួនាទីសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុកលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រតិភូកម្មឱ្យរដ្ឋបាលក្រុង ស្រុកយ៉ាងដូចម្តេច? (កិច្ចការរដ្ឋបាលគាំទ្រមធ្យមសិក្សាចំណេះទូទៅ ការអភិវឌ្ឍយុវជន និងការអប់រំកាយ និងកីឡា)

ពេញចិត្តខ្លាំង ☐ ពេញចិត្តធម្មតា ☐ មិនពេញចិត្តទេ ☐

៣. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះស្ថានភាពនៃការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់មកឱ្យរដ្ឋបាលក្រុង ស្រុក? (មុខងារអប់រំកុមារតូច អប់រំបឋមសិក្សា អប់រំក្រៅប្រព័ន្ធ)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៤. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះស្ថានភាពនៃការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក? (កិច្ចការរដ្ឋបាលគាំទ្រមធ្យមសិក្សាចំណេះទូទៅ ការអភិវឌ្ឍយុវជន និងការអប់រំកាយ និងកីឡា)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

## ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកអប់រំ៖

៥. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្ដេចចំពោះការគ្រប់គ្រងបុគ្គលិកអប់រំដែលបានធ្វើសមាហរណកម្មមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក?

| | | | |
|---|---|---|---|
| ៥.១. ការតែងតាំង៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៥.២. ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៥.៣. ការផ្លាស់ប្ដូរ៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៥.៤. ការចូលនិវត្តន៍៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៥.៥. ការគ្រប់គ្រងវត្តមានបុគ្គលិកអប់រំ៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |

៥.៦. ជារួម តើសមត្ថភាពដឹកនាំគ្រប់គ្រងបុគ្គលិកអប់រំ របស់រដ្ឋបាលក្រុង ស្រុក ដូចម្ដេច?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

## ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងថវិកាសម្រាប់អនុវត្តមុខងារអប់រំ៖

៦. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្ដេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាគាំទ្រការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក (ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព)?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៧. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្ដេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាគាំទ្រប្រតិបត្តិការសាលារៀននីមួយៗដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក? (បង្កលក្ខណៈកាន់តែងាយស្រួល ឆាប់រហ័ស ដោះស្រាយបញ្ហាចំទិសដៅ)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

## ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំ៖

៨. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្ដេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារនានាសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

## ព័ត៌មានពាក់ព័ន្ធនឹងគណនេយ្យភាពក្នុងការផ្ដល់សេវាអប់រំ៖

៩. តើការផ្លាស់ប្ដូរខ្សែគណនេយ្យភាពរបស់ការិយាល័យអប់រំ យុវជន និងកីឡាពីការធ្វើគណនេយ្យភាពដោយផ្ទាល់ជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត មកធ្វើគណនេយ្យភាពដោយផ្ទាល់ជាមួយរដ្ឋបាលក្រុង ស្រុកបានធ្វើឱ្យមានការផ្លាស់ប្ដូរនូវប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំកុមារតូច មុខងារអប់រំបឋមសិក្សា មុខងារអប់រំក្រៅប្រព័ន្ធ មុខងារគាំទ្រផ្នែករដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សា មុខងារការអភិវឌ្ឍយុវជន និងមុខងារការអប់រំកាយ និងកីឡា យ៉ាងដូចម្ដេច? (ប្រសិទ្ធ

ភាពការងារ ការរាយការណ៍ ការផ្ដល់អន្ដរាគមការគាំទ្រដើម្បីដោះស្រាយបញ្ហានានា)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

១០.តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្ដេចចំពោះការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុក ជាមួយក្រសួង/មន្ទីរអប់រំ យុវជន និងកីឡាក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានផ្ទេរឱ្យ (ទាំងមុខងារដែលបានប្រគល់ និងមុខងារដែលបានធ្វើប្រតិភូកម្ម)? (ការអនុវត្តតាមនីតិវិធី និងស្តង់ដាដែលបានកំណត់ ការធ្វើរបាយការណ៍...)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

## ខ. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានតាមរយៈកិច្ចប្រជុំពិភាក្សា

១. តើលោក លោកស្រីយល់ឃើញថាមានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះចំពោះការអនុវត្តមុខងារការអប់រំកុមារតូច មុខងារការអប់រំបឋមសិក្សា និងមុខងារការអប់រំក្រៅប្រព័ន្ធ បន្ទាប់ពីមុខងារទាំងនេះត្រូវបានប្រគល់មកឱ្យរដ្ឋបាលក្រុង ស្រុក? សូមបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ផង?

២. តើលោក លោកស្រីយល់ឃើញថាមានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះចំពោះការអនុវត្តមុខងារគាំទ្រការងាររដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សា មុខងារអភិវឌ្ឍយុវជន និងមុខងារអប់រំកាយ និងកីឡា បន្ទាប់ពីមុខងារទាំងនេះត្រូវបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក? សូមបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ផង?

៣. បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡា គ្រឹះស្ថានបឋមសិក្សា និងមតេយ្យសិក្សាមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក តើការអនុវត្តតួនាទីរបស់ការិយាល័យអបរំ យុវជន និងកីឡា និងតួនាទីរបស់នាយកសាលាបានជួបបញ្ហាប្រឈមជាគន្លឹះអ្វីខ្លះ? ហើយបានដោះស្រាយបញ្ហាប្រឈមទាំងនោះដោយរបៀបណា?

៤. តើរដ្ឋបាលក្រុង ស្រុកធ្លាប់បានផ្តួចផ្តើមគំនិត និងផ្តល់អន្តរាគមន៍គាំទ្រអ្វីខ្លះដើម្បីជំរុញ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មឱ្យ? (ការណែនាំតម្រង់ទិសអំពីប្រព័ន្ធគ្រប់គ្រងការងារ ការបង្កើតយន្តការសម្រាប់គាំទ្របន្ថែម ការផ្តល់អាទិភាពខ្លាំងដល់ការងារអប់រំ ការកៀរគរធនធានដើម្បីផ្តល់ការគាំទ្រដល់ការងារអប់រំ.....)

៥. បន្ទាប់ពីការផ្ទេរបុគ្គលិកអប់រំ(បុគ្គលិកនៃការិយាល័យអប់រំ និងគ្រូបង្រៀននៅតាមសាលាបឋមសិក្សាមត្តេយ្យសាលា និងមជ្ឈមណ្ឌលសិក្សាសហគមន៍) មកស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រងបុគ្គលិកអប់រំដែលបានផ្ទេរទាំងនោះ? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? ធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៦. បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យអប់រំ និងការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក តើលោក លោកស្រីយល់យ៉ាងដូចម្តេចចំពោះការរៀបចំ ការគ្រប់គ្រង និងការប្រើប្រាស់កញ្ចប់ថវិកាសម្រាប់គាំទ្រការិយាល័យអប់រំ យុវជន និងកីឡា កញ្ចប់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការសាលា

រៀន ថវិកាសម្រាប់គាំទ្រមជ្ឈមណ្ឌលសិក្សាសហគមន៍? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៧. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារសម្រាប់អនុវត្តមុខងារអប់រំដែលបានផ្ទេរឱ្យ? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៨. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះទំនាក់ទំនងការងាររវាងការិយាល័យអប់រំ យុវជន និងកីឡា ជាមួយនឹងការិយាល័យ អង្គភាពពាក់ព័ន្ធ នាយករដ្ឋបាល គណៈអភិបាល និងក្រុមប្រឹក្សានៃរដ្ឋបាលក្រុង ស្រុក? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៩. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះទំនាក់ទំនងការងាររដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ?និងធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

១០.តើលោក លោកស្រីយល់ឃើញថា រដ្ឋបាលក្រុង ស្រុកមានសមត្ថភាពដឹកនាំ គ្រប់គ្រង ចាត់ចែងមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យប្រកបដោយប្រសិទ្ធភាព ស្របតាមស្តង់ដាបច្ចេកទេសដែលបានកំណត់ហើយឬនៅ? និងតើត្រូវមានការគាំទ្រអ្វីខ្លះបន្ថែមទៀតពីថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីធានាដល់ការគ្រប់គ្រងមុខងារទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព?

១១.តើលោក លោកស្រីមានមេរៀន និងបទពិសោធន៍ល្អៗអ្វីខ្លះក្នុងការអនុវត្តតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុកលើគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក ដើម្បីផ្តល់អនុសាសន៍សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារទាំងនេះទៅពេលអនាគតផង និងសម្រាប់ពង្រីកការប្រគល់មុខងារទាំងនេះទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌផង?

## III.បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានពីតំណាងគ្រូបង្រៀននៅតាមសាលាបឋមសិក្សា និងសាលាមត្តេយ្យនៃរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបង

### ក. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មាន/ស្ទង់មតិជាលក្ខណៈបុគ្គល

សូមបំពេញចម្លើយដោយគូសសញ្ញា √ នៅក្នុងប្រអប់ ☐ ណាមួយដែលជាចម្លើយរបស់លោក លោក ស្រីចំពោះសំណួរដូចខាងក្រោម៖

**ព័ត៌មានទូទៅ៖**

១. តើលោក លោកស្រីពេញចិត្តចំពោះការផ្ទេរគ្រូបង្រៀននៅតាមសាលាបឋមសិក្សា សាលាមត្តេយ្យ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ឱ្យមកស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកយ៉ាងដូចម្តេច?

ពេញចិត្តខ្លាំង ☐ ពេញចិត្តធម្មតា ☐ មិនពេញចិត្តទេ ☐

២. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះស្ថានភាពនៃការគ្រប់គ្រងសាលារៀនបឋមសិក្សា

សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ បន្ទាប់ពីសាលារៀនទាំងនេះត្រូវបានប្រគល់ឱ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក? (សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ វិធានការការពារកូវីដ ការរក្សាអនាម័យ សុវត្ថិភាពការធ្វើដំណើរការរបស់សិស្សានុសិស្ស.....)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

<u>ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកអប់រំ</u>

៣. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រងបុគ្គលិកអប់រំដែលបានធ្វើសមាហរណកម្មមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក?

៣.១. ការតែងតាំង៖ ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៣.២. ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ៖ ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៣.៣. ការផ្លាស់ប្តូរ៖ ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៣.៤. ការចូលនិវត្តន៍៖ ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៣.៥. ការគ្រប់គ្រងវត្តមានបុគ្គលិកអប់រំ៖ ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៣.៦. ជារួម តើសមត្ថភាពដឹកនាំគ្រប់គ្រងបុគ្គលិកអប់រំ របស់រដ្ឋបាលក្រុង ស្រុក ដូចម្តេច?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

<u>ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងថវិកាសម្រាប់អនុវត្តមុខងារអប់រំ</u>

៤. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាគាំទ្រប្រតិបត្តិការសាលារៀននីមួយៗដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក? (បង្កលក្ខណៈកាន់តែងាយស្រួល ឆាប់រហ័យ ដោះស្រាយបញ្ហាចំទិសដៅ)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

<u>ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំ</u>

៥. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ដីធ្លី ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារនានានៅតាមសាលារៀនដែលបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

<u>ព័ត៌មានពាក់ព័ន្ធនឹងគណនេយ្យភាពក្នុងការផ្តល់សេវាអប់រំ</u>

៦. បន្ទាប់ពីមានការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកចាប់ពីឆ្នាំ២០២០មក តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការចុះមកត្រួតពិនិត្យ និងគាំទ្ររបស់ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក និងមន្ត្រីការិយាល័យអប់រំក្រុង ស្រុកនៅតាមសាលារៀន?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

### ខ. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានតាមរយៈកិច្ចប្រជុំពិភាក្សា

១. តើលោក លោកស្រីយល់ឃើញថា មានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះចំពោះការគ្រប់គ្រងជា

ទូទៅនៅតាមសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ បន្ទាប់ពីមុខងារគ្រប់គ្រងសាលាទាំងនេះត្រូវបានប្រគល់មកស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក? សូមបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ផង? (សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ វិធានការការពារកូវីដ ការរក្សាអនាម័យ សុវត្ថិភាពការធ្វើដំណើរការរបស់សិស្សានុសិស្ស.....)

២. តើលោក លោកស្រីយល់ឃើញថា មានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះចំពោះសកម្មភាពអភិវឌ្ឍយុវជន និងសកម្មភាពអប់រំកាយ និងកីឡានៅតាមសាលារៀន បន្ទាប់ពីមុខងារទាំងនេះត្រូវបានធ្វើប្រតិភូកម្មមកស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក? សូមបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ផង?

៣. បន្ទាប់ពីការផ្ទេរបុគ្គលិកអប់រំ (បុគ្គលិកនៃការិយាល័យអប់រំ និងគ្រូបង្រៀននៅតាមសាលាបឋមសិក្សា មត្តេយ្យសាលា និងមជ្ឈមណ្ឌលសិក្សាសហគមន៍) មកស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រងគ្រូបង្រៀនដែលកំពុងបំពេញការងារនៅតាមសាលារៀនទាំងនោះ? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? ធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៤. បន្ទាប់ពីការផ្ទេរសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍មកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក តើលោក លោកស្រីយល់យ៉ាងដូចម្តេចចំពោះការរៀបចំការគ្រប់គ្រង និងការប្រើប្រាស់កញ្ចប់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការសាលារៀន និងថវិកាសម្រាប់គាំទ្រមជ្ឈមណ្ឌលសិក្សាសហគមន៍? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៥. បន្ទាប់ពីការផ្ទេរសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍មកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារនៅតាមសាលារៀនទាំងនោះ? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ?និងធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៦. បន្ទាប់ពីការផ្ទេរសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍មកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក តើលោក លោកស្រីសង្កេតឃើញថារដ្ឋបាល ក្រុង ស្រុក បានផ្តល់ការគាំទ្រ ឬកៀរគរការគាំទ្រអ្វីខ្លះ ដើម្បីសកម្មភាពអភិវឌ្ឍនានានៅតាមសាលារៀន? សូមរៀបរាប់?

៧.តើលោក លោកស្រីមានមេរៀន និងបទពិសោធន៍ល្អៗខ្លះ ដើម្បីផ្តល់អនុសាសន៍សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀនទៅពេលអនាគតផង និងសម្រាប់ពង្រីកការប្រគល់មុខងារទាំងនេះទៅរដ្ឋបាលក្រុង ស្រុកដទៃទៀតផង?

## IV. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានពីមេឃុំ ចៅសង្កាត់ និងតំណាងប្រជាពលរដ្ឋ

### ក. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មាន/ស្ទង់មតិជាលក្ខណៈបុគ្គល

សូមបំពេញចម្លើយដោយគូសសញ្ញា √ នៅក្នុងប្រអប់ ☐ ណាមួយដែលជាចម្លើយរបស់លោក

លោក ស្រីចំពោះសំណួរដូចខាងក្រោម៖

<u>ព័ត៌មានទូទៅ៖</u>

១. បន្ទាប់ពីមានការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកចាប់ពីឆ្នាំ២០២០មក តើលោកលោកស្រីយល់ឃើញថា ការគ្រប់គ្រងសាលាបឋមសិក្សា សាលាមត្តេយ្យ និងមជ្ឈមណ្ឌលសិក្សាសហគមន៍មានការប្រែប្រួលយ៉ាងដូចម្តេច? (សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ វិធានការការពារកូវីដ ការរក្សាអនាម័យ សុវត្ថិភាពការធ្វើដំណើរការរបស់សិស្សានុសិស្ស.....)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

២. បន្ទាប់ពីមានការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកចាប់ពីឆ្នាំ២០២០មក តើលោកលោកស្រីយល់ឃើញថា រដ្ឋបាលក្រុង ស្រុកបានផ្តោតការយកចិត្តទុកដាក់លើការផ្តល់អន្តរាគមន៍ ការគាំទ្រ ការដោះស្រាយបញ្ហាប្រឈមនានានៅតាមសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍យ៉ាងដូចម្តេច?

ច្រើនជាងមុន ☐ ដូចមុន ☐ តិចជាងមុន ☐

<u>ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកអប់រំ៖</u>

៣. បន្ទាប់ពីមានការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកចាប់ពីឆ្នាំ២០២០មក តើលោកលោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះស្ថានភាពនៃគ្រប់គ្រងគ្រូបង្រៀននៅតាមសាលាបឋមសិក្សាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍? (ការគ្រប់គ្រងវត្តមានគ្រូបង្រៀន ការបង្រៀនតាមនិយាមដែលបានកំណត់....)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

<u>ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងថវិកាសម្រាប់អនុវត្តមុខងារអប់រំ៖</u>

៤. បន្ទាប់ពីមានការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកចាប់ពីឆ្នាំ២០២០មក តើលោកលោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការប្រើប្រាស់ថវិកាប្រតិបត្តិការនៅតាមសាលារៀន? (ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ឆាប់រហ័យ ដោះស្រាយបញ្ហាចំទិសដៅ)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

<u>ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំ៖</u>

៥. បន្ទាប់ពីមានការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកចាប់ពីឆ្នាំ២០២០មក តើលោកលោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ដីធ្លី ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារនានានៅតាមសាលារៀន?

ល្អប្រជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

<u>ព័ត៌មានពាក់ព័ន្ធនឹងគណនេយ្យភាពក្នុងការផ្តល់សេវាអប់រំ៖</u>

៦. បន្ទាប់ពីមានការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកចាប់ពីឆ្នាំ២០២០មក តើលោកលោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការចុះមកត្រួតពិនិត្យ និងគាំទ្ររបស់ថ្នាក់ដឹកនាំនៃរដ្ឋបាល

ក្រុង ស្រុក និងមន្ត្រីការិយាល័យអប់រំក្រុង ស្រុកនៅតាមសាលារៀន?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

### ខ. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានតាមរយៈកិច្ចប្រជុំពិភាក្សា

១. បន្ទាប់ពីមានការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកចាប់ពីឆ្នាំ២០២០មក តើលោក លោកស្រីសង្កេតឃើញថាមានការផ្លាស់ប្តូរអ្វីខ្លះនៅតាមសាលារៀនបឋមសិក្សា និងមត្តេយ្យសិក្សា? និងសង្កេតឃើញបញ្ហាប្រឈមគួរឱ្យកត់សម្គាល់អ្វីខ្លះ? (បរិស្ថាន សន្តិសុខ របៀបរៀបរយ អនាម័យ សុវត្ថិភាពនៃការធ្វើដំណើររបស់សិស្សានុសិស្ស ការគ្រប់គ្រងគ្រូបង្រៀន ការគ្រប់គ្រង និងប្រើប្រាស់ ថវិកាសាលារៀន សណ្តាប់ធ្នាប់សាធារណៈនៅតាមសាលារៀន....ជាដើម)

២. បន្ទាប់ពីមានការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកចាប់ពីឆ្នាំ២០២០មក តើរដ្ឋបាលក្រុង ស្រុកធ្លាប់បានពិភាក្សាការងារ ឬពិគ្រោះយោបល់ជាមួយរដ្ឋបាលឃុំ សង្កាត់ និងគណៈកម្មាធិការទ្រទ្រង់សាលា ដើម្បីកៀគរការចូលរួមគាំទ្រ និងដោះស្រាយបញ្ហាប្រឈមនានាដែរ ឬទេ? សូមរៀបរាប់?

៣. បន្ទាប់ពីមានការផ្ទេរមុខងារក្នុងវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុកចាប់ពីឆ្នាំ២០២០មក តើរដ្ឋបាលឃុំ សង្កាត់ និងគណៈកម្មាធិការទ្រទ្រង់សាលាបានចូលរួម និងគាំទ្រអ្វីខ្លះដល់ការចូលរួមអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក?

៤.តើលោក លោកស្រីមានមេរៀន និងបទពិសោធន៍ល្អៗអ្វីខ្លះក្នុងការចូលរួមអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក ដើម្បីផ្តល់អនុសាសន៍សម្រាប់ការពង្រីកការប្រគល់មុខងារទាំងនេះទៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្តដទៃទៀត?

## V. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានអភិបាលខេត្ត ប្រធាន និងមន្ត្រីពាក់ព័ន្ធនៃមន្ទីរអប់រំ យុវជន និងកីឡា មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរមុខងារ និងរតនាគារខេត្តបាត់ដំបង

### ក. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មាន/ស្ទង់មតិជាលក្ខណៈបុគ្គល

សូមបំពេញចម្លើយដោយគូសសញ្ញា √ នៅក្នុងប្រអប់ ☐ ណាមួយដែលជាចម្លើយរបស់លោក លោក ស្រីចំពោះសំណួរដូចខាងក្រោម៖

**ព័ត៌មានទូទៅ៖**

១. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះស្ថានភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក? (មុខងារអប់រំកុមារតូច អប់រំបឋមសិក្សា អប់រំក្រៅប្រព័ន្ធ)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

២. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះស្ថានភាពនៃការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក? (កិច្ចការ

រដ្ឋបាលគាំទ្រមធ្យមសិក្សាចំណេះទូទៅ ការអភិវឌ្ឍយុវជន ការអប់រំកាយ និងកីឡា)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកអប់រំ៖

៣. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រងបុគ្គលិកអប់រំដែលបានធ្វើសមាហរណកម្មមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក?

៣.១. ការតែងតាំង៖ ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៣.២. ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ៖ ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៣.៣. ការផ្លាស់ប្តូរ៖ ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៣.៤. ការចូលនិវត្តន៍៖ ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៣.៥. ការគ្រប់គ្រងវត្តមានបុគ្គលិកអប់រំ៖ ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៣.៦. ជារួម តើសមត្ថភាពដឹកនាំគ្រប់គ្រងបុគ្គលិកអប់រំ របស់រដ្ឋបាលក្រុង ស្រុក ដូចម្តេច?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងថវិកាសម្រាប់អនុវត្តមុខងារអប់រំ៖

៤. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់ការិយាល័យអប់រំ យុវជន និងកីឡាដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក (ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព)?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៥. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះស្ថានភាពនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់ប្រតិបត្តិការនៅតាមសាលារៀននីមួយៗដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក? (បង្គលក្ខណៈកាន់តែងាយស្រួល ឆាប់រហ័យ ដោះស្រាយបញ្ហាចំទិសដៅ)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំ៖

៦. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារនានាសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក?

ល្អប្រជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

ព័ត៌មានពាក់ព័ន្ធនឹងគណនេយ្យភាពក្នុងការផ្តល់សេវាអប់រំ៖

៩. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចអំពីការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកចំពោះប្រជាពលរដ្ឋក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក (ការពិគ្រោះយោបល់ និងការឆ្លើយតបទៅហ្នឹងសំណើសំណូម

ពររបស់ប្រជាពលរដ្ឋចំពោះសេវាអប់រំ)?

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

១០.តើឯកឧត្តម លោកជំទាវ លោក លោកស្រីឃើញយ៉ាងដូចម្តេចអំពីការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក? (ការអនុវត្តតាមនីតិវិធី និងស្តង់ដាដែលបានកំណត់ការធ្វើរបាយការណ៍...)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

## ខ. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានតាមរយៈកិច្ចប្រជុំពិភាក្សា

១. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញថាមានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះចំពោះការអនុវត្តមុខងារការអប់រំកុមារតូច មុខងារការអប់រំបឋមសិក្សា និងមុខងារការអប់រំក្រៅប្រព័ន្ធបន្ទាប់ពីមុខងារទាំងនេះត្រូវបានប្រគល់មកឱ្យរដ្ឋបាលក្រុង ស្រុក? សូមបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ផង?

២. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញថាមានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះចំពោះការអនុវត្តមុខងារគាំទ្រកិច្ចការរដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សា មុខងារការអភិវឌ្ឍយុវជន និងមុខងារការអប់រំកាយ និងកីឡា បន្ទាប់ពីមុខងារទាំងនេះត្រូវបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក? សូមបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ផង?

៣. តើឯកឧត្តម លោកជំទាវ លោក លោកស្រីដឹងថា ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុកបានជួបបញ្ហាប្រឈមជាគន្លឹះអ្វីខ្លះ? និងធ្លាប់បានផ្តល់អន្តរាគមន៍ដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៤. តើឯកឧត្តម លោកជំទាវ លោក លោកស្រីបានដឹងថា រដ្ឋបាលក្រុង ស្រុកធ្លាប់បានផ្តួចផ្តើមគំនិត និងផ្តល់អន្តរាគមន៍គាំទ្រអ្វីខ្លះដើម្បីជំរុញ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យ? (ការណែនាំតម្រង់ទិសអំពីប្រព័ន្ធគ្រប់គ្រងការងាររដ្ឋបាល ការបង្កើតយន្តការសម្រាប់គាំទ្របន្ថែម ការផ្តល់អាទិភាពដល់ការងារអប់រំ ការកៀរគរធនធានដើម្បីផ្តល់ការគាំទ្រដល់ការងារអប់រំ....)

៥. តើឯកឧត្តម លោកជំទាវ លោក លោកស្រីដឹងទេថា ការគ្រប់គ្រងបុគ្គលិកអប់រំ (បុគ្គលិកការិយាល័យអប់រំ និងគ្រូបង្រៀននៅតាមសាលាបឋមសិក្សា មត្តេយ្យសាលា និងមជ្ឈមណ្ឌលសិក្សាសហគមន៍) របស់រដ្ឋបាលក្រុង ស្រុកមានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះ? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងតើធ្លាប់បានផ្តល់អន្តាគមន៍ដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៦. តើឯកឧត្តម លោកជំទាវ លោក លោកស្រីដឹងទេថា ការរៀបចំ ការគ្រប់គ្រង និងការប្រើប្រាស់កញ្ចប់ថវិកាសម្រាប់គាំទ្រការិយាល័យអប់រំ យុវជន និងកីឡា កញ្ចប់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការសាលារៀន ថវិកាសម្រាបគាំទ្រមជ្ឈមណ្ឌលសិក្សាសហគមន៍មានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានយ៉ាងដូច

ម្តេច? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងតើធ្លាប់បានផ្តល់អន្តរាគមន៍ដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៧. តើឯកឧត្តម លោកជំទាវ លោក លោកស្រីដឹងទេថាការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារសម្រាប់អនុវត្តមុខងារអប់រំរបស់រដ្ឋបាលក្រុង ស្រុកជួបបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងតើធ្លាប់បានផ្តល់អន្តរគមន៍ដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៨. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះទំនាក់ទំនងការងាររដ្ឋបាលក្រុង ស្រុកជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត? តើមានបញ្ហាប្រឈមជាចម្បងអ្វីខ្លះ? និងតើធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

៩. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ថាយ៉ាងដូចម្តេចចំពោះសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រង ចាត់ចែង មុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យ? ត្រូវមានការគាំទ្រអ្វីខ្លះបន្ថែមទៀតពីថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុកអាចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរឱ្យកាន់តែមានប្រសិទ្ធភាព? (មានសេចក្តីណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងមុខងារទាំងនោះហើយ ឬនៅ?

១០.តើឯកឧត្តម លោកជំទាវ លោក លោកស្រីមានអនុសាសន៍អ្វីខ្លះសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារទាំងនេះទៅពេលអនាគត និងសម្រាប់ពង្រីកការប្រគល់មុខងារទាំងនេះទៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្តដទៃទៀតផង?

## បញ្ជីសំណួរសម្រាប់រដ្ឋបាលក្រុង ស្រុកក្នុងខេត្តផ្សេងទៀតក្រៅពីខេត្តបាត់ដំបង

### I. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានពីក្រុមប្រឹក្សា អភិបាល អភិបាលរង នាយករដ្ឋបាល ប្រធាន និងមន្ត្រីនៃការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ការិយាល័យគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលក្រុង ស្រុក

### ក. បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មាន/ស្ទង់មតិជាលក្ខណៈបុគ្គល

សូមបំពេញចម្លើយដោយគូសសញ្ញា √ នៅក្នុងប្រអប់ □ ណាមួយដែលជាចម្លើយរបស់លោក លោក ស្រី ចំពោះសំណួរដូចខាងក្រោម៖

<u>ព័ត៌មានទូទៅ៖</u>

១. តើលោក លោកស្រីពេញចិត្តកម្រិតណាចំពោះការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក? (***សម្គាល់៖*** *មុខងារដែលបានផ្ទេរប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក រួមមាន មុខងារអប់រំកុមារតូច អប់រំបឋមសិក្សា អប់រំក្រៅប្រព័ន្ធ កិច្ចការរដ្ឋបាលគាំទ្រមធ្យមសិក្សាចំណេះទូទៅ ការអភិវឌ្ឍយុវជន ការអប់រំកាយ និងកីឡា។ ការិយាល័យអប់រំ យុវជន និងកីឡារួមទាំងបុគ្គលិក និងថវិកាត្រូវបានការផ្ទេរសមាហរណកម្មមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលរដ្ឋបាលក្រុង ស្រុក។ គ្រូបង្រៀន និងថវិកាសម្រាប់គាំទ្រប្រតិបត្តិការនៅតាមសាលារៀនបឋមសិក្សា មត្តេយ្យសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងសាលារៀននីមួយៗ។ រដ្ឋបាលក្រុង ស្រុកមានតួនាទីសំខាន់ក្នុងការជួយជំរុញ សម្របសម្រួល គាំទ្រ ពិនិត្យ និងផ្តល់យោបល់ និងលើកសំណើនានា។*)

ពេញចិត្តខ្លាំង □ ពេញចិត្តធម្មតា □ មិនពេញចិត្ត □

២. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះស្ថានភាព ឬលទ្ធផលនៃការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក? (*ស្ថានភាពទូទៅពាក់ព័ន្ធនឹងការងារសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ វិធានការការពារកូវីដ ការរក្សាអនាម័យ សុវត្ថិភាពការធ្វើដំណើរការរបស់សិស្សានុសិស្ស សកម្មភាពអភិវឌ្ឍយុវជន ការអប់រំកាយ និងកីឡានៅតាមសាលារៀន*)

ល្អជាងមុន □ ដូចមុន □ អន់ជាងមុន □

<u>ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកអប់រំ៖</u>

៣. តើលោក លោកស្រីយល់ឃើញថា មានការប្រែប្រួលយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង**បុគ្គលិកនៃការិយាល័យអប់រំ**ដែលបានធ្វើសមាហរណកម្មមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក?

| | | | |
|---|---|---|---|
| ៣.១. ការតែងតាំង៖ | ល្អជាងមុន □ | ដូចមុន □ | អន់ជាងមុន □ |
| ៣.២. ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ៖ | ល្អជាងមុន □ | ដូចមុន □ | អន់ជាងមុន □ |
| ៣.៣. ការផ្លាស់ប្តូរ៖ | ល្អជាងមុន □ | ដូចមុន □ | អន់ជាងមុន □ |
| ៣.៤. ការចូលនិវត្តន៍៖ | ល្អជាងមុន □ | ដូចមុន □ | អន់ជាងមុន □ |
| ៣.៥. ការគ្រប់គ្រងវត្តមានបុគ្គលិកអប់រំ៖ | ល្អជាងមុន □ | ដូចមុន □ | អន់ជាងមុន □ |

៤. តើលោក លោក ស្រីយល់ឃើញថា មានការប្រែប្រួលយ៉ាងដូចម្តេចចំពោះការគ្រប់គ្រង**គ្រូបង្រៀននៅតាមសាលារៀន** បន្ទាប់ពីគ្រូនៅសាលារៀនទាំងនេះត្រូវបានធ្វើប្រតិភូកម្មមករដ្ឋបាលក្រុង ស្រុក? (***សម្គាល់៖*** *គ្រូបង្រៀននៅតាមសាលារៀនស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់មន្ទីរ/ក្រសួងអប់រំ យុវជន និងកីឡា ដោយពុំទាន់ត្រូវបានផ្ទេរឱ្យស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកនៅឡើយ ក៏ប៉ុន្តែរដ្ឋបាលក្រុង ស្រុកមានតួនាទី*

*សំខាន់ក្នុងការជួយជំរុញ តាមដាន ត្រួតពិនិត្យ ផ្ដល់យោបល់ និងលើកសំណើនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងការចាត់ចែង និងការប្រើប្រាស់គ្រូបង្រៀននៅតាមសាលារៀនទាំងនោះ*)

| | | | |
|---|---|---|---|
| ៤.១. ការតែងតាំង៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៤.២. ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៤.៣. ការផ្លាស់ប្ដូរ៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៤.៤. ការចូលនិវត្តន៍៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |
| ៤.៥. ការគ្រប់គ្រងវត្តមានបុគ្គលិកអប់រំ៖ | ល្អជាងមុន ☐ | ដូចមុន ☐ | អន់ជាងមុន ☐ |

**ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងថវិកាសម្រាប់អនុវត្តមុខងារអប់រំ៖**

៥. តើលោក លោកស្រីយល់ឃើញថា មានការប្រែប្រួលយ៉ាងដូចម្ដេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក (ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព)? (***សម្គាល់៖*** *ថវិកាសម្រាប់គាំទ្រប្រតិបត្តិការរបស់ការិយាល័យអប់រំ យុវជន និងកីឡាត្រូវផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក។ រដ្ឋបាលក្រុង ស្រុកត្រូវគ្រប់គ្រងចាត់ចែងថវិកានេះជាកញ្ចប់ថវិកាមានភ្ជាប់លក្ខខណ្ឌសម្រាប់ការិយាល័យអប់រំ យុវជន និងកីឡា*)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

៦. តើលោក លោកស្រីយល់ឃើញថា មានការប្រែប្រួលយ៉ាងដូចម្ដេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកាសម្រាប់គាំទ្រប្រតិបត្តិការសាលាបឋមសិក្សា មត្តេយ្យសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ (ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព) បន្ទាប់ពីសាលារៀនទាំងនេះត្រូវបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក? (***សម្គាល់៖*** *ថវិកាគាំទ្រប្រតិបត្តិការតាមសាលារៀនស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់មន្ទីរអប់រំ និងសាលារៀនសាមីនីមួយៗ។ រដ្ឋបាលក្រុង ស្រុកមានតួនាទីជួយជំរុញ គាំទ្រ សម្របសម្រួល តាមដានត្រួតពិនិត្យ ផ្ដល់យោបល់ និងលើកសំណើនានាពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកានៅតាមសាលារៀននីមួយៗ*)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

**ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំ៖**

៧. តើលោក លោកស្រីយល់ឃើញថា មានការប្រែប្រួលយ៉ាងដូចម្ដេចចំពោះការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារនានាសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំដែលបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក? (***សម្គាល់៖*** *រដ្ឋបាលក្រុង ស្រុកមានតួនាទីជួយគាំទ្រ សម្របសម្រួល តាមដានត្រួតពិនិត្យ ផ្ដល់យោបល់ និងលើកសំណើនានាពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសម្បត្តិនៅតាមសាលារៀននីមួយៗ*)

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

**ព័ត៌មានពាក់ព័ន្ធនឹងគណនេយ្យភាពក្នុងការផ្ដល់សេវាអប់រំ៖**

៨. តើលោក លោកស្រីយល់ឃើញយ៉ាងដូចម្ដេចអំពីការធ្វើគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកចំពោះក្រសួង/មន្ទីរអប់រំ យុវជន និងកីឡាក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក? *(ការប្រែប្រួលពាក់ព័ន្ធនឹងការអនុវត្តការងារតាមនីតិវិធី និងស្តង់ដាដែលបានកំណត់ ការធ្វើរបាយការណ៍...ជាដើម)*

ល្អជាងមុន ☐ ដូចមុន ☐ អន់ជាងមុន ☐

**ព័ត៌មានពាក់ព័ន្ធនឹងការពង្រីកការប្រគល់មុខងារក្នុងវិស័យអប់រំ៖**

៩. ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំ តើលោក លោកស្រីយល់ឃើញថាជម្រើសណាមួយដែលសមស្របជាង?

**៩.១. ចំពោះមុខងារអប់រំកុមារតូច**

ប្រគល់មកក្រុង ស្រុក □ រក្សាធ្វើប្រតិភូកម្មដដែល □

**៩.២. ចំពោះមុខងារអប់រំបឋមសិក្សា**

ប្រគល់មកក្រុង ស្រុក □ រក្សាធ្វើប្រតិភូកម្មដដែល □

**៩.៣. ចំពោះមុខងារអប់រំក្រៅប្រព័ន្ធ**

ប្រគល់មកក្រុង ស្រុក □ រក្សាធ្វើប្រតិភូកម្មដដែល □

**៩.៤. ចំពោះមុខងារគាំទ្រកិច្ចការរដ្ឋបាលដល់គ្រឹះស្ថានធម្យមសិក្សា**

ប្រគល់មកក្រុង ស្រុក □ រក្សាធ្វើប្រតិភូកម្មដដែល □

**៩.៥. ចំពោះមុខងារការអភិវឌ្ឍយុវជន**

ប្រគល់មកក្រុង ស្រុក □ រក្សាធ្វើប្រតិភូកម្មដដែល □

**៩.៦. ចំពោះមុខងារអប់រំកាយ និងកីឡា**

ប្រគល់មកក្រុង ស្រុក □ រក្សាធ្វើប្រតិភូកម្មដដែល □

## ខ.បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានតាមរយៈកិច្ចប្រជុំពិភាក្សា

១. តើលោក លោកស្រីយល់ឃើញថាមានការផ្លាស់ប្តូរជាវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះចំពោះការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក? សូមបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ផង?

២. ក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាល ក្រុង ស្រុក តើរដ្ឋបាលក្រុង ស្រុកបានជួបបញ្ហាប្រឈមជាគន្លឹះអ្វីខ្លះ? និងធ្លាប់បានដោះស្រាយបញ្ហាប្រឈមទាំងនោះយ៉ាងដូចម្តេច?

